**Declassified to Public**
**28 October 2021**



**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**

**សំណុំរឿង:** ០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស

**បញ្ជូនទៅ:** សហចៅក្រមស៊ើបអង្កេត

**កាលបរិច្ឆេទនៃឯកសារ:** ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨

**ភាគីបញ្ជូន:** ការិយាល័យសហព្រះរាជអាជ្ញា

**ភាសាដើម:** អង់គ្លេស

**ប្រភេទឯកសារ:** សម្ងាត់

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 28-Nov-2016, 10:23
CMS/CFO: Sann Rada

---

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា

---

**បញ្ជូនដោយ:**

**ការិយាល័យសហព្រះរាជអាជ្ញា**

អ្នកស្រី ជា លាង

លោក Robert PETIT

លោក យ៉ែត ចរិយា

លោក William SMITH

**ចែកជូនដល់:**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

# មាតិកា

**សេចក្ដីផ្ដើម**...............................................................................៥

**សេចក្ដីសង្ខេបអង្គហេតុ**....................................................................៦

សេចក្ដីសង្ខេបរយៈកាលកម្ពុជាប្រជាធិបតេយ្យ...........................................៦

រចនាសម្ព័ន្ធភូមិភាគ តំបន់ និងស្រុករបស់ប.ក.ក.................... .............................. .៨

បទឧក្រិដ្ឋកម្ម...........................................................................................១០

*ភូមិភាគកណ្ដាល*......................................................................................១០

ការបោសសម្អាតនៅភូមិភាគកណ្ដាល.......................................................១០

មន្ទីរសន្ដិសុខវត្តអូរត្រកួន...........................................................................១២

មន្ទីរសន្ដិសុខវត្តបាធាយ.............................................................................១៣

មន្ទីរសន្ដិសុខ មិត្តសុប (គរ) .......................................................................១៣

មន្ទីរសន្ដិសុខវត្តភ្នំប្រុស...............................................................................១៤

មន្ទីរសន្ដិសុខគោកព្រីង................................................................................១៥

មន្ទីរសន្ដិសុខចំការស្វាយចន្ទី.......................................................................១៥

ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ..............................................១៦

ការប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម.......................................................១៦

មន្ទីរសន្ដិសុខវត្តស្រង៉ែ.................................................................................២០

គុកនិងកន្លែងសម្លាប់ទួលតាផ្លុង....................................................................២១

មន្ទីរសន្ដិសុខវត្តកណ្ដាល..............................................................................២១

មន្ទីរសន្ដិសុខវត្តបារាយជាន់ដែក..................................................................២២

*ភូមិភាគពាយ័ព្យ*......................................................................................២២

ការបោសសម្អាតនៅភូមិភាគពាយ័ព្យ...........................................................២២

វត្តគីរីរម្យ...................................................................................................២៤

ទីតាំងសម្លាប់នៅបន្ទាយអូតាក្រៃ....................................................................២៥
មន្ទីរសន្តិសុខបន្ទាយត្រែង.............................................................................២៥
មន្ទីរសន្តិសុខវត្តធម្មយុត...............................................................................២៥
មន្ទីរសន្តិសុខវត្តកណ្ដាល...............................................................................២៦
មន្ទីរសន្តិសុខវត្តសម្ដេច.............................................................................. ....២៧
មន្ទីរសន្តិសុខវត្តពោធិ៍លង្ការ.........................................................................២៧
មន្ទីរសន្តិសុខវត្តបន្ទាយនាង..........................................................................២៧
ទីតាំងសម្លាប់នៅល្អាងភ្នំគួយយំ....................................................................២៨
ទីតាំងសម្លាប់នៅវត្តចំការខ្នុរ.........................................................................២៨
គុកលេខ៨...................................................................................................២៨
ទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ....................................................................២៩
មន្ទីរសន្តិសុខភ្នំទ្រយោង...............................................................................២៩
មន្ទីរសន្តិសុខភូមិចក្រី..................................................................................៣០
វត្តព្រះនេត្រព្រះនិងចំការតាឡឹង...................................................................៣០
ទំនប់ត្រពាំងថ្ម..............................................................................................៣១
ស្ពានស្រែងនិងទំនប់ព្រៃរនាម.......................................................................៣១
*ភូមិភាគនិរតី*................................................................................................៣១
មន្ទីរសន្តិសុខវត្តព្រះធាតុ..............................................................................៣១
ជនសង្ស័យ..................................................................................................៣២
*តាម៉ុក*........................................................................................................៣២
ប្រវត្តិរូបផ្ទាល់ខ្លួន.........................................................................................៣២
សិទ្ធិអំណាច................................................................................................៣៣
ការចូលរួមនិងការដឹងឮ................................................................................៣៥
*តាទិត*........................................................................................................៣៨
ប្រវត្តិរូបផ្ទាល់ខ្លួន.........................................................................................៣៨
សិទ្ធិអំណាច................................................................................................៣៨

ការចូលរួមនិងការដឹងលឮ....................................................................៤០

*អ៊ឹម ចែម*.......................................................................................៤២

ព័ត៌មានផ្ទាល់ខ្លួន........................................................................៤២

សិទ្ធិអំណាច.............................................................................៤២

ការចូលរួម និងការដឹងឮ.............................................................៤៤

**បទល្មើសដែលបានចោទប្រកាន់**.....................................................................៤៥

**សំណើ**................................................................................ .......................៤៩

**ឯកសារយោងជាប្រភពភស្តុតាង និងប្រភពច្បាប់**...........................................៥២

# សេចក្ដីផ្ដើម

១. យើង សហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)៖

(១) បានឃើញច្បាប់អ.វ.ត.ក

(២) បានឃើញវិធានផ្ទៃក្នុងអ.វ.ត.ក

(៣) បានឃើញសំណុំរឿងលេខ០០៤ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០០៨ និង

(៤) ក្រោយពីបានធ្វើការស៊ើបសួរបឋមរួចហើយ ឃើញមានដូចតទៅ:

២. ចាប់តាំងនៅដើមឆ្នាំ១៩៧៧ **តាអាន** បានដឹកនាំកម្មាភិបាលមួយក្រុមពីភូមិភាគនិរតី ដែលបានធ្វើការបោសសម្អាត និងជំនួសកម្មាភិបាលភូមិភាគកណ្ដាល (ភូមិភាគឧត្តរចាស់)។ ដោយសារតែការបោសសម្អាតនេះ **តាអាន** បានក្លាយជាអនុលេខាភូមិភាគកណ្ដាល និង ជាលេខា តំបន់៤១។ នៅមុនពេលដឹកនាំការបោសសម្អាតភូមិភាគកណ្ដាល **តាអាន** គឺជា សមាជិកគណៈអចិន្ត្រៃយ៍តំបន់៣៥នៅភូមិភាគនិរតី និងជាសភាតំណាងប្រជាជនមួយរូបដែលត្រូវបានជ្រើសតាំង។

៣. នៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨ កម្មាភិបាលភូមិភាគនិរតីមួយក្រុមផ្សេងទៀតដឹកនាំដោយ តាម៉ុក និង **តាទិត** បានបោសសម្អាត និង ជំនួសកម្មាភិបាលភូមិពាយ័ព្យ។ ដោយសារការបោសសម្អាតនេះ **តាទិត** បានក្លាយជាលេខាស្ដីទីភូមិភាគពាយ័ព្យ និងជាលេខាតំបន់១ ។ មុនពេលដឹកនាំការបោសសម្អាតភូមិភាគពាយ័ព្យ **តាទិត** ជាលេខាស្រុកគីរីវង់នៃភូមិភាគនិរតី នៅក្នុងឆ្នាំ១៩៧៦ និង ១៩៧៧។

៤. នៅខែមិថុនា ឆ្នាំ១៩៧៧ ជាផ្នែកមួយនៃការបោសសម្អាតភូមិភាគពាយ័ព្យទ្រង់ទ្រាយធំ ដឹកនាំដោយ តាម៉ុក និង **តាទិត, អ៊ឹម ចែម** បានដឹកនាំការបោសសម្អាតស្រុកព្រះនេត្រព្រះ ក្នុងតំបន់៥ នៃភូមិភាគពាយ័ព្យ និងបានក្លាយជាលេខាស្រុកព្រះនេត្រព្រះ។ គាត់បានបង្កើត និង ទទួលខុសត្រូវមន្ទីរសន្តិសុខតំបន់៥នៅភ្នំទ្រយោង និងបានប្រើប្រាស់ឥទ្ធិពលយ៉ាងច្រើននៅទូទាំងតំបន់៥។ ពីឆ្នាំ១៩៧៦ ដល់ខែឧសភា ឆ្នាំ១៩៧៧ **អ៊ឹម ចែម** ជាលេខាស្រុកកោះអណ្ដែត នៃភូមិភាគនិរតី។

៥. ដោយសារតែការបោសសម្អាតទាំងនេះសហព្រះរាជអាជ្ញាមានហេតុផលនាំឱ្យជឿជាក់ថា:

(១) **តាអាន** ក្នុងឋានៈជាអនុលេខាភូមិភាគកណ្តាល និង ជាលេខាតំបន់៤១ ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានកើតឡើងនៅក្នុងភូមិភាគកណ្តាល ដូចដែលមានរៀបរាប់នៅក្នុងកថាខណ្ឌ១៨ ដល់ ៥៣។

(២) **តាទិត** ក្នុងឋានៈជាលេខាស្តីទីភូមិភាគពាយ័ព្យ និង ជាលេខាតំបន់១ ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានកើតឡើងនៅក្នុងភូមិភាគពាយ័ព្យ ដូចដែលមានរៀបរាប់នៅក្នុង កថាខណ្ឌ៥៤ ដល់ ៧៩ ។ នៅក្នុងឋានៈជាលេខាស្រុកគីរីវង់ គាត់ក៏ទទួលខុសត្រូវដែរ ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងភូមិភាគនិរតី ដូចដែលមានរៀបរាប់នៅក្នុងកថាខណ្ឌ៨០ ដល់ ៨១។

(៣) **អ៊ឹម ចែម** នៅក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងភូមិភាគពាយ័ព្យ ដូចដែលមានរៀបរាប់នៅក្នុងកថាខណ្ឌ៥៤ ដល់ ៥៩ និង ពី៧៤ ដល់ ៧៩។

## សេចក្តីសង្ខេបអង្គហេតុ

### សេចក្តីសង្ខេបរយៈកាលកម្ពុជាប្រជាធិបតេយ្យ

៦. ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ដែលត្រូវបានហៅជាទូទៅថា ខ្មែរក្រហម បានស្វះស្វែងកែប្រែសង្គមកម្ពុជាយ៉ាងសម្បើមឱ្យស្រប តាមខ្សែបន្ទាត់មនោគមន៍វិជ្ជា តាមរយៈការកែប្រែសេដ្ឋកិច្ច និងសង្គមយ៉ាងគំហុក។ ដូចដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីមួយរបស់ សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧(កថាខណ្ឌ៥ ដល់១០) ផែនការឧក្រិដ្ឋរួមមាន អត្ថិភាពនៅក្នុងចំណោមមេដឹកនាំ ប.ក.ក ក្នុងការបង្កើតសង្គមមួយ មិនមានវណ្ណៈ មិនមានអាទិទេព និងមានជាតិពន្ធតែមួយដូចគ្នា ដោយលុបបំបាត់ចោលនូវភាពខុសគ្នាផ្នែកក្រុមជាតិពន្ធ ក្រុមជាតិ សាសនា វណ្ណៈ និង វប្បធម៌ទាំងអស់។

៧. គោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក តម្រូវឱ្យមានការជម្លៀសប្រជាជនពីទីក្រុង និងស្ទើរតែធ្វើឱ្យប្រជាជនទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យក្លាយជាទាសករនៅក្នុងសហករណ៍កសិកម្ម រោងចក្រ និង ការដ្ឋានការងារដែលមានលក្ខណៈអមនុស្សធម៌ និងគ្មានក្តីមេត្តា។ អ្វីមួយ ឬ នរណាម្នាក់ដែល ប.ក.ក យល់ថា ជាការគំរាមកំហែង ឬ ជាឧបសគ្គចំពោះគោលនយោបាយ និង មនោគមន៍វិជ្ជារបស់ខ្លួន នឹងត្រូវសម្លាប់ ឬ កម្ទេច ដែលរួមមានទាំងសាសនា ភាពខុសប្លែកគ្នាផ្នែកជាតិពន្ធ វណ្ណៈ[1]

"អ្នកសក្តិភូមិ" "នាយទុន" "គហបតី" និង រាល់អ្នកដែលរបបនោះគិតថាជា"ខ្មាំង" ឬ "ជនក្បត់" ទាំងអស់នៅក្នុងចំណោមប្រជាជន ឬ នៅក្នុងជួរកម្មាភិបាលប.ក.ក[2]។ ក្រុមជាក់លាក់ដែលជាមុខសញ្ញារបស់ ប.ក.ក រួមមាន "ប្រជាជនថ្មី"[3] អ្នកដែលមានជាតិពន្ធុវៀតណាម[4] និង ជនភាគតិចចាមដែលមានលក្ខណៈជាជាតិពន្ធុ និងសាសនា ជាពិសេសនៅក្នុងភូមិភាគកណ្តាល និងបូព៌ា។

៨. ប.ក.ក បានអនុវត្តគោលនយោបាយមិនស្របច្បាប់របស់ខ្លួនតាមរយៈខ្សែបណ្តាញមន្ទីរសន្តិសុខនៅទូទាំងប្រទេស ដែលបានឃុំឃាំង ធ្វើបាប ធ្វើទារុណកម្ម និងសម្លាប់ខុសច្បាប់នូវ ប្រជាជនរបស់របបកម្ពុជាប្រជាធិបតេយ្យចំនួនយ៉ាងច្រើនសន្ធឹកសន្ធាប់។ ប.ក.ក បានធ្វើការបោសសម្អាតម្តងហើយម្តងទៀតដែលក្នុងនោះ កម្មាភិបាល និងអ្នកបម្រើការឱ្យប.ក.កផ្សេងទៀតត្រូវបានដកពីដំណែង និង សម្លាប់ ("កម្ទេច") ដោយសារមានការប្រឆាំងពិតប្រាកដ ឬត្រូវគេគិតថាប្រឆាំងនឹង ប.ក.ក។ កម្មាភិបាលដឹកនាំ អ្នកធ្វើការសន្តិសុខ និងប្រជាជនគ្រប់ថ្នាក់ទាំងអស់នៅក្នុងសង្គមទទួលបាននូវការណែនាំឱ្យការពារជាប្រចាំប្រឆាំងនឹងខ្មាំង "ស៊ីរូងផ្ទៃក្នុង" និង ឱ្យ "បន្តប្រយុទ្ធនិងបោសសម្អាត" សមាសភាពមិនល្អ។[5] (៥) ប្រជាជនចន្លោះពី១,៧ទៅ២,២លាន នាក់បានស្លាប់នៅក្នុងអំឡុងពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ដែលប.ក.ក គ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ។

៩. ប.ក.ក បានចាត់ទុកភូមិភាគនិរតីជាភូមិភាគគំរូសម្រាប់ការកែប្រែសង្គមកម្ពុជាឡើងវិញតាមខ្សែបន្ទាត់មនោគមន៍វិជ្ជា។ បន្ទាប់ពីនោះមក ក្នុងឆ្នាំ១៩៧៧ និង ១៩៧៨ នៅពេលដែលមានការសម្រេចថា ភូមិភាគកណ្តាល និង ភូមិភាគពាយ័ព្យ មិនបានសម្រេចតាមគោលបំណងប.ក.ក និងថា ថ្នាក់ដឹកនាំរបស់ភូមិភាគទាំងនេះមិនស្មោះត្រង់នឹងរបបខ្លួន កម្មាភិបាលប.ក.កពីភូមិភាគនិរតីក៏បានចូលកាន់កាប់ភូមិភាគទាំងនោះ តាមរយៈការបោសសម្អាតជាជាឈុតៗបន្តបន្ទាប់។

១០. នៅក្នុងដើមឆ្នាំ១៩៧៧ **តាអាន** បានដឹកនាំកម្មាភិបាលភូមិភាគនិរតីមួយក្រុមធ្វើការបោសសម្អាតនិងជំនួសស្ទើរតែអង្គការចាត់តាំងភូមិភាគកណ្តាលទាំងមូល តាំងពីថ្នាក់ឃុំដល់ថ្នាក់ភូមិភាគ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ភូមិភាគពាយ័ព្យទាំងមូលត្រូវបានបោសសម្អាត ដោយក្រុមកម្មាភិបាលភូមិភាគនីរតីមួយក្រុមទៀត ដែលដឹកនាំដោយ **តាម៉ុក** និង **អ៊ឹម ចែម**។

១១. បន្ទាប់ពីការមកដល់របស់កម្មាភិបាលភូមិភាគនីរតីក្នុងភូមិភាគកណ្តាល និង ពាយ័ព្យ ដំណាក់កាលដ៏ឃោរឃៅមួយបានកើតឡើងភ្លាម ដែលពេលនោះ ប្រជាជនត្រូវបានបង្ខំឱ្យធ្វើការងារយ៉ាប់យ៉ឺនជាងមុន អាហារទទួលទានបានតិចតួចជាងមុន ហើយមនុស្សរាប់ពាន់នាក់ត្រូវបានចាប់ និង សម្លាប់

ដែល រួមមានទាំងប្រជាជនថ្មី កម្មាភិបាលមូលដ្ឋាន ជនជាតិចាម ជនកម្ពុជាមានដើមកំណើតវៀតណាម និងអ្នកមកពីភូមិភាគបូព៌ា ដែលត្រូវបានបញ្ជូនទៅភូមិភាគកណ្តាល និង ពាយ័ព្យទាំងឡាន១ទៅសម្លាប់។ អាចមានការស្លាប់មនុស្សច្រើនរហូតដល់ក៏៤០០.០០០នាក់ នៅក្នុងភូមិភាគកណ្តាល[6] និង ៥៦០.០០០នៅក្នុងភូមិភាគពាយ័ព្យ[7](៧) នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។

## រចនាសម្ព័ន្ធ ភូមិភាគ តំបន់ និង ស្រុក របស់ ប.ក.ក

១២. គណៈភូមិភាគ តំបន់ និងស្រុក គឺជារចនាសម្ព័ន្ធគ្រប់គ្រងដ៏សំខាន់ ដែលបក្សកុម្មុយនីស្តកម្ពុជាបានគ្រប់គ្រងរបបកម្ពុជាប្រជាធិបតេយ្យ[8]។ បក្សកុម្មុយនីស្តកម្ពុជាត្រូវបានរៀបរចនាសម្ព័ន្ធតាមឋានានុក្រម ដែលនាំឱ្យគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានអនុវត្តន៍ដោយភូមិភាគ តំបន់ ស្រុក និងសាខា ទូទាំងទឹកដីទាំងមូលរបស់កម្ពុជាប្រជាធិបតេយ្យ[9]។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅតាមថ្នាក់នីមួយៗ មានការទទួលខុសត្រូវចំពោះការត្រួតពិនិត្យ ដឹកនាំ និងអនុវត្តន៍ផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[10]។ នៅខែមីនា ឆ្នាំ១៩៧៦ គណៈភូមិភាគត្រូវបានផ្តល់សិទ្ធិអំណាចយ៉ាងដាច់ខាតឱ្យធ្វើការ "កម្ទេចទាំងក្នុងជួរ និងក្រៅជួរ" នៅតាមមូលដ្ឋានរបស់ខ្លួន[11]។ លទ្ធផលនៃសិទ្ធិអំណាចនេះគឺថាមេដឹកនាំភូមិភាគមាន "ស្វ័យភាពដ៏ទូលំទូលាយក្នុងការសម្រេចចាប់ខ្លួន" និងមានសិទ្ធិអំណាចចេញពីមជ្ឈិមដែលអាច "សម្លាប់មនុស្សណាម្នាក់តាមដែលខ្លួនចង់" នៅក្នុងតំបន់របស់ខ្លួន ដើម្បីឈានទៅសម្រេចគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[12]។

១៣. ប្រទេសទាំងមូលត្រូវបានបែងចែកទៅជា "ភូមិភាគ" ចំនួន៦[13]។ បន្ទាប់មក ភូមិភាគ ត្រូវបែងចែកទៅជាអង្គភាពតូចបន្ទាប់ ដែលត្រូវបានស្គាល់ថាជា "តំបន់" ដែលបន្ទាប់មកត្រូវ បានបែងចែកទៅជា "ស្រុក" មួយចំនួន។ ស្រុកនីមួយៗរួមមាន"ឃុំ"មួយចំនួន ឬ "ឃុំ" ដែលមានភូមិរហូតដល់ទៅ២០។ រចនាសម្ព័ន្ធភូមិរបស់ប្រទេសកម្ពុជាជាប្រពៃណីត្រូវបានលប់បំបាត់ជាបន្តបន្ទាប់ ហើយប្រជាជនត្រូវបានបង្ខំឱ្យចូលធ្វើការក្នុងសមូហភាពកសិកម្ម ដែលហៅថា "សហករណ៍"[14]។ សាខាគឺជាបណ្តាញគ្រប់គ្រងថ្នាក់ទាបជាងគេបំផុតនៅក្នុងឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ជាក់ស្តែងសាខានេះមាននៅតាមឃុំ ភូមិ និង សហករណ៍ព្រមទាំងរោងចក្រ អង្គភាពយោធាថ្នាក់កងអនុសេនាធំ ការដ្ឋានធ្វើការ និងមន្ទីរនានារបស់ក្រសួង[15]។

១៤. ភូមិភាគ តំបន់ ស្រុក និងសាខា មានសារសំខាន់ក្នុងការអនុវត្តន៍សារាចរ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេស។ គណបក្សកុម្មុយនីស្តកម្ពុជាដែលមាន សមាជិក

បីនាក់ បានគ្រប់គ្រងថ្នាក់នីមួយៗតាមឋានានុក្រមចាត់តាំងនេះ ដោយមានលេខាម្នាក់ជាអ្នកធ្វើការបញ្ជាទូទៅ អនុលេខាទទួលខុសត្រូវខាងសន្តិសុខ និង សមាជិកទទួលខុសត្រូវខាងសេដ្ឋកិច្ច[16]។ គណៈភូមិភាគដឹកនាំបញ្ជាតាមភូមិភាគ និងមានភារកិច្ចត្រួតពិនិត្យ គ្រប់គ្រង និងធ្វើទស្សនកិច្ចតាមតំបន់ ស្រុក សាខា និង មន្ទីរនានា(មូលដ្ឋាន)ជាក់លាក់ណាមួយរបស់សាខា[17]។ គោលបំណង នៃការធ្វើទស្សនកិច្ចនេះគឺដើម្បីដឹកនាំឱ្យមានការអនុវត្តន៍ភារកិច្ច និងរាយការណ៍ត្រឡប់ទៅឱ្យខាងគណៈមជ្ឈិមវិញ ស្តីពីស្ថានភាព និងការងាររបស់ភូមិភាគ[18]។ គណៈនៅថ្នាក់ភូមិភាគ ស្រុក និងសាខាបំពេញតួនាទីស្រដៀងគ្នាក្នុងការអនុវត្តន៍គោលនយោបាយ និងកិច្ចការព្រមទាំងរាយការណ៍ស្តីពីសភាពការណ៍ និងការងាររបស់ផងខ្លួន[19] ។

១៥. ដោយមានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញ មន្ទីរ៨៧០ មាននាទីជាលេខាធិការដ្ឋានរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ហើយមាន “ភារកិច្ចត្រួតពិនិត្យមើលការអនុវត្តន៍”[20] ។ មន្ទីរ៨៧០ បានបញ្ជូនសារាចរអំពីគោលនយោបាយរបស់គណៈអចិន្ត្រៃយ៍ទៅឱ្យអង្គភាពតំបន់ របស់បក្សកុម្មុយនីស្តកម្ពុជា[21] ព្រមទាំងធ្វើឯកសារ និងបែងចែករបាយការណ៍ដែលទទួលបានមកពី ភូមិភាគ និងអង្គភាពរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ស្តីពីសភាពការណ៍ទូទៅ និងការ អនុវត្តន៍គោលនយោបាយគណៈអចិន្ត្រៃយ៍ទូទាំងកម្ពុជាប្រជាធិបតេយ្យ[22]។ មធ្យោបាយមួយចំនួនធំត្រូវបានប្រើប្រាស់ដើម្បីរក្សាទំនាក់ទំនងជាប្រចាំរវាងមជ្ឈិម និងអង្គភាព គ្រប់គ្រងតាមតំបន់ ដោយរួមមានការប្រើទូរស័ព្ទតាមូលដ្ឋាន សារទូរលេខ និរសារ និងបណ្តាញវិទ្យុទូទាំងប្រទេសដែល បង្កើតនៅក្នុងខែតុលា ឆ្នាំ១៩៧៥[23] ។

## ផែនការឧក្រិដ្ឋកម្មរួម

១៦. ផែនការឧក្រិដ្ឋកម្មរួម ឬសហកម្មឧក្រិដ្ឋកម្មរួម ចាប់ផ្តើមកើតមានយ៉ាងហោចណាស់ចាប់តាំងពីខែកុម្ភៈ ឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមាន **តាអាន**, សមាជិកគណៈភូមិភាគ និងតំបន់ របស់គាត់ ព្រមទាំងអ្នកក្រោមបង្គាប់ដែលមកជាមួយគាត់ពីភូមិភាគនិរតី។ កម្មវត្ថុរបស់សហកម្មឧក្រិដ្ឋកម្មរួមគឺត្រូវបោសសម្អាតនៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) និងសម្លាប់ រាល់ខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យនៅក្នុងភូមិភាគនោះ។ ទិសដៅជាក់លាក់របស់ សហកម្មឧក្រិដ្ឋកម្មរួមនេះគឺ កម្មាភិបាលមូលដ្ឋាន ក្រុមគ្រួសារ និង “ខ្សែបណ្តាញ” របស់ អ្នកទាំងនោះ ព្រមទាំងប្រជាជនដែលមានទំនាក់ទំនងជាមួយ “សង្គមចាស់,” ប្រជាជនថ្មី ឬប្រជាជន១៩៧៥, ជនជាតិភាគតិចចាម និងអ្នកកាន់សាសនា និងអ្នកមានជាតិពន្ធុវៀតណាម។ **តាអាន** បានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះដោយធ្វើជាសហចារី និងចង់បានលទ្ធផលបែបនេះ។

១៧. ផែនការឧក្រិដ្ឋកម្មរួមមួយទៀត ឬសហកម្មឧក្រិដ្ឋកម្មរួម បានកើតមានឡើងយ៉ាងហោចណាស់ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមាន តាម៉ុក, **តាទិត**, **អ៊ឹម ចែម** និងសមាជិកគណៈកម្មាធិការ ព្រមទាំងអ្នកក្រោមបង្គាប់ផ្ទាល់របស់គាត់ ដែលមកពីខាងភូមិភាគនិរតី។ កម្មវត្ថុរបស់សហកម្មឧក្រិដ្ឋកម្មរួមនេះ គឺត្រូវបោសសម្អាតនៅភូមិភាគពាយ័ព្យ និងសម្លាប់ខ្មាំងទាំងអស់របស់របបកម្ពុជាប្រជាធិបតេយ្យ។ ទិសដៅជាក់លាក់របស់សហកម្មឧក្រិដ្ឋកម្មរួម គឺកម្មាភិបាលមូលដ្ឋាន ក្រុមគ្រួសារ និង "ខ្សែបណ្តាញ" របស់អ្នកទាំងនោះ ព្រមទាំងប្រជាជនដែលមានទំនាក់ទំនងជាមួយនឹង "សង្គមចាស់," ប្រជាជនថ្មី ឬ "ប្រជាជន១៩៧៥" ជនជាតិភាគតិចចាម ដែលមានលក្ខណៈជាតិពន្ធុនិងសាសនា និងអ្នកដែលមានជាតិពន្ធុវៀតណាម។ **តាទិត** និង **អ៊ឹម ចែម** បានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះ ធ្វើជាសហចារី និងចង់បានលទ្ធផលបែបនេះ។

## បទឧក្រិដ្ឋកម្ម

## ភូមិភាគកណ្តាល

## ការបោសសម្អាតនៅភូមិភាគកណ្តាល

១៨. នៅដើមឆ្នាំ១៩៧៧ **តាអាន** បានដឹកនាំកម្មាភិបាលមួយក្រុមមកពីភូមិភាគនិរតីទៅកាន់ភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ហើយបានបោសសម្អាតកម្មាភិបាលភូមិភាគកណ្តាល នៅទីនោះសឹងទាំងអស់ ដោយចាប់ផ្តើមពីថ្នាក់ភូមិភាគ និងតំបន់ ហើយចុះរហូតដល់ថ្នាក់ឃុំ និងភូមិទៀតផង[24]។ នៅពេលដែលការបោសសម្អាតបានចប់សព្វគ្រប់ **តាអាន** បានក្លាយជាអនុលេខាភូមិភាគកណ្តាល និងលេខាតំបន់៤១ ព្រមទាំងថ្នាក់តំបន់ ស្រុក និងឃុំទាំងអស់ ដែលបណ្តាញគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានជំនួសដោយកម្មាភិបាលភូមិភាគនិរតី ដែល **តាអាន** បាននាំមកពីតំបន់នោះ ហើយដែលអ្នកទាំងនោះជាអ្នករាយការណ៍ឱ្យគាត់[25] ។

១៩. កម្មាភិបាលដែលត្រូវបានបោសសម្អាតនៅក្នុងភូមិភាគកណ្តាលត្រូវ "បាត់ខ្លួន" និងមិនដែលឃើញត្រឡប់មកវិញទេ ឬ ត្រូវបានចាប់ខ្លួន និងនាំយកទៅកាន់មន្ទីរស-២១ ឬគុកផ្សេងៗទៀត ដែលអ្នកទាំងក្រោយមកនោះត្រូវបានសម្លាប់ជាបន្តបន្ទាប់[26]។ កម្មាភិបាលដ៏គួរឱ្យកត់សម្គាល់ម្នាក់គត់ដែលរួចផុតពីការបោសសម្អាតនោះ គឺលេខាភូមិភាគកណ្តាលឈ្មោះ កែ ពក[27] ដែលមានការភ័យខ្លាចបាត់បង់ជីវិតខ្លួនគាត់[28] និងបានបន្ទោស "កម្មាភិបាលអាក្រក់មកពីភូមិភាគនិរតី" ចំពោះការបំពារបំពាននិងការសម្លាប់ដ៏សាហាវដែលកើតឡើងនៅទូទាំងភូមិភាគកណ្តាលនៅក្នុងឆ្នាំ១៩៧៧និង១៩៧៨[29] ។

២០. ការបោសសម្អាតនៅភូមិភាគកណ្តាលត្រូវបានធ្វើឡើងដោយមានការចាត់តាំង និងមានលក្ខណៈជាប្រព័ន្ធដោយចាប់ផ្តើមពីកម្មាភិបាលថ្នាក់ខ្ពស់រហូតដល់ថ្នាក់ក្រោម[30] ។ ដូចដែលមាននៅក្នុងកំណត់បញ្ជីស-២១ មួយច្បាប់ស្រាប់ នៅថ្ងៃទី១៨ និង១៩ ខែកុម្ភៈ ឆ្នាំ១៩៧៧ មេដឹកនាំជាន់ខ្ពស់របស់ភូមិភាគកណ្តាល ដូចខាងក្រោមនេះ ត្រូវបាននាំយកមកកាន់មន្ទីរស-២១៖ ឈ ឆេន ហៅ ស្រេង ដែលជាអនុលេខាភូមិភាគកណ្តាល, ជុន ឈុំ ហៅ តាំង ដែលជា លេខាតំបន់៤១, ចាន់ មុល ហៅ តុល ដែលជាលេខាតំបន់៤២ និងសមាជិកគណៈភូមិភាគកណ្តាល និងប្រធានពាណិជ្ជកម្មភូមិភាគ និង គណៈកសិកម្ម មន្ទីរពេទ្យ និង គណៈសាធារណការ[31] ។ ពីរ-បីសប្តាហ៍ក្រោយមកទៀត សមាជិកភូមិភាគ និង គណៈតំបន់ដែលនៅសេសសល់ និងសមាជិកគណៈស្រុក ព្រៃឈរ កងមាស កំពង់សៀម និងជើងព្រៃ (ដែលស្រុកទាំងអស់នេះជាផ្នែករបស់តំបន់៤១) ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់ស-២១[32] ។

២១. ក្រុមគ្រួសារកម្មាភិបាលដែលត្រូវបានបោសសម្អាត ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលជាញឹកញាប់ដែរ[33] ។ នៅក្នុងករណី ស្រេង អនុលេខាភូមិភាគកណ្តាល និងអតីតលេខា តំបន់៤១ កម្មាភិបាលភូមិភាគនិរតីក៏បានចាប់ខ្លួន និងសម្លាប់ឪពុកម្តាយ[34], បងប្អូនប្រុស[35], និង បងប្អូនស្រី, ប្តី និងកូន៧នាក់ក្នុងចំណោមកូនទាំង៨នាក់របស់គាត់ទៀតផង[36]។ ការបោសសម្អាត បានបន្តយ៉ាង ហោចណាស់ក៏រហូតដល់ចុងឆ្នាំ១៩៧៧[37] ដោយរាលដាលរហូតដល់ប្រធានភូមិ[38] ។ សាក្សីទាំងឡាយ បង្ហាញថាការចាប់ខ្លួនត្រូវបានធ្វើឡើងដោយកម្មាភិបាលភូមិភាគនិរតី ដែលមកកាន់ភូមិភាគកណ្តាលជាមួយ **តាអាន**[39] និងថា កម្មាភិបាលមូលដ្ឋានដែលត្រូវបោសសម្អាតត្រូវបានជំនួសដោយកម្មាភិបាល ភូមិភាគនិរតីនៃក្រុមរបស់ **តាអាន**[40] ។

២២. បន្ថែមលើការកម្ចាត់ចោលកម្មាភិបាលនៅទីនោះគឺថា បន្ទាប់ពីការមកដល់របស់ **តាអាន** និង កម្មាភិបាលភូមិភាគនិរតីនៅក្នុងភូមិភាគកណ្តាល មានការកើនឡើងចំនួននៃការចាប់ខ្លួន ការសម្លាប់ និង ការបាត់ខ្លួន ហើយមានសភាពធ្ងន់ធ្ងរទៅនៃស្ថានភាពរស់នៅជាទូទៅក្នុងចំណោមប្រជាជន។ របៀបរបបច្បាស់លាស់មួយបានកើតមានឡើងទូទាំងភូមិភាគកណ្តាលបន្ទាប់ពី **តាអាន** និង កម្មាភិបាលភូមិភាគនិរតីបានមកដល់មានការតម្រូវឱ្យធ្វើការងារកាន់តែច្រើនឡើងៗ មានការផ្តល់អាហារកាន់តែតិចជាងមុន ហើយប្រជាជនជាច្រើនត្រូវបានចាប់ខ្លួន និងមិនដែលឃើញ ត្រឡប់មកវិញឡើយ[41] ដោយរាប់ទាំងប្រជាជនថ្មី ឬ ប្រជាជន១៩៧៥[42], ប្រជាជនដែលមាន “ជាប់ពាក់ព័ន្ធជាមួយសង្គមចាស់”[43] និងជនជាតិចាម[44] ។ ជាទូទៅ ប្រជាជនដែលបាន “បាត់ខ្លួន” ត្រូវបានយកចេញនៅពេលយប់តាមរទេះសេះ[45]។ មន្ទីរសន្តិសុខ, គុក[46] និងទីតាំងសម្លាប់ ដូចមានរៀបរាប់នៅខាងក្រោម

គឺជាទីតាំងឧក្រិដ្ឋកម្ម ដែលប្រជាជនទាំងអស់នេះ ត្រូវបានឃុំខ្លួន និងសម្លាប់ចោលក្នុងអំឡុងពេលដែល **តាអាន** និងកម្មាភិបាលភូមិភាគនិរតី ចាប់ផ្តើមគ្រប់គ្រងនៅ ភូមិភាគកណ្តាល។

**ខេត្តកំពង់ចាម**

**មន្ទីរសន្តិសុខវត្តអូរត្រកួន**

២៣. វត្តអូរត្រកួនស្ថិតនៅស្រុកពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម (ជាផ្នែកមួយនៃតំបន់៤១ និងភូមិភាគកណ្តាល) ហើយត្រូវបាន ប.ក.ក. ប្រើប្រាស់ជាគុកប្រចាំស្រុកកងមាសចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៦[47] ។ អ្នករដ្ឋការស្រុកបានប្រមែប្រមូល និងរាប់សាកសពបន្សល់ទុកពី របបកម្ពុជាប្រជាធិបតេយ្យបានធ្វើការប៉ាន់ស្មានថាមនុស្សច្រើនរហូតដល់ ៣២.៦៩០ នាក់ ត្រូវបានយកទៅសម្លាប់នៅវត្តអូរត្រកួន[48] ។ សាកសពទាំងនោះត្រូវបានរកឃើញនៅឆ្នាំ ១៩៧៩ ក្នុងរណ្តៅសាកសពជាច្រើនគ្របដណ្តប់លើផ្ទៃដីជិត១ហិចតា។ រណ្តៅទាំងនោះមានរណ្តៅធំៗយ៉ាងតិចចំនួន ២០០ (បណ្តោយ ៥ម៉ែត្រ ទទឹង ៤ម៉ែត្រ និងជម្រៅ ២ ម៉ែត្រ) និងមានជាង ១.០០០ រណ្តៅតូចៗ[49] ។ ការសម្លាប់មនុស្សខ្លាំងក្លាបំផុតគឺបន្ទាប់ពីកម្មាភិបាលភូមិភាគនិរតី ចូលមកដល់ក្នុងឆ្នាំ១៩៧៧[50] ។ នៅពេលនោះ ជនរងគ្រោះនៅ វត្តអូរត្រកួនមាន២ក្រុមធំៗគឺ ៖ "ប្រជាជនថ្មី"[51] និង ជនជាតិចាម[52]។ (ការសម្លាប់ជនជាតិចាមជាក្រុមនៅ វត្តអូរត្រកួននេះត្រូវបានលើកមកពិភាក្សានៅ ត្រង់កថាខណ្ឌ ៤០-៤៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ)។

២៤. ក្នុងអំឡុងពេលដែលកម្មាភិបាលភូមិភាគនិរតីនៅកាន់កាប់មន្ទីរសន្តិសុខនេះ ប្រធានគុកអូរត្រកួនមានឈ្មោះ ថា ហាន ។ គាត់ក៏ជាប្រធានសន្តិសុខទូទាំងស្រុកទាំងមូល[53] ។ ហាន រាយការណ៍ទៅអោយគណ:ស្រុក ឈ្មោះ កាន ដែលជាអ្នករាយការណ៍បន្តឱ្យទៅគណៈតំបន់ **តាអាន**[54] ។ កាន និង ហាន ទាំងពីរនាក់ ជាកម្មាភិបាលភូមិភាគនិរតីដែលចូលមកកាន់តំបន់៤១ជាមួយ **តាអាន** នៅដើមឆ្នាំ ១៩៧៧ [55]។

២៥. អ្នកទោសជាប់ឃុំនៅវត្តនេះទទួលរងនូវស្ថានភាពគ្មានមនុស្សធម៌ មុនពេលអ្នកទោសទាំងនោះត្រូវយកចេញទៅសម្លាប់នៅចម្ការក្បែរនោះ។ នៅក្នុងវត្តមានអ្នកទោសជាច្រើនដេកតម្រៀបគ្នាជាជួរដោយមានជាប់ខ្នោះជើងភ្ជាប់ទៅនឹងរនុកដែកដ៏វែងមួយលាតសន្ធឹងពេញផ្ទៃដីវត្ត ប្រវែងជាង ២០ ម៉ែត្រ[56] ។ អាហារសម្រាប់អ្នកទោសគឺមានតែត្រកួនចិញ្ច្រាំលាយជាមួយគ្រាប់ពោត៨គ្រាប់[57] ។ អ្នកទោសទាំងនោះមានរូបរាង "ស្គមស្គាំង" "និយាយខ្សាវៗ និង មានមុខមាត់ស្លេកស្លាំងដូចខ្មោច"[58]។ អ្នកទោសដែលជាប់ឃុំឃាំងហើយមិនងាយនឹងទទួលការដោះលែងឡើយ[59] ។ អ្នកទោសម្នាក់ដែលរួចជីវិតត្រូវឆ្មាំគុកនិយាយប្រាប់ថា ខ្លួនពិតជា "មានសំណាង" ហើយព្រោះ "ការដោះលែង

អ្នកទោសគឺជាករណីដ៏កម្រមួយ"[60] ។ គាត់ទទួលរងការទាត់ធាក់ពីពួកឈ្លបក្មេងៗដែលជាអ្នកចាប់មនុស្ស និង វាយដំនឹងដំបងទាល់តែដួលពោបនឹងដី[61] ។ ពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩ ប្រជាជននៅទីនោះបានចូលទៅក្នុងវត្ត ហើយឃើញស្លាកស្នាមឈាមដាមជាប់ទីនោះ[62] ។

## មន្ទីរសន្តិសុខវត្តបាធាយ

២៦. វត្តបាធាយស្ថិតនៅក្នុងភូមិបាធាយ ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម (ជាទឹកដីតំបន់៤១ និងភូមិភាគកណ្តាល)។ តាមការប៉ាន់ស្មានថាមានមនុស្សពី ៨.០០០ ទៅ ១០.០០០ នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខនេះ[63] ។ ការសម្លាប់ និងការបាត់ខ្លួនកើនឡើងយ៉ាងខ្លាំង ខណៈ ដែលកម្មាភិបាលភូមិភាគនិរតីចូលមកដល់នៅដើមឆ្នាំ១៩៧៧ ដែលជាករណីកើតមានឡើងទូទាំង ភូមិភាគកណ្តាលតែម្តង[64] ។ នៅឆ្នាំ១៩៧៨ មនុស្សដែលគេយកទៅសម្លាប់ជាច្រើន ជាប្រជាជនមកពីភូមិភាគបូព៌ាដឹកតាមរថយន្តមកមន្ទីរសន្តិសុខនេះ[65] ហើយការសម្លាប់នេះគឺជាផ្នែកមួយនៃការបោសសម្អាតភូមិភាគនោះ[66] ។ អ្នករួចជីវិតម្នាក់បានសង្កេតកំណត់ត្រាមួយក្នុងដៃសន្តិសុខគុកដែលសរសេរថា "បាន សម្លាប់ ៦.០០០ នាក់នៃប្រជាជន បូព៌ាក្នុងក្រុមបូព៌ា"[67] ។ នៅទីនោះមានរណ្តៅសាកសពចំនួនពី ៤០០ ទៅ ៥០០ កន្លែង[68] ។ ចេតិយសម្រាប់រំលឹកវិញ្ញាណក្ខន្ធមួយត្រូវបានកសាងឡើងដើម្បីតម្កល់ធាតុអ្នកស្លាប់ទាំងឡាយនោះ[69] ។

២៧. អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខត្រូវទទួលរងនូវទារុណកម្ម វាយដំនឹងដំបង ធ្វើឱ្យអ្នកទាំងនោះស្រែកថ្ងូរទាំងការឈឺចាប់[70] ។ អ្នកទោសទទួលបានរបបអាហារតែមួយពេលគត់ក្នុងមួយថ្ងៃ គឺបបរមួយវែកប៉ុណ្ណោះ ហើយអ្នកទោសខ្លះស្លាប់ដោយការស្រេកឃ្លាន និងជំងឺផ្សេងៗ[71] ។ ប្រធានគុកគឺសមមិត្តឃីម រីឯគណៈស្រុកឈ្មោះ ភឹម [72]។ គណៈស្រុក ភឹម មកពីភូមិភាគនិរតី នៅឆ្នាំ១៩៧៧[73] ។ អ្នកទោសរួចជីវិត និងកម្មាភិបាលសន្តិសុខមួយចំនួនត្រូវបានរកឃើញអត្តសញ្ញាណ[74] ។

## មន្ទីរសន្តិសុខមិត្តសុប (គរ)

២៨. មន្ទីរសន្តិសុខមិត្តសុបជាមន្ទីរសន្តិសុខថ្នាក់តំបន់សម្រាប់តំបន់ ៤១ និងស្ថិតក្នុងវាលស្រែក្រៅភូមិក្រូច ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម[75] ។ មានអ្នកទោសសរុបចំនួនជាង ២.៣០០នាក់ត្រូវបានជ្រើថាយកមកសម្លាប់នៅមន្ទីរសន្តិសុខនេះ រួចយកទៅកប់នៅវាលពិឃាតបួនកន្លែងក្បែរនោះ[76] ។ មន្ទីរសន្តិសុខនេះដាក់ឈ្មោះតាម មិត្តសុប ជាអតីតប្រធានគុកដែលត្រូវបានបោសសម្អាត និងជំនួសតំណែងដោយកម្មាភិបាលភូមិភាគនិរតីឈ្មោះ តាង៉ូវ ក្នុងឆ្នាំ ១៩៧៧[77] ។ ពេលដែល

កម្មាភិបាលភូមិភាគនិរតីចូលមកដល់ស្រុកព្រៃឈរ កម្មាភិបាលប្រចាំស្រុកព្រៃឈរត្រូវសម្លាប់ និងដាក់ជំនួសដំណែងរហូតដល់ថ្នាក់ឃុំ[78] ។ ពេលនោះហើយ ដែលការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខកាន់តែកើនឡើង ហើយករណីស្លាប់ដោយអត់អាហារក៏ច្រើនជាងមុនទៅទៀត[79] ។

២៩. ពេល មិត្តសុប នៅកាន់កាប់មន្ទីរសន្តិសុខនេះ អ្នកទោសប្រមាណ៣០ភាគរយ ត្រូវបានដោះលែង ប៉ុន្តែតាំងពី តាង៉ូវ ចូលមកកាន់ជំនួសនៅឆ្នាំ១៩៧៧ ស្ទើរតែគ្មានអ្នកទោសណាម្នាក់ឡើយដែលត្រូវបានដោះលែង[80] ។ អ្នកទោសដែលនៅសេសសល់ទាំងប៉ុន្មានត្រូវបានយកទៅសម្លាប់ទាំងអស់មុនពេលវៀតណាមចូលក្នុងឆ្នាំ១៩៧៩[81] ។ ក្នុងតំណែងជាប្រធានមន្ទីរសន្តិសុខតំបន់៤១ តាង៉ូវត្រូវបានជឿថាជាអ្នករាយការណ៍ទៅលេខាតំបន់៤១ ឈ្មោះ **តាអាន** ដែលតាំងទីស្នាក់ការស្ថិតនៅប្រមាណមិនដល់ ១០ គីឡូម៉ែត្រ ពីភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ[82] ។

## មន្ទីរសន្តិសុខវត្តភ្នំប្រុស

៣០. មន្ទីរសន្តិសុខវត្តភ្នំប្រុសមានទីតាំងស្ថិតនៅលើភ្នំមួយ ក្នុងចំណោមភ្នំពីរខាងលិចទីរួមខេត្តកំពង់ចាម ។ មន្ទីរសន្តិសុខនេះស្ថិតនៅឃុំក្រឡា និង ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម (ទឹកដីតំបន់៤១និងភូមិភាគកណ្តាល)។ មន្ទីរសន្តិសុខនេះគឺជា "កន្លែងសម្លាប់រង្គាលដ៏ឃោរឃៅ មួយក្នុងចំណោមមន្ទីរសន្តិសុខដទៃទៀតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[83] ។ វត្តដែលនៅលើកំពូលភ្នំប្រុសត្រូវប្រែក្លាយជាគុក ហើយជនរងគ្រោះត្រូវយកទៅសម្លាប់នៅវាលទំនាបចន្លោះភ្នំទាំងពីរ[84] ។ តាមការប៉ាន់ស្មានគឺមានមនុស្ស១០.០០០នាក់ ត្រូវបានសម្លាប់នៅទីនេះ[85] ។ នៅរវាងឆ្នាំ១៩៧៧ និង ១៩៧៨ គឺជារយៈពេលមានការសម្លាប់ធ្ងន់ធ្ងរបំផុតបន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីចូលមកដល់[86] ។ សាក្សី សង្កេតឃើញអ្នកទោសត្រូវបានគេដឹកតាមឡានយកទៅមន្ទីរសន្តិសុខដែលជួនកាលដឹកម្តង៥ឡាន[87] ។

៣១. ពេលនោះគណៈស្រុកកំពង់សៀមឈ្មោះ យាយយុទ្ធ ភេទស្រី ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយ **តាអាន**។ យាយយុទ្ធ បានធ្វើដំណើរជាមួយ **តាអាន** ទៅភូមិភាគកណ្តាលនៅដើមឆ្នាំ១៩៧៧[88] ។ ប្រជាជនយកទៅសម្លាប់នៅភ្នំប្រុសរួមមានប្រជាជន "ពាន់ព័ន្ធនឹងសង្គមចាស់" និងអ្នកដែលជាប់ខ្សែកម្មាភិបាលដែលជាប់សង្ស័យ[89] ។ លលាដ៍ខ្មោច និងឆ្អឹងប្រមូលមកពីវាលពិឃាតនៅមន្ទីរសន្តិសុខវត្តភ្នំប្រុស ត្រូវបានយកទៅតម្កល់នៅវត្តនគរ[90] ។

## មន្ទីរសន្តិសុខគោកព្រីង

៣២. មន្ទីរសន្តិសុខគោកព្រីងស្ថិតនៅជាប់ច្រាំងនៃបឹងធំ ក្បែរភូមិក្តីបឹង ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម (ទឹកដីតំបន់៤១ នៃភូមិភាគកណ្តាល)[91] ។ តាមការប៉ាន់ស្មានគឺមានមនុស្ស ១.០០០ នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខគោកព្រីងទីនេះ[92] ។ នៅឆ្នាំ ១៩៧៧ បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីចូលមកដល់ក៏មាន"ការបោសសម្អាតដ៏ធំ" ទៅលើកម្មាភិបាលប្រចាំតំបន់ ការបាត់ខ្លួនក៏ចាប់ផ្តើមឡើង ហើយលក្ខខណ្ឌការងារកាន់តែធ្ងន់ធ្ងរទៅៗ ហើយប្រជាជន "ទទួលបញ្ជាឱ្យរកមើលអ្នកដទៃដែលមាននិន្នាការមិនល្អ"[93] ។ ជារៀងរាល់យប់មានមនុស្សពី ២០ ទៅ ៥០ នាក់ត្រូវគេ "បណ្តើរកាត់" ភូមិបឹងក្តីយកទៅវាលពិឃាតក្បែរបឹង[94] ។ ប្រជាជនដែលគេបណ្តើរនៅតាមផ្លូវទៅកន្លែងសម្លាប់ "មានសភាពទន់ខ្សោយដើរស្ទើរតែពុំរួច ហើយត្រូវខ្មែរក្រហម វាយដំតាមផ្លូវ"[95]។ ប្រជាជនដែលគេយកទៅសម្លាប់ភាគច្រើនជា"ប្រជាជនប្រភេទ១៩៧៥"[96] ។ អ្នកទាំងនោះមិនដែលឃើញត្រឡប់មកវិញឡើយ[97] ។

៣៣. ឈ្លបដែលយកប្រជាជនទៅគោកព្រីងត្រូវបានជ្រើសរើសដោយគណៈឃុំវិហារធំ និង ធ្វើការឱ្យគណៈឃុំនេះ ដែលជាកម្មាភិបាលភូមិភាគនិរតីឈ្មោះ តាជា។ តាជាមកតំបន់នេះជាមួយគណៈស្រុកឈ្មោះ យាយយុទ្ធ[98] ។ តាជាបានរាយការណ៍ទៅយាយយុទ្ធ ហើយយាយយុទ្ធជាអ្នករាយការណ៍បន្តទៅគណៈតំបន់ ឈ្មោះ **តាអាន**[99] ។ ឈ្លបនៅឃុំរបស់ តាជា ជារឿយៗតែងតែនិយាយគ្នាពីចំនួនមនុស្សដែលគេសម្លាប់ និង ជប់លៀងពេលខ្លួនរកឃើញរបស់មានតម្លៃនៅជាប់នឹងជនរងគ្រោះ[100] ។ នៅចុងឆ្នាំ១៩៧៨ អនុ យាយយុទ្ធ បានទៅកន្លែង តាជា ហើយ"ប្រាប់ តាជា ឱ្យទុកតែ៣០គ្រួសារប៉ុណ្ណោះក្នុង១ភូមិ"[101]។ របបកម្ពុជាប្រជាធិបតេយ្យដួលរលំមុនពេលអនុវត្តគម្រោងការសម្លាប់មនុស្សទាំងអស់ដោយទុកតែ ៣០ គ្រួសារក្នុងភូមិនីមួយៗ[102] ។

## មន្ទីរសន្តិសុខចំការស្វាយចន្ទី

៣៤. មន្ទីរសន្តិសុខចំការស្វាយចន្ទីស្ថិតនៅចំការក្នុងភូមិ វារីលិច ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម (ទឹកដីតំបន់ ៤២ នៃភូមិភាគកណ្តាល)[103] ។ តាមការប៉ាន់ស្មានប្រជាជន ប្រមានពី ៥០០០ ទៅ ៧០០០នាក់ ត្រូវបានយកមកសម្លាប់ទីនេះ[104] ។ អំឡុងពេលសម្លាប់ខ្លាំងបំផុតគឺចាប់ផ្តើមពីពាក់កណ្តាលឆ្នាំ ១៩៧៨ រហូតដល់ខែមករា ឆ្នាំ១៩៧៩[105] ។ ជនកម្ពុជាមានសែស្រឡាយវៀតណាម និង អ្នកដែលរៀបការជាមួយប្រជាជនទាំងនោះ គឺជាមុខសញ្ញាពិសេស[106] ។ នៅខែកក្កដា ឆ្នាំ១៩៧៨ នៅចំការនោះ មានការសម្លាប់មនុស្សជាក្រុម ក្នុងនោះមានស្ត្រី និង

កុមារផងដែរ[107] ។ មិនយូរប៉ុន្មានផង លេខាភូមិភាគកណ្ដាល កែ ពក បានមកមើលទីតាំងនោះ ហើយបានចាប់ខ្លួន និងសម្លាប់គណៈឃុំ។ កែពក បានឱ្យសន្តិសុខស្រុក "ស្រង់ឈ្មោះប្រជាជនរៀនសូត្រចេះដឹងដើម្បីយកទៅសម្លាប់" [108]។

## ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ

៣៥. ទំនប់អន្លង់ជ្រៃ (ឬហៅម្យ៉ាងទៀតថាទំនប់ទួលកុកឃូរ) ស្ថិតនៅក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម (តំបន់ ៤១ នៃភូមិភាគកណ្ដាល)[109] ។ ទំនប់នេះមានកំពស់ ៥០ ម៉ែត្រ ហើយមានប្រវែង "វែងណាស់" ហើយត្រូវបានសាងសង់នៅរវាងខែមករា និងខែមិថុនា ឆ្នាំ១៩៧៨[110] ។ ទំនប់នេះត្រូវបានសាងសង់ឡើងស្របតាមគោលនយោបាយរបស់ ប.ក.ក. ដែលទាមទារឱ្យមានការសាងសង់ប្រព័ន្ធទំនប់ទឹក និងប្រឡាយដើម្បីបង្កើនផលិតផលកសិកម្មទូទាំងប្រទេស[111] ។ កម្មករចំនួនមួយម៉ឺននាក់ មកពី ស្រុកព្រៃឈរ ស្រុកកំពង់សៀម ស្រុកកងមាស និង ស្រុកបាធាយ នៃតំបន់៤១។ អ្នកទាំងនោះត្រូវបានបង្ខំឱ្យធ្វើការសាងសង់ទំនប់[112] ។ កម្មករទាំងនោះចាប់ផ្ដើមធ្វើការជារៀងរាល់ថ្ងៃតាំងពីម៉ោង ៤ទៀបភ្លឺ[113] ។ កម្មករទំនប់មានរូបរាងស្គមស្គាំង ហើយធ្លាក់ខ្លួនឈឺ ដោយសារមិនបានទទួលរបបអាហារគ្រប់គ្រាន់[114] ។ មិនត្រឹមតែប៉ុណ្ណោះកម្មករទំនប់ទទួលរងទុក្ខវេទនាដោយមិនបានទទួលការថែរក្សាព្យាបាលត្រឹមត្រូវ[115] ។ អ្នកណាដែលបដិសេធមិនទៅធ្វើការនៅទំនប់នឹងត្រូវយកទៅសម្លាប់ចោល [116]។

៣៦. អន្លង់ជ្រៃជាទំនប់ថ្នាក់តំបន់ និងទទួលការមកចុះធ្វើទស្សនកិច្ចពីរខែម្ដងពីសំណាក់លេខាតំបន់ ៤១ ឈ្មោះ **តាអាន**[117] ។ ពេលចុះទស្សនកិច្ច **តាអាន** ធ្វើសុន្ទរកថាឱ្យកម្មករស្ដាប់ ដែលពេលនោះ **តាអាន** ប្រាប់ ឱ្យកម្មករខិតខំធ្វើការ និងនិយាយអំពី "មហាលោតផ្លោះមហាអស្ចារ្យ និងសម្រេចឱ្យបានផលស្រូវ ៣ តោន ក្នុងមួយហិកតា"។[118]

## ការប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម

៣៧. ជនជាតិចាមគឺជាជនជាតិភាគតិចដោយឡែក ហើយស្ថិតនៅក្នុងក្រុមជាតិពន្ធ និង ក្រុមសាសនាផ្សេង។ ជនជាតិចាមកាន់សាសនាឥស្លាម និងជាកូនចៅជំនាន់ក្រោយរបស់អាណាចក្រចម្ប៉ា ដែលតាំងទីលំនៅតាមបណ្ដោយដងទន្លេមេគង្គនៃប្រទេសកម្ពុជា[119] ។ ជនជាតិចាមមានភាសារបស់ខ្លួន ហើយរស់នៅ ក្នុងភូមិដោយឡែករបស់ខ្លួន ដោយប្រតិបត្តិជំនឿ និងការស្លៀកពាក់តាមប្រពៃណី

របស់ផងខ្លួន[120] ។ ការរស់នៅផ្តុំគ្នាច្រើនបំផុតរបស់ជនជាតិចាមនៅប្រទេសកម្ពុជា គឺស្ថិតក្នុងខេត្តកំពង់ចាម[121] ។

៣៨. ចាប់តាំងពីការចាប់ផ្តើមនៃរបបកម្ពុជាប្រជាធិបតេយ្យ ជនជាតិចាមនៅប្រទេសកម្ពុជាទទួលរងនូវការធ្វើទុកបុកម្នេញ និងជាមុខសញ្ញារបស់ ប.ក.ក.[122] ។ នៅចុងឆ្នាំ១៩៧៥ ប.ក.ក. ចាប់ផ្តើមជម្លៀសជនជាតិចាមទាំងបង្ខំឱ្យចេញពីភូមិស្រុក និងរាយបណ្តាក់ជនជាតិចាមនៅតាមភូមិនានាដែលមានសុទ្ធតែជនជាតិខ្មែររស់នៅ[123] ។ ជនជាតិចាមរាប់ម៉ឺននាក់ ត្រូវបានជម្លៀសទាំងបង្ខំឱ្យទៅភូមិភាគឧត្តរ និង ពាយ័ព្យ[124] ជាផ្នែកមួយនៃគោលនយោបាយ ប.ក.ក. ដែលរៀបចំឡើងដើម្បី "បំបែក(ជនជាតិចាម)"[125] ។ បុរសជនជាតិចាមត្រូវបំបែកចេញពីស្ត្រីជនជាតិចាម និងកូនរបស់ខ្លួន ហើយបញ្ជូនទៅកន្លែងផ្សេងៗគ្នាឱ្យធ្វើការក្នុងកងចល័ត[126] ។ ហេតុការណ៍ដូចនេះកើតឡើងជាច្រើនកន្លែង ដូចជានៅស្រុកកងមាស ស្រុកក្រូចឆ្មារ និងស្រុកកោះសុទិន ខេត្តកំពង់ចាម[127] ។

៣៩. រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យហាមឃាត់សាសនា "ប្រតិកិរិយា" ដែលយកមកប្រតិបត្តិដោយ ប.ក.ក. រួមមានការហាមឃាត់ចំពោះសាសនាឥស្លាមផងដែរ[128] ។ ជនជាតិចាមត្រូវបានហាមឃាត់មិនឱ្យចូលរួមក្នុងកិច្ចការសាសនាឥស្លាម (vachip) ដូចជាការបួងសួង (sambahyang) ការតមអាហារ ធ្វើទេយ្យទាន ឬ ប្រារព្ធពីធីបុណ្យសាសនា បុណ្យសពអ្វីឡើយ[129] ។ ជនជាតិចាមត្រូវបានហាមឃាត់មិនឱ្យមានគម្ពីរសាសនា[130] ដែលកម្មាភិបាលខ្មែរក្រហមបានប្រមូលយកទៅដុតចោលអស់[131] ។ ប.ក.ក. ដៅមុខសញ្ញាយកទៅសម្លាប់ចំពោះមេដឹកនាំសាសនានិងនយោបាយជនជាតិចាម និងជនជាតិចាមណាម្នាក់ដែលមិនព្រមផ្តាច់ខ្លួនចេញពីសាសនា[132] ។ ភាសាចាមត្រូវបានហាមឃាត់មិនឱ្យនិយាយ[133] សូម្បីតែគ្រឿងប្រដាប់តែងកាយប្រពៃណីចាម (សារ៉ុង fez and makhna ក្រណាត់រុំវែងសម្រាប់ស្ត្រីពេលចូលបួងសួង[134] និងការប្រើប្រាស់ឈ្មោះមានលក្ខណៈចាមក៏មិនអនុញ្ញាតដែរ[135] ។ ជនជាតិចាមត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើដែលជំនឿរបស់ខ្លួនហាមឃាត់យ៉ាងតឹងរឹង (haram) ដូចជាការ ហូបសាច់ជ្រូកជាដើម[136] ហើយស្ត្រីចាមត្រូវបង្ខំឱ្យកាត់សក់ខ្លី[137] និងមិនអនុញ្ញាតឱ្យគ្របក្បាលឡើយ[138] ។ បើមិនគោរពតាមវិន័យនេះទេជនជាតិចាមនឹងត្រូវយកទៅសម្លាប់ចោល[139] ។ ក្នុងអំឡុងពេលនោះវិហារសាសនាឥស្លាមជាច្រើនត្រូវបានធ្វើឱ្យខូច ឬបំផ្លាញចោលតែម្តង[140] ។

៤០. នៅពាក់កណ្តាលឆ្នាំ ១៩៧៧ ការធ្វើទុកបុកម្នេញជាទូទៅមួយរបស់ ប.ក.ក. មកលើជនជាតិចាមនៅខេត្តកំពង់ចាម ក្លាយទៅជាការប្រល័យពូជសាសន៍ ដោយអ្នកភូមិចាមទាំងមូលត្រូវប្រមូលយកទៅមន្ទីរសន្តិសុខដើម្បីសម្លាប់ក្នុងកិច្ចខិតខំរួមមួយដើម្បីលុបបំបាត់ជនជាតិចាមឱ្យអស់ពីទីនោះ។

៤១. នៅល្ងាចមួយក្នុងខែសីហា ឆ្នាំ១៩៧៧ កងកម្លាំងសន្តិសុខនៅឃុំពាមជីកង ស្រុកកងមាស (ផ្នែកមួយនៃតំបន់៤១) បានចាប់ខ្លួនជនជាតិចាមគ្រប់រូបតាមភូមិនីមួយៗ និង នាំជនជាតិចាមទាំងនោះទៅវត្តអូរត្រកួន ដែលជាគុកថ្នាក់ស្រុក[141] ។ ជនជាតិចាមចំនួន ៣០០ នាក់ត្រូវចាប់ខ្លួនក្នុងយប់ដដែលនោះ[142] ។ គេឃើញពេជ្ឈឃាដប្រចាំនៅគុក កំពុងសម្លាប់ អ្នកទោសជនជាតិចាម ហើយការសម្លាប់នេះធ្វើនៅចម្ការក្បែរគុក និង បន្តរហូតដល់ម៉ោង១ព្រឹកទើបឈប់[143] ។ កុមារនៅក្នុងចំណោមអ្នកទោសត្រូវបានសម្លាប់ដោយបោកផ្ទប់នឹងដើមឈើ[144] ។ មិនត្រឹមតែប៉ុណ្ណោះ ពេជ្ឈឃាដមាន "ការប្រលងប្រណាំគ្នាមើលតើអ្នកណាអាចសម្លាប់មនុស្សលឿនជាងគេ" ដែលក្នុងនោះមានម្នាក់អាចសម្លាប់បានដល់ទៅ៩០នាក់ ក្នុងរយៈពេល១ម៉ោង[145] ។ ប្រធានសន្តិសុខឃុំ ប្រាប់មនុស្សដែលខ្លួនចាត់តាំងឱ្យចាប់ជនជាតិចាមថា "ប្រជាជនចាមជាពូជសាសន៍ផ្សេងពីយើង ហើយត្រូវតែកម្ទេចពួកវាចោល"ហើយថា"ប្រសិនបើយើងទុកប្រជាជនចាមទាំងនោះ ពួកវានឹងបះបោរប្រឆាំងនឹងយើងនៅពេលណាមួយជាពុំខាន"[146]។

៤២. ក្នុងអំឡុងពេលដូចគ្នាដែរ ប្រជាជនឥស្លាមដែលនៅសល់ពីភូមិមួយផ្សេងទៀតនៅស្រុកកងមាស គឺភូមិអង្គបាន២ ត្រូវបានប្រមូលផ្តុំគ្នានៅល្ងាចមួយ ហើយបញ្ជូនទៅដាក់គុកនៅវត្តអូរត្រកួន[147]។ ប្រជាជនចាមដែលនាំយកមកពីភូមិអង្គរបាន២ សុទ្ធតែជាស្ត្រី និង ក្មេងៗនៅពេលដែលបុរសជនជាតិចាមទាំងអស់ត្រូវបានបំបែកចេញពីគ្រួសាររបស់ពួកគេ ហើយតាំងលំនៅថ្មីជាមួយកងចល័ត[148]។ សាក្សីដែលបានបញ្ជូនជនជាតិចាមពីភូមិអង្គរបាន២ បានឃើញប្រជាជនចាមដើរកាត់របងទៅកាន់វត្តអូរត្រកួននៅពេលដែលគាត់មកដល់ទីនោះ[149]។ គាត់ជឿថាខ្មែរក្រហមមិនចង់អោយជនជាតិភាគតិចចាមរស់នៅក្នុងភូមិនេះ ឬ នៅក្នុងប្រទេសកម្ពុជាទេ ហើយជនជាតិចាមមកពីភូមិនេះត្រូបានចាប់ខ្លួនដោយសារតែប្រជាជនទាំងនោះជាប្រជាជនចាម ទោះបីជាប្រជាជនទាំងនោះខិតខំធ្វើការនិងមិនបានប្រព្រឹត្តកំហុសឆ្គងអ្វីក៏ដោយ[150] ។

៤៣. ក្នុងឱកាសមួយផ្សេងទៀតក្នុងឆ្នាំ១៩៧៧ គ្រួសារជនជាតិចាមប្រាំពីរ ឬ ប្រាំបីគ្រួសារត្រូវបានសម្លាប់នៅឯមាត់ទន្លេក្នុងឃុំរកាគយ ស្រុកកងមាស[151] ។

៤៤. ការសម្លាប់រង្គាលសហគមន៍ចាមនៅក្នុងស្រុកកងមាស នៅឯវត្តអូរត្រកួនបានធ្វើឡើងតែក្នុងអំឡុងពេល១០ថ្ងៃប៉ុណ្ណោះបន្ទាប់ពីលេខាតំបន់៤១ ឈ្មោះ **តាអាន** បានធ្វើទស្សនកិច្ចទៅកាន់ការដ្ឋាននៅក្នុងស្រុក ជើងព្រៃដែលនៅជាប់គ្នា ហើយ **តាអាន** បានបញ្ជាមេកងអោយបង្ហាញចំនួនជនជាតិចាមដែលនៅសល់ ហើយប្រមូលផ្តុំពួកគេ "ដើម្បីបញ្ជូនពួកគេទៅកាន់មូលដ្ឋានដើមវិញ"[152] ។ ក្នុងព្រឹត្តិការណ៍ក្រោយពីមានបញ្ជារបស់ **តាអាន** ជនរងគ្រោះត្រូវបានសម្លាប់ដោយសារតែពួកគេជា

ជនជាតិចាម ហើយការសម្លាប់នេះគឺធ្វើដោយមានអមដោយសេចក្ដីថ្លែងបញ្ជាក់អំពីចេតនាប្រល័យពូជសាសន៍។ ការសម្លាប់នោះនាំដល់ការបំផ្លាញជនជាតិចាមមួយផ្នែកធំដែលរស់នៅក្នុងតំបន់នោះ ។

៤៥. ការសម្លាប់ជនជាតិចាមទាំងភូមិៗបានកើតឡើងនៅក្នុងទីតាំងផ្សេងៗទៀតនៅកំពង់ចាម ដោយរួមទាំងបណ្ដាភូមិស្ថិតនៅត្រើយម្ខាងនៃទន្លេមេគង្គក្នុងស្រុកក្រូចឆ្មារ ដែលជាផ្នែកមួយនៃភូមិភាគបូព៌ា ។ ក្នុងករណីខ្លះ ជនជាតិចាមដែលរស់នៅក្នុងភូមិភាគកណ្ដាលក៏អាចត្រូវបាននាំឆ្លងកាត់ទន្លេទៅសម្លាប់នៅក្រូចឆ្មារដែរ។ តួយ៉ាងដូចជា នៅក្នុងភូមិកោះផល (កោះមួយនៅកណ្ដាលទន្លេមេគង្គក្នុងស្រុក ក្រូចឆ្មារ) គេមើលឃើញមានទូកដឹកជនរងគ្រោះមកដល់ជារៀងរាល់ថ្ងៃក្នុងអំឡុងឆ្នាំ១៩៧៧ ឆ្លងកាត់តាមទន្លេមេគង្គ (ស្រុកព្រែកប្រសប់ ឬ ស្រុកស្ទឹងត្រង់ ដែលជាផ្នែកមួយនៃភូមិភាគកណ្ដាល) និងនៅកន្លែងផ្សេងៗទៀត[153] ។ នៅភូមិកោះផល ក្នុងចំណោមអ្នកស្រុកជនជាតិចាមប្រហែល១៨៦៤ នាក់ដែលរស់នៅទីនោះក្នុងឆ្នាំ១៩៧៥ មានតែ ១៨០ នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតក្នុងឆ្នាំ១៩៧៩[154] ។

៤៦. ជាងនេះទៅទៀត ជនជាតិចាមដែលតាំងទីលំនៅនៅក្នុងបណ្ដាភូមិក្នុងផ្នែកនៃភូមិភាគបូព៌ា នៃទន្លេមេគង្គ អាចត្រូវបាននាំយកឆ្លងកាត់ទន្លេរទៅសម្លាប់នៅភូមិភាគកណ្ដាល។ អ្នកស្រុកដែលរស់នៅក្នុងភូមិជនជាតិចាមចំនួន៥ ក្នុងស្រុកក្រូចឆ្មារ ឬក៏ទ្រា ១-៥ ត្រូវបាន "ផ្លាស់ចេញ" និងយកទៅសម្លាប់ចោល[155] ។ ភូមិទាំងនោះមានទីតាំងកាត់ទន្លេពីគុកវត្តស្ទឹងត្រង់ ក្នុងស្រុកស្ទឹងត្រង់ (ឃុំព្រែកកក់)ផ្នែកមួយនៃតំបន់៤២នៃភូមិភាគកណ្ដាល[156] ។ ប្រជាជនដែលរស់នៅស្ទឹងត្រង់ បានរាយការណ៍ថាបានឃើញសាកសពជនជាតិចាមជាច្រើន រួមទាំងក្មេងៗ ដែលក្បាលរបស់ពួកគេត្រូវបានកាត់ចោលបណ្ដែតតាមទឹកទន្លេមេគង្គ[157] ។ នៅចុងឆ្នាំ១៩៧៨ អ្នកទោសដែលនៅសល់នៅទ្រា ត្រូវបានប្រមូលហើយសួរពួកគេថា តើពួកគេជាជនជាតិខ្មែរ ឬ ជនជាតិចាម ហើយក៏បំបែកទៅតាមប្រភេទនោះទៅ។ អ្នកទោសខ្មែរត្រូវបានគេរាយការណ៍ថាទទួលការដោះលែង ចំណែកឯអ្នកទោសជនជាតិចាមចំនួន១០០នាក់បានបាត់ខ្លួន លើកលែងតែជនជាតិចាម៦រូបដែលបានលាក់អត្តសញ្ញាណរបស់ពួកគេ[158] ។

៤៧. លទ្ធផលចុងក្រោយនៃរបបប្រល័យពូជសាសន៍នេះ ប្រជាជនចាមជាច្រើនផ្នែកនៅកំពង់ចាមត្រូវបានសម្លាប់[159] ។ ក្នុងចំណោមប្រជាជនចាមដែលរស់នៅក្នុងរបបប្រល័យកម្ពុជាប្រជាធិបតេយ្យ ក្នុងបួនភូមិដែលស្គាល់ក្នុងស្រុកកងមាសមានតែ២នាក់ប៉ុណ្ណោះដែលបានគេចខ្លួនរួច ហើយនៅរស់រានមានជីវិត[160] ។ ជនជាតិចាមដែលបានជម្លៀសពីភូមិទាំងនោះទៅតំបន់ដទៃទៀត នៅដើមដំបូងនៃអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យក៏ទំនងជាត្រូវបានសម្លាប់ផងដែរ។ ភូមិមួយក្នុងចំណោមភូមិទាំងបួន គឺអន្ទង់ស (ហៅ អង្គរបាន ១) ក្នុងចំណោមប្រជាជន ចាមជាង៦០០

គ្រួសារដែលរស់នៅទីនោះក្នុងឆ្នាំ១៩៧៥ គ្មាននៅសល់ម្នាក់ណាឡើយនៅចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបន្ទាប់មកមានតែ៣០គ្រួសារប៉ុណ្ណោះបានត្រឡប់ទៅស្រុកវិញ[161] ។ នៅភូមិសាច់ស្វ ក្នុងចំណោមប្រជាជនចាមចំនួន៣០០គ្រួសារដែលបានតាំងទីលំនៅនៅទីនោះមុនឆ្នាំ ១៩៧៥ មានតែមួយគ្រួសារប៉ុណ្ណោះដែលបានត្រលប់ទៅវិញ[162] ។ ប្រជាជនចាមជាច្រើន រហូតដល់១០.០០០ អាចត្រូវបានសម្លាប់នៅក្នុងមន្ទីរសន្តិសុខវត្តអូរត្រកួនតែមួយកន្លែង[163] ។

៤៨. ក្នុងចំណោមប្រជាជនជាង ១៥៨.០០០ នាក់ដែលជឿថាត្រូវបានសម្លាប់នៅក្នុងខេត្តកំពង់ចាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានប្រហែលជា ៧៥.០០០នាក់ ក្នុងចំណោមប្រជាជនទាំងនោះ (ស្មើរតែ៥០ភាគរយនៃចំនួនស្លាប់សរុប) ត្រូវបានស្គាល់ថាជា "ជនជាតិភាគតិច"[164] ។ នេះគឺជាចំនួនភាគរយខ្ពស់ជាងខេត្តដទៃទៀតយ៉ាងច្រើន ។ តួយ៉ាងក្នុងចំណោមប្រជាជនជាង ៣២៥.០០០ នាក់ដែលបានស្លាប់នៅក្នុងខេត្តកំពង់ធំមានជនជាតិភាគតិច[165] តែ ១.៥០០ នាក់ប៉ុណ្ណោះ ហើយក្នុងចំណោមប្រជាជនជាង ៤៧០.០០០ នាក់ដែលត្រូវបានសម្លាប់នៅក្នុងខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបងមានជាជនជាតិភាគតិចប្រហែលជា ៩២.៥០០ នាក់[166] ។

## ខេត្តកំពង់ធំ

## មន្ទីរសន្តិសុខវត្តស្រម៉ៃ

៤៩. មន្ទីរសន្តិសុខវត្តស្រម៉ៃគឺជាគុកដែលមានកន្លែងសម្លាប់ចំនួនពីរគឺ នៅព្រៃត្បែង និងព្រៃដងវែងដែលមានទីតាំងនៅក្នុងភូមិត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ (ផ្នែកមួយនៃតំបន់៤៣ នៃភូមភាគកណ្តាល)[167] ។ ការសម្លាប់រង្គាលនៅទីនោះភាគច្រើនធ្វើឡើងតែមួយឆ្នាំប៉ុណ្ណោះចាប់ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ១៩៧៨ ដែលក្នុងអំឡុងពេលនោះប្រជាជនចន្លោះពី ១៥.០០០ ទៅ ៣៦.០០០ នាក់ត្រូវបានសម្លាប់ យោងតាមសំដីរបស់ប្រធានមន្ទីរសន្តិសុខគុក[168] ។ ជនរងគ្រោះរួមមាន ប្រជាជនថ្មី ទាហាន ប្រជាជនមូលដ្ឋាន ដែល "ជាប់ទិន្នាការ" ឬកម្មាភិបាលដែល "ខុសសីលធម៌"[169] ។ កន្លែងសម្លាប់ នៅឯព្រៃដងវែងមាន ៤០០ ទៅ ៥០០ រណ្តៅ ដែលមានទំហំពី ពីរម៉ែត្របួនជ្រុង ទៅបួនម៉ែត្របួនជ្រុង ហើយជម្រៅប្រហែលជា ១.៥ ម៉ែត្រ[170] ។ កន្លែងសម្លាប់នៅព្រៃត្បែង មាន ៥០រណ្តៅ ដែលរណ្តៅមួយៗមានទំហំ ៣ទៅ៤ម៉ែត្រគូប[171] ។ វត្តអាចដាក់អ្នកទោសបានពី ១៣០ ទៅ ១៤០ នាក់ ហើយក្នុងអំឡុងឆ្នាំ១៩៧៨ គ្រួសារជាច្រើនត្រូវបាននាំយកមកដោយរទេះគោជារៀងរាល់ថ្ងៃ[172] ។ អ្នកទោសត្រូវគេដាក់ខ្នោះជើង ស្ទួរចម្លើយ ហើយត្រូវបានធ្វើទារុណកម្មដោយប្រើទឹក[173] ។ មានមនុស្សតិចតួចណាស់ដែលត្រូវបានដោះលែង[174] ។

## គុក និងកន្លែងសម្លាប់មនុស្សនៅទួលតាផ្លុង

៥០. មន្ទីរសន្តិសុខទួលតាផ្លុងមានទីតាំងនៅវិទ្យាល័យរស្មីសោភ័ណ ក្នុងភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ (ផ្នែកនៃតំបន់៤៣នៃភូមភាគកណ្តាល)[175] ។ កន្លែងប្រហារជីវិតនៅមន្ទីរសន្តិសុខមានទីតាំងនៅទួលតាផ្លុង[176] ។ គេជឿថាយ៉ាងហោចណាស់ ប្រជាជន ៤០.០០០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខនេះ[177]។ ចេតិយនៅកន្លែងនោះត្រូវបានរាយការណ៍ថាមានការប្រមូលផ្តុំគ្រោងលលាដ៍ក្បាលខ្មោចជាច្រើនជាងគេបង្អស់នៅក្រៅទីក្រុងភ្នំពេញនិងនៅវត្តជើងឯក[178] ។

៥១. នៅដើមឆ្នាំ១៩៧៥ វិទ្យាល័យត្រូវបានយកធ្វើជាគុក[179] ។ អគារ ឬ បន្ទប់ជាច្រើនត្រូវបានប្រើសម្រាប់ ឃុំអ្នកទោស ហើយបន្ទប់មួយផ្សេងទៀតត្រូវបានប្រើសម្រាប់សួរចម្លើយ[180] ។ នៅពេលនោះមាន អ្នកទោសច្រើនជាង ៥០០ នាក់ត្រូវបានឃុំខ្លួននៅនៅក្នុងសាលារៀន[181] ។ ក្នុងឆ្នាំ ១៩៧៥-១៩៧៦ ជាទូទៅអ្នកទោសត្រូវបានឃុំខ្លួនពី១ខែទៅ២ខែ ប៉ុន្តែក្នុងអំឡុងឆ្នាំ១៩៧៧-១៩៧៨ ការបោសសំអាតជនក្បត់ត្រូវបានបង្កើន ដោយអ្នកទោស ត្រូវបានឃុំខ្លួនតែមួយយប់ ប៉ុណ្ណោះមុនពេលយកទៅសម្លាប់ចោល[182] ។ នៅចុងឆ្នាំ ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨ អ្នកទោស១៧មេសា ជាច្រើនត្រូវបានសម្លាប់ហើយក្នុងខែមករាឆ្នាំ១៩៧៩អ្នកទោសទាំងអស់ត្រូវបានប្រហារជីវិតមុនពេលកងទ័ពវៀតណាមចូលមកដល់[183] ។

## មន្ទីរសន្តិសុខវត្តកណ្តាល

៥២. មន្ទីរសន្តិសុខវត្តកណ្តាលមានទីតាំងនៅក្នុងភូមិសៀមរាង ឃុំច្រនៀង ស្រុកបារាយណ៍ ខេត្តកំពង់ធំ (ផ្នែកមួយនៃតំបន់៤២នៃភូមភាគកណ្តាល)[184] ។ ប្រជាជនជាច្រើនពាន់នាក់ត្រូវបានសម្លាប់នៅត្រង់ទីតាំងនេះ[185] ។ បន្ទាប់ពីការមកដល់នៃពួកកម្មាភិបាលភូមិភាគនិរតី មេសហករណ៍ និង គណៈស្រុក ទាំងអស់បានបាត់ខ្លួន[186]។ នៅក្នុងសហករណ៍មួយមានប្រជាជន ២.០០០នាក់ក្នុងចំណោម ៧.០០០នាក់ ត្រូវបានដឹកយកទៅតាមឡាន ហើយមិនដែលបានត្រឡប់មកវិញទេ[187] ។ អតីតឆ្មាំសន្តិសុខនៅគុកនេះ បានឃើញការធ្វើទារុណកម្ម ការសម្លាប់ (ដោយរួមទាំងក្មេងៗ ដែលត្រូវបានសម្លាប់ ដោយបោក នឹងសសរ) និងការវះយកថ្លើមមនុស្សចេញទាំងរស់[188] ។

## មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក[189]

៥៣. មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែកមានទីតាំងនៅភូមិត្រស់ ឃុំបាល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ (ផ្នែកមួយនៃតំបន់៤២ ភូមិភាគកណ្តាល)[190] ។ តាមការប៉ាន់ស្មានប្រជាជនចន្លោះពី ១៥.០០០ ទៅ ២០.០០០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខនេះ[191] ។ ចេតិយធំមួយនេះទំនងជាមានផ្ទុកគ្រោងឆ្អឹងមនុស្សប្រមាណ១០.០០០នាក់[192] ។ ជនរងគ្រោះរួមមាន ប្រជាជនថ្មី ប្រជាជនមូលដ្ឋាន ជនជាតិចាម ជនជាតិភាគតិច វៀតណាម ចិន[193] ។ បទសម្ភាសន៍ជាមួយសាក្សីបានបង្ហាញថាអំឡុងពេលដែលមានការសម្លាប់ធ្ងន់ធ្ងរបំផុតកើតកើតមានឡើងបន្ទាប់ពីកម្មាភិបាលនិរតីបានមកដល់ភូមិភាគកណ្តាល[194] ។ ចំនួនអ្នកទោសដែលបានរស់រានមានជីវិត បានពិពណ៌នាពីស្ថានភាពអមនុស្សធម៌នៅក្នុងគុករួមទាំងការវាយធ្វើបាប និងទុកបង្អត់អាហាររយៈពេលយូរ[195] ។

## ភូមិភាគពាយ័ព្យ

## ការបោសសម្អាតនៅភូមិភាគពាយ័ព្យ

៥៤. ចាប់ផ្តើមពីខែមិថុនា ឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានបោសសម្អាតចាប់តាំងពីថ្នាក់ភូមិ រហូតដល់ថ្នាក់ភូមិភាគ ពីសំណាក់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាមកពីភូមិភាគនិរតីដែលដឹកនាំដោយ តាម៉ុក **តាទិត** និង **អ៊ឹម ចែម**[196] ។

៥៥. ការបោសសម្អាតបានចាប់ផ្តើមនៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ ដោយមានការចាប់ខ្លួនសមាជិកគណៈភូមិភាគពាយ័ព្យ និងលេខាតំបន់១ ឈ្មោះ រស់ ម៉ៅ ហៅ សាយ[197], ព្រមជាមួយនឹងការមកដល់របស់កងកំលាំងភូមិភាគនិរតី នៅក្នុងស្រុកព្រះនេត្រព្រះ ដែលដឹកនាំ ដោយ **អ៊ឹម ចែម**។ លេខាភូមិភាគនិរតី និង សមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ឈ្មោះ តាម៉ុក បានចាត់តាំងឱ្យ **អ៊ឹម ចែម** គ្រប់គ្រងនៅក្នុងស្រុកព្រះនេត្រព្រះ និង "ដោះស្រាយ" បញ្ហាប្រជាជននៅទីនោះ[198], ព្រមទាំងបានទំនាក់ទំនងជាមួយ **ចែម** និង បានផ្តល់បទបញ្ជាទៅឱ្យគាត់ [ចែម] បន្ទាប់ពី គាត់ [ចែម] បានផ្លាស់ទៅកាន់ភូមិភាគពាយ័ព្យនោះ[199] ។

៥៦. បន្ទាប់ពីបានមកដល់ស្រុកព្រះនេត្រព្រះ **អ៊ឹម ចែម** បានជួបជាមួយអ្នកកាន់តំណែងមុន ដែលជាលេខាស្រុក ឈ្មោះ អន ម៉ោង (AN Maong) ហើយបានទទួលបញ្ជីឈ្មោះមនុស្ស ចំនួន១០០,០០០ នាក់ ដោយរាប់បញ្ចូលទាំងកម្មាភិបាលថ្នាក់ស្រុកដែលកំពុងធ្វើការនៅទីនោះផង[200] ។ មិនយូរប៉ុន្មាន អន ម៉ោង (AN Maong) ត្រូវបានចាប់ខ្លួនពោលគឺ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៧[201], ហើយរយៈពេលពីរបី ថ្ងៃក្រោយមក កម្មាភិបាលជាន់ខ្ពស់ផ្សេងៗទៀតមកពីតំបន់៥ និង ស្រុកព្រះនេត្រព្រះ

ក៏ត្រូវបានចាប់ខ្លួនដែរ[202] ។ **អ៊ឹម ចែម** បាននាំមកជាមួយគាត់នូវកម្មាភិបាលភូមិភាគនិរតីចំនួន ៥០០នាក់ ទៅកាន់ស្រុកព្រះនេត្រព្រះ ហើយបានប្រើប្រាស់កំលាំង ទាំងអស់នោះ ដើម្បីធ្វើការដក ហូតអាវុធពីកម្មាភិបាលភូមិភាគពាយ័ព្យនៅទីនោះព្រមទាំងបានបញ្ជូនអ្នកទាំងអស់នោះទៅកាន់ការ ដ្ឋានធ្វើការងារដោយបង្ខំ ឬទៅមន្ទីរសន្តិសុខ[203], ដូចជា (មន្ទីរ)ស-២១ និងគុកតំបន់៥ នៅភ្នំទ្រយោង[204] ដែលអ្នកទាំងអស់នោះ ត្រូវបានឃុំខ្លួន និងសម្លាប់ចោល។ កម្មាភិបាលគ្រប់ជាន់ថ្នាក់ទាំងអស់ដែល មានស្រាប់នៅភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ដោយរាប់ចាប់តាំងពីប្រធានភូមិ ប្រធានឃុំ មន្ត្រីថ្នាក់ស្រុកនិងតំបន់ ព្រមទាំងសមាជិកគ្រួសាររបស់អ្នកទាំងនេះដែរ[205] ។

៥៧. ចាប់ពីប៉ុន្មានខែចុងក្រោយនៃឆ្នាំ១៩៧៧ រហូតដល់នៅពាក់កណ្តាលឆ្នាំ១៩៧៨ ការបោសសម្អាត ត្រូវបានពង្រីកជាលក្ខណៈប្រព័ន្ធដល់ទូទាំងភូមិភាគពាយ័ព្យទាំងមូលតែម្តង។ ឧទាហរណ៍ នៅក្នុងខែ សីហា ឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគនិរតី (ដែលជួនកាលត្រូវបាន ហៅថាជា ពួកនិរតី) បានមក ដល់ក្នុងស្រុកមោងឫស្សី ហើយ “មេដឹកនាំចាស់ៗទាំងអស់ ត្រូវបានសម្លាប់ចោល”[206] ។ នៅស្រុក បាត់ដំបងនៃតំបន់៤ កម្មាភិបាលភូមិភាគនិរតី បានមកដល់ នៅក្នុងខែសីហា និងបានចូលរួម ជាមួយកម្មាភិបាលភូមិភាគបស្ចិម[207] ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ ហើយ “នៅក្នុងខែមេសា ឆ្នាំ១៩៧៨ កម្មាភិបាលមូលដ្ឋានស្រាប់តែបាត់ខ្លួនមួយរំពេច”[208] ។ នៅក្នុងស្រុកស៊ីសុផុនរបស់តំបន់៥ កម្មាភិបាល មូលដ្ឋាន“ត្រូវបានបោសសម្អាតទាំងអស់ ហើយបាននាំទៅកន្លែងផ្សេងៗទៀត និងជំនួស ដោយពួកនិរតី” នៅក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ១៩៧៧[209] ។ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ កម្មាភិបាល ភូមិភាគពាយ័ព្យនៅក្នុងខេត្តពោធិ៍សាត់ “ត្រូវបានបង្ខំឱ្យឡើងជិះឡាន ហ្សេ.អឹម.សេ និងបានដឹក យកតាមទិសដៅទៅស្រុកមោងឫស្សី”[210] ។ នៅកន្លែងវត្តបន្ទាយនាង របស់ស្រុកមង្គលបុរី ប្រធានៗ នៅមូលដ្ឋាន “ត្រូវបានចាប់ខ្លួនដោយពួកនិរតី ដែលកំពុងមកដល់ទីនោះ នៅក្នុងខែមីនា ឆ្នាំ១៩៧៨”[211] ។ ភ័ស្តុតាងស្រដៀងគ្នានេះដែរ កើតមាននៅតាមកន្លែងផ្សេងៗទៀតរបស់ភូមិភាគពាយ័ព្យ[212] ។ ការបោសសម្អាតត្រូវបានដាក់ឱ្យអនុវត្តន៍ពីសំណាក់ កងកំលាំងយោធារបស់ភូមិភាគ និរតីរបស់ តាម៉ុក ដែល “ដកហូតអាវុធ” ពីកម្មាភិបាលមូលដ្ឋានរបស់ភូមិភាគពាយ័ព្យ[213] ។

៥៨. ការបោសសម្អាត ដែលកើតឡើងនៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ ដោយមានការចាប់ខ្លួនប្រធាន ភូមិភាគជាន់ខ្ពស់ និងប្រធានតំបន់ ដោយរាប់បញ្ចូលទាំងលេខាភូមិភាគពាយ័ព្យ ឈ្មោះ មូល សម្បត្តិ ហៅ រស់ ញឹម[214], អនុលេខាភូមិភាគពាយ័ព្យ ឈ្មោះ គី[215], លេខាតំបន់៣ ឈ្មោះ ភោគ សារី ហៅ តុំ[216], លេខាតំបន់១និងសមាជិកគណៈភូមិភាគពាយ័ព្យ ឈ្មោះ ហេង ទាវ ហៅ ប៉ែត ហៅ កន្ទុល[217] និង កូនរបស់ ញឹម ឈ្មោះ ដៀល[218] ។ នៅពេលដែលការបោសសម្អាតបានចប់សព្វគ្រប់ **តាទិត** បានលេចឡើងធ្វើជាលេខាស្តីទីរបស់ ភូមិភាគពាយ័ព្យ ហើយបណ្តាញគ្រប់គ្រងរបស់បក្សកុម្មុយនីស្ត

កម្ពុជាថ្នាក់តំបន់ ស្រុក និងឃុំ ត្រូវបានជំនួសដោយកម្មាភិបាលភូមិភាគនិរតី ដែលបានរាយការណ៍មកឱ្យគាត់ [តាម៉ុក][219] ។ កម្មាភិបាលភូមិភាគពាយ័ព្យដែលត្រូវបោសសម្អាតត្រូវបាន "បាត់ខ្លួន" និងមិនដែលឃើញត្រឡប់មកវិញឡើយ ឬក៏ត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីស-២១ ជាមន្ទីរដែលអ្នកទាំងអស់នោះត្រូវបានសម្លាប់ជាបន្តបន្ទាប់[220] ។ ភូមិភាគពាយ័ព្យមានចំនួនអ្នកទោសជាប់នៅមន្ទីរស-២១ខ្ពស់ជាងគេបំផុតបើប្រៀបធៀបជាមួយភូមិភាគផ្សេងៗទៀត ដោយមានចំនួន៥ដងច្រើនជាងចំនួនអ្នកទោសមកពីភូមិភាគដែលមានអ្នកទោសច្រើនជាងគេបន្ទាប់ទី២[221] ។

៥៩. ក្រៅពីការបោសសម្អាតកម្មាភិបាលដែលមានស្រាប់នៅទីនោះ ការចាប់ខ្លួន ការសម្លាប់ និង ការបាត់ខ្លួនមានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងចំណោមប្រជាជនទូទៅនៅក្នុងស្រុកព្រះនេត្រព្រះ[222] និងទូទាំងភូមិភាគពាយ័ព្យ[223] បន្ទាប់ពី **តាម៉ុក**, **អ៊ឹម ចែម**, តាម៉ុក និងកម្មាភិបាល ភូមិភាគនិរតីចូលមកគ្រប់គ្រង។ តាមសម្តីរបស់អ្នករស់រានមានជិវិតម្នាក់មកពីខាង (ភូមិភាគ) ពាយ័ព្យបានឱ្យដឹងថា "ឆ្នាំ១៩៧៨ជាឆ្នាំដែលមានការសម្លាប់យ៉ាងរង្គាល"[224] ។ ជនរងគ្រោះនៅក្នុងអំឡុងពេលនោះរួមមាន ប្រជាជនថ្មី[225] ប្រជាជនមូលដ្ឋាន[226] អ្នកមានជាតិពន្ធុវៀតណាម[227]ហើយ ប្រជាជនទាំងឡាយៗដែលត្រូវបាននាំមកពីភូមិបូព៌ាទៅកាន់ទីនោះ[228] ។ មន្ទីរសន្តិសុខ ទីតាំងសម្លាប់ និងការដ្ឋានធ្វើការដោយបង្ខំ ដែលនឹងមានរៀបរាប់នៅក្នុងកថាខណ្ឌខាងក្រោម គឺជាទីតាំងប្រព្រឹត្តបទឧក្រិដ្ឋកម្មដែលជនរងគ្រោះទាំងអស់នេះត្រូវបានឃុំខ្លួន និងសម្លាប់ចោលនៅក្នុងអំឡុងពេលនោះដែល **តាម៉ុក**, **អ៊ឹម ចែម**, និងកម្មាភិបាលភូមិនិរតី ធ្វើការគ្រប់គ្រងនៅក្នុងតំបន់ ភូមិភាគពាយ័ព្យនោះ។

## វត្តគីរីរម្យ

៦០. មន្ទីរសន្តិសុខវត្តគីរីរម្យ មានទីតាំងស្ថិតនៅក្នុងភូមិភ្នំសំពៅ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ដែលជាផ្នែកមួយរបស់តំបន់១នៃភូមិភាគពាយ័ព្យ[229] ។ ប្រជាជនច្រើន រហូតដល់១៥,០០០នាក់ត្រូវបានសម្លាប់នៅទីតាំងនោះ[230] ។ រយៈពេលដ៏ធ្ងន់ធ្ងរបំផុត នៃការសម្លាប់រង្គាលនៅទីតាំងនេះគឺនៅក្នុងឆ្នាំ១៩៧៨ដល់១៩៧៩[231] ដែលជារយៈពេលដូចគ្នានៅក្នុងអំឡុងពេលដែល **តាម៉ុក** ធ្វើការគ្រប់គ្រង និងមានសិទ្ធិអំណាចទៅលើទីកន្លែងនោះ ក្នុងនាមជាលេខាតំបន់១ និងលេខាស្តីទីរបស់ភូមិភាគពាយ័ព្យ។

## ទីតាំងសម្លាប់នៅបន្ទាយអូតាក្រៃ

៦១. ទីតាំងសម្លាប់នេះស្ថិតនៅក្នុងភូមិអូតាក្រៃ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងក៏ជាផ្នែកមួយរបស់តំបន់១នៃភូមិភាគពាយ័ព្យដែរ[232] ។ តាមការប៉ាន់ស្មានថា មានប្រជាជនចំនួន ១,៥០០នាក់ ត្រូវបានសម្លាប់នៅក្នុងទីតាំងនេះ[233] ។ ជនរងគ្រោះត្រូវបានដឹកតាមឡានពី ភូមិភាគបូព៌ាទៅសម្លាប់ចោលនៅបន្ទាយអូតាក្រៃ ក្នុងចន្លោះឆ្នាំ១៩៧៧ និង ដើមឆ្នាំ ១៩៧៩[234] ។ អតីតទាហានកងចល័តម្នាក់ឃើញផ្ទាល់ភ្នែក អ្នកសម្លាប់បានវាយជនរងគ្រោះនៅក្នុងទីតាំងនេះ[235] ។

## មន្ទីរសន្តិសុខបន្ទាយត្រែង

៦២. មន្ទីរសន្តិសុខបន្ទាយត្រែង ស្ថិតនៅក្នុងភូមិគីឡូ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងក៏ជាផ្នែកមួយរបស់តំបន់១នៃភូមិភាគពាយ័ព្យ[236] ។ តាមការប៉ាន់ស្មានមានប្រជាជន ចំនួន ៨០០ ទៅ ១,០០០ នាក់ ត្រូវបានសម្លាប់នៅក្នុងទីតាំងនេះ[237] ។ ការសម្លាប់ដ៏ខ្លាំងក្លាបំផុតបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ខណៈពេលដែលប្រជាជន មួយចំនួនធំត្រូវបាន "សម្លាប់ដោយមិនរើសមុខ"[238]។ ទំហំដីនៃវាលពិឃាតនោះមានចំនួន ១០ហិកតា និងគ្របដណ្តប់ទៅដោយព្រៃឫស្សីទាំងអស់ ដែលត្រូវបានហៅថា ព្រៃឫស្សីសង្កាដែក[239] ។ ជនដែលដល់ម្នាក់ ដែលនៅរស់រានមានជីវិតនៅឡើយត្រូវបានរកឃើញ[240] ។

## មន្ទីរសន្តិសុខវត្តធម្មយុត

៦៣. មន្ទីរសន្តិសុខវត្តធម្មយុត (ដែលឥឡូវនេះហៅថា វត្តបូផារត្តិ) មានទីតាំងនៅក្នុងភូមិរាមគុន ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដែលស្ថិតនៅចំងាយ៦០០ម៉ែត្រពីទីបញ្ជាការស្រុក[241] ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ស្រុកមោងឫស្សី ត្រូវបានបែងចែក ជាពិសេសរវាងតំបន់១ និងតំបន់៤ របស់ភូមិភាគពាយ័ព្យ[242] ។ តាមការប៉ាន់ស្មានថា មានមនុស្សចំនួន ១,០០០នាក់ ត្រូវបានសម្លាប់នៅក្នុងមន្ទីរសន្តិសុខនេះ ហើយចំនួននៃការសម្លាប់កាន់តែមានសភាព "ធ្ងន់ធ្ងរខ្លាំង" នៅក្នុងខែ វិច្ឆិកា និងខែធ្នូ ឆ្នាំ១៩៧៨ នៅពេលដែលភូមិទាំងអស់ត្រូវបានសម្លាប់ដោយពួកនិរតី (កម្មាភិបាលភូមិភាគនិរតី) និង "អ្នកគាំទ្រតាម៉ុក"[243] ។ ពួកនិរតី បានមកដល់ តំបន់នេះនៅក្នុងអំឡុងខែសីហា ឆ្នាំ១៩៧៧ ដែលនៅពេលនោះមេដឹកនាំថ្នាក់ស្រុកទាំងអស់ត្រូវបានសម្លាប់ចោល[244] ។

៦៤. កន្លែងគុកនោះមានទំហំ១៥ម៉ែត្រ គុណនឹង៦០ម៉ែត្រ[245] ។ ប្រជាជនទូទាំងស្រុកត្រូវបាន ឃុំខ្លួន ដោយដាក់ខ្នោះ សួរចម្លើយ និងបន្ទាប់មកត្រូវសម្លាប់ចោលនៅខាងមុខវិហារ[246] ។ អ្នកធ្វើការនៅក្នុងកងចល័តម្នាក់នៅតំបន់នោះបានឃើញផ្ទាល់ភ្នែកចំពោះការសម្លាប់នេះ និងបានឃើញសន្តិសុខគុកឆាថ្លើមមនុស្ស និង "បានដាក់ថ្លើមមនុស្សប្រមាណជា៥០-៦០ហាលថ្ងៃ"[247] ។ សាក្សីម្នាក់ផ្សេងទៀតក៏បានសង្កេតឃើញកម្មាភិបាលនៅក្នុងគុកនេះស៊ីថ្លើមមនុស្សនាដែរ[248] ។

## មន្ទីរសន្តិសុខវត្តកណ្តាល

៦៥. មន្ទីរសន្តិសុខវត្តកណ្តាល មានទីតាំងនៅត្រើយខាងកើតនៃស្ទឹងសង្កែ ដែលស្ថិតនៅចំកណ្តាលទីក្រុងបាត់ដំបង ហើយក៏ជាគុកធំបំផុតនៅក្នុងភូមិភាគពាយ័ព្យ[249] ។ នាពេលបច្ចុប្បន្ននេះ មិនមានការប៉ាន់ស្មានណាមួយស្តីពីចំនួនប្រជាជន ដែលត្រូវបានសម្លាប់នៅទីតាំងមន្ទីរសន្តិសុខនេះទេ ក៏ប៉ុន្តែបើយោងតាមអ្នកនៅរស់ជីវិតម្នាក់ថា អ្នកទោសត្រូវបានសម្លាប់ចោលស្ទើររាល់ថ្ងៃ និងខ្មោចត្រូវបានអូសយកចេញ "ដូចសត្វជ្រូក ដោយដៃ និងជើងចងភ្ជាប់ទៅនឹងព្រនង់ឬស្សីមួយ"[250]។ អគារឃុំខ្លួនរបស់មន្ទីរសន្តិសុខនេះមានកំពស់បីជាន់ និងមាន "បន្ទប់ជាច្រើនសម្រាប់ដាក់អ្នកទោស"[251] ។ វត្តកណ្តាលជាគុកមានការរៀបចំយ៉ាងប្រុងប្រយ័ត្ន ដែលបញ្ជីអ្នកទោសត្រូវរក្សាទុក[252] អ្នកទោសត្រូវថតរូប និងសំណុំឯកសារជាលាយលក្ខណ៍អក្សរជាមួយនឹងប្រវត្តិរូបត្រូវបានរៀបចំទុក[253]។ នៅក្នុងឆ្នាំ១៩៧៨ អ្នកទោសត្រូវបានសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់នៅក្នុងវត្ត ឬនៅក្នុងផ្ទះនានាដែលស្ថិតនៅស្ថិតនៅក្បែរៗវត្តនោះ[254]។ វ៉ាន់ ណាត ដែលបានជាប់ ឃុំឃាំងនៅវត្តកណ្តាលចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៨[255] ត្រូវបាននាំយកទៅព្រៃខាងក្រោយគុកដាក់ទៅក្នុង "ផ្ទះថ្មតូចមួយ" ជាកន្លែងដែលគាត់បានឃើញ "រនុកដែកយ៉ាងវែង ដំបងស្បោងផ្លាស្ទិក និងរំពាត់" ភ្ជួរនៅលើជញ្ជាំង និង "ស្នាមប្រឡាក់ឈាមស្រស់ៗ" នៅខាងក្រោមកៅអីរបស់គាត់ទៀតផង[256]។

៦៦. វិធីធ្វើទារុណកម្មម្យ៉ាង ដែលត្រូវបានប្រើប្រាស់នៅទីនេះ គឺលាម្រាមដៃបីកណ្តាលរបស់អ្នកទោសរួចយកកម្ចុល និងស្លាបមាន់ចាក់[257]។ ការឆក់ខ្សែភ្លើងក៏ត្រូវបានធ្វើឡើងដែរដើម្បីធ្វើទារុណកម្ម អ្នកទោស និងជម្រិតយកចម្លើយ[258]។ បរិយាកាសនៃការភ័យខ្លាចកើតមាននៅវត្តកណ្តាលខណៈដែល អ្នកទោសបានដឹងថា អ្នកទោសផ្សេងៗទៀតត្រូវបានធ្វើទារុណកម្ម[259] ហើយភ័យខ្លាចថា អ្នកទោសនឹងប្រឈមមុខនឹងជោគវាសនាដូចៗគ្នា[260]។ ស្ថានភាពរស់នៅគុកគឺ មានលក្ខណៈអមនុស្សធម៌ណាស់។ វ៉ាន់ណាតបានទទួលបបរមួយចានចែកជាមួយអ្នកទោស ៦នាក់ផ្សេងទៀត[261] ហើយមិនអនុញ្ញាតឱ្យផឹកទឹក

ទេ[262]។ អ្នកទោសត្រូវបានដាក់ខ្នោះជើងជាប់[263] ឬចាក់សោរទុកនៅក្នុងឃ្លាំងធ្វើពីឈើ[264]។ អ្នកទោសភាគច្រើនដែលត្រូវនាំទៅកាន់មន្ទីរសន្តិសុខវត្តកណ្តាល មិនដែលបានឃើញត្រឡប់មកវិញទេ [265]។

## មន្ទីរសន្តិសុខវត្តសម្តេច

៦៧. មន្ទីរសន្តិសុខវត្តសម្តេច មានទីតាំងនៅភូមិសម្តេច ឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់ដំបង[266]។ តាមការប៉ាន់ស្មានថា មានប្រជាជនពី ៥,០០០ ទៅ ៦,០០០នាក់ ត្រូវបានសម្លាប់នៅទីនេះ ចាប់ពីឆ្នាំ ១៩៧៧ ដល់១៩៧៨[267]។ រយៈពេលនៃការសម្លាប់ខ្លាំងបំផុតបានកើតឡើង "នៅចុងឆ្នាំ១៩៧៨" (ជារយៈពេលដែល **តាម៉ុត** បានក្លាយជាលេខាតាមព្រឹត្តន័យ ឬតាមនីតិន័យ របស់ភូមិភាគពាយ័ព្យ)[268]។

## មន្ទីរសន្តិសុខវត្តពោធិ៍លង្ការ

៦៨. មន្ទីរសន្តិសុខវត្តពោធិ៍លង្ការ មានទីតាំងនៅភូមិកាច់រទេះ ឃុំកំពុងព្រៀង ស្រុកសង្កែ ខេត្តបាត់ដំបង[269]។ តាមការប៉ាន់ស្មានថា មានប្រជាជនប្រមាណពី ៥,០០០ ទៅ ៧,៥០០ នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខនេះ[270]។ ការសម្លាប់ "បានកើនឡើងយ៉ាងខ្លាំងចាប់ ពីឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៩"[271]។ អតីតទាហានកងចល័តម្នាក់បានឃើញផ្ទាល់ភ្នែកនូវជនរងគ្រោះពេញៗឡានត្រូវបានដឹកពីខាងភូមិភាគបូព៌ាទៅកាន់ទីតាំងនេះរាល់ថ្ងៃ ដែលគ្មាននរណាម្នាក់អាចរស់ជីវិតឡើយ[272]។ នារដូវក្តៅក្នុងឆ្នាំ១៩៧៨ អ្នករស់ជិវិតម្នាក់ពីគុកនេះ បានឃើញផ្ទាល់ភ្នែកនូវការសម្លាប់មនុស្សចំនួន១៤ទៅ១៥នាក់ ដែលត្រូវបានវាយចំក្បាលផ្នែកខាងក្រោយដោយប្រើព្រនង់ឈើ[273]។ អតីតឆ្មាំគុកមួយចំនួននៅមន្ទីរសន្តិសុខនេះត្រូវបានរកឃើញអត្តសញ្ញាណ[274]។

## មន្ទីរសន្តិសុខវត្តបន្ទាយនាង

៦៩. មន្ទីរសន្តិសុខវត្តបន្ទាយនាង មានទីតាំងនៅក្នុងភូមិភ្នំ ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ[275]។ តាមការប៉ាន់ស្មានមានជនរងគ្រោះចំនួនពី ៣,៥០០ ដល់ ៥,០០០នាក់ ត្រូវបានសម្លាប់ចោលនៅទីនេះ[276]។ មានរណ្តៅចំនួនពី ១០០ ទៅ ២០០ រណ្តៅ ដែលរណ្តៅនីមួយៗមានសាកសពចំនួន២០ ទៅ២៥ នៅក្នុងទីតាំងសម្លាប់ទំហំ១ហិកតាចំពីខាងមុខវត្ត[277]។ អ្នកទោសត្រូវបានវាយនឹងបំពង់ទីបព្យួរក ធ្វើឱ្យថប់ដង្ហើមដោយប្រើស្បោងផ្លាស្ទិក និងធ្វើទារុណកម្ម ដោយឆក់ខ្សែភ្លើងដែលតចរន្តចេញពីម៉ាស៊ីនភ្លើងតូចមួយ[278]។ កម្មាភិបាល ភូមិភាគពាយ័ព្យ ដែលត្រូវបានបោសសម្អាតដោយពួកនិរតី ត្រូវបានចាប់ខ្លួន និងនាំទៅកាន់មន្ទីរសន្តិសុខនេះ[279]។

## ទីតាំងសម្លាប់នៅល្អាងភ្នំគួយយំ

៧០. ទីតាំងសម្លាប់នៅល្អាងភ្នំគួយយំ មានទីតាំងនៅខាងក្រោយវិទ្យាល័យអូរប្រាសាទ នៅក្នុងភូមិភ្នំធំ ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ[280]។ តាមការប៉ាន់ស្មានមានប្រជាជនចំនួន៥០០នាក់ ត្រូវបានសម្លាប់នៅទីនេះនៅក្នុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩[281]។ ឧទាហរណ៍ កម្មករវាយយកថ្មចំនួន ១០០នាក់ ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលភូមិភាគនិរតី និងបាននាំយកទៅកាន់ទីតាំងនេះដើម្បីសម្លាប់ចោល[282]។ មានតែពីរបីនាក់ប៉ុណ្ណោះអាចរស់រានមានជីវិត [283]។

## ទីតាំងសម្លាប់នៅវត្តចំការខ្នុរ

៧១. ទីតាំងសម្លាប់នៅវត្តចំការខ្នុរ មានទីតាំងនៅឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ[284]។ វត្តដែលនៅក្បែរទីតាំងសម្លាប់នេះត្រូវបានប្រើជាមន្ទីររបស់កម្មាភិបាលមូលដ្ឋាន[285]។ លលាដ៏ក្បាលជាង៩,០០០ ត្រូវបានរកឃើញនៅទីតាំងនេះ និងត្រូវបានដាក់នៅក្នុងបូជនីយដ្ឋានវត្តសុភមង្គល[286]។ ជនរងគ្រោះភាគច្រើនជាអ្នកតាំងទីលំនៅជនជាតិវៀតណាម[287]។ ជាពិសេស ការសម្លាប់កាន់តែមានលក្ខណៈធ្ងន់ធ្ងរនៅចុងឆ្នាំ១៩៧៨ នៅពេលនោះ ជួនកាល "ឡានមានមនុស្សពេញៗចំនួន៥ ឬ៦" បានមកដល់[288]។ អ្នករស់ជីវិតម្នាក់បានឃើញផ្ទាល់ភ្នែកប្រជាជន "រាប់ពាន់នាក់" "ត្រូវបានចងដាក់ខ្នោះជាប់ និងសែងចេញពីឡានធំៗចំនួន ២០" នៅក្នុងយប់មួយ[289]។ ឡានទាំងអស់នោះបានត្រឡប់ទៅវិញក្នុងល្ងាចនោះ "ដោយដឹកតែសម្លៀកបំពាក់របស់ប្រជាជនប៉ុណ្ណោះ"[290]។

## គុកលេខ៨

៧២. មន្ទីរសន្តិសុខនេះមានទីតាំងនៅភូមិក្បាលឈើពុក ឃុំស្យា ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់[291]។ តាមការប៉ាន់ស្មានមានប្រជាជនចំនួនពី ៥.០០០ ទៅ ១០.០០០ នាក់ ត្រូវបានសម្លាប់នៅក្នុងមន្ទីរសន្តិសុខនេះ[292]។ គុកនេះមានអគារចំនួន៤៖ អគារមួយសម្រាប់កុមារ អគារមួយសម្រាប់ស្ត្រី និងអគារពីរទៀតសម្រាប់បុរស[293]។ អគារទាំងនេះអាចដាក់ អ្នកទោសបាន២៤០នាក់ ហើយជានិច្ចកាលគឺពេញៗតែម្តង[294]។ អ្នកទោសត្រូវដាក់ខ្នោះនៅពេលយប់ ហើយតម្រូវឱ្យធ្វើការរយៈពេល ១១ម៉ោងនៅពេលថ្ងៃ[295]។ ការរំលោភ ការកាត់អវៈយវៈ និងយកថ្លើមមនុស្ស ត្រូវបានអ្នកទោសម្នាក់រស់ជីវិតមើលឃើញផ្ទាល់ភ្នែកទាំងអស់[296]។ អ្នកទោសដែលនៅសេសសល់ត្រូវបានសម្លាប់ចោលនៅពេលយប់មុនពេលវៀតណាមចូលមកដល់នៅក្នុងខែមករា ឆ្នាំ១៩៧៩[297]។

## ទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ

៧៣. ទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ មានទីតាំងនៅក្បែរភូមិព្រីងខ្ពស់ ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ហើយត្រូវបានរៀបរាប់ពីមុននៅក្នុងកថាខណ្ឌទី៦២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម ដែលដាក់ចូលក្នុងសំណុំឯកសារនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧។ តាមការប៉ាន់ស្មានមានប្រជាជនចំនួន ១០.០០០នាក់ ត្រូវបានសម្លាប់នៅទីនេះ ដោយរាប់បញ្ចូល ទាំងមនុស្ស ១.០០០នាក់មកពីភូមិភាគបូព៌ា ដែលគេឱ្យប្រើក្រមាក្រឡាឆ្នូតដើម្បីជាសញ្ញាសម្គាល់ និងបាននាំយកទៅសម្លាប់ចាប់ពីឆ្នាំ១៩៧៧រហូតដល់ឆ្នាំ១៩៧៨[298]។

## មន្ទីរសន្តិសុខភ្នំទ្រយោង

៧៤. មន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានវាយយកថ្មដែលជាប់ពាក់ព័ន្ធមួយកន្លែងមានទីតាំងនៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ (ដែលជាផ្នែកមួយរបស់តំបន់៥ នៃភូមិភាគពាយ័ព្យ)។ តាមការប៉ាន់ស្មានមានប្រជាជនរហូតដល់ទៅ ៤០.០០០នាក់ មានស្លាប់នៅក្នុងទីតាំងនេះចន្លោះឆ្នាំ ១៩៧៧ និងឆ្នាំ១៩៧៩[299]។ មន្ទីរសន្តិសុខភ្នំទ្រយោង ជាគុកថ្នាក់តំបន់សម្រាប់តំបន់៥ និងជាមន្ទីរសន្តិសុខដ៏ធំជាងគេបំផុតនៅក្នុងតំបន់នេះ[300]។ មនុស្សមកពីតំបន់៥ទាំងមូល[301] និង សូម្បីតែអ្នកទោសមកពីតំបន់៣[302] ក៏ត្រូវបានឃុំខ្លួននៅទីនេះដែរ។

៧៥. មន្ទីរសន្តិសុខភ្នំទ្រយោង មានតួនាទីជាកន្លែងអប់រំលត់ដំដល់សមាសភាពក្បត់តាមការចោទប្រកាន់[303] ជាការដ្ឋានធ្វើការដោយបង្ខំ[304] និងជាទីតាំងសម្លាប់មនុស្សដែលត្រូវបានយល់ថាជាខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ[305]។ អ្នកជាប់ឃុំឃាំងទាំងនេះ ដែលត្រូវចាត់ថ្នាក់ថាជាអ្នកប្រព្រឹត្តល្មើសធ្ងន់ធ្ងរត្រូវបង្ខំឱ្យធ្វើការនៅក្នុងការដ្ឋានបំបែកថ្ម និងត្រូវផ្តល់របបអាហារតែបបរមួយវែកប៉ុណ្ណោះក្នុងមួយពេល[306]។ អ្នកដែលមិនធ្វើការឱ្យបានស្វាហាប់នោះទេត្រូវសម្លាប់ចោល[307] ហើយអ្នកខ្លះបានស្លាប់ដោយសារការអត់ឃ្លាន ឬធ្វើការហួសកម្លាំង[308]។ ឈ្លបឃុំ និងកម្មាភិបាលភូមិភាគនិរតីនៅក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** ទទួលខុសត្រូវចំពោះការចាប់ខ្លួនប្រជាជន និងនាំយកប្រជាជនទៅសម្លាប់នៅភ្នំទ្រយោង[309]។ ការសម្លាប់ដែលមានច្រើនរហូតដល់ទៅ១៥នាក់ក្នុងមួយយប់ៗ[310] ត្រូវបានធ្វើឡើងនៅភាគខាងជើងភ្នំទ្រយោង[311]។

## មន្ទីរសន្តិសុខភូមិចក្រី

៧៦. មន្ទីរសន្តិសុខភូមិចក្រី និងទីកន្លែងសម្លាប់នៅក្បែរភូមិតារ៉ូត មានទីតាំងនៅភូមិចក្រី ឃុំជួប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ របាយការណ៍ប៉ាន់ស្មានថា ប្រជាជនច្រើនរហូតដល់ ៦.០០០ នាក់ ត្រូវបានឃុំខ្លួន និងសម្លាប់នៅកន្លែងនោះ[312] ។ ក្នុងអំឡុងមួយសប្តាហ៍ នៅចុងខែមិថុនា ឆ្នាំ១៩៧៨ "មន្ត្រីនារីរបស់ភូមិភាគនិរតី" បាននាំមនុស្សពី ២០ ទៅ ៣០នាក់ ជារៀងរាល់យប់ ទៅកាន់គុកនោះ និងបានសម្លាប់អ្នកទាំងនោះចោល[313] ។ ក្រៅពីនោះ ប្រជាជននៅភូមិចក្រីស្ទើរតែទាំងអស់ ដែលមានចំនួន៤០០នាក់ ត្រូវបានសម្លាប់ក្នុងពេលបោសសម្អាត ដែលធ្វើឡើងនៅទូទាំងស្រុកព្រះនេត្រព្រះ រហូតដល់ចុងខែសីហា ឆ្នាំ១៩៧៨[314] ។ ទាំងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ មានទីតាំងនៅជិតមន្ទីរស្រុកព្រះនេត្រព្រះ ហើយហាក់ដូចជាថា មន្ទីរសន្តិសុខនេះជាគុកថ្នាក់ស្រុក សម្រាប់ស្រុកព្រះនេត្រព្រះ[315] ។

## វត្តព្រះនេត្រព្រះ និងចំការតាឡឹង

៧៧. ដោយមានមន្ទីរពេទ្យមួយ និងទីតាំងសម្លាប់ជាប់គ្នានោះនៅចំការតាឡឹង វត្តព្រះនេត្រព្រះ រួមមានទីតាំងរណ្តៅសាកសពចំនួន៦ ដែលត្រូវបានគាស់រួច[316] ។ ការប៉ាន់ស្មានដំបូងៗពីរណ្តៅសាកសព បានឱ្យដឹងថា មានប្រជាជនប្រមាណជា៧០០នាក់ ត្រូវបានសម្លាប់នៅទីនេះ ទោះជាសាកសពខ្លះ អាចត្រូវបានដុតនៅក្នុងទីតាំងទាំងពីរនេះក៏ដោយ[317] ។ សាក្សីម្នាក់បានបញ្ជាក់ថា "គណៈឃុំរបស់ប៉ុល ពត" បានប្រើប្រាស់ផ្ទះមួយនៅក្បែរវត្តព្រះនេត្រព្រះ និងថា អ្នកទោសត្រូវបានគេឃុំនៅក្នុងផ្ទះនោះ មុនពេលត្រូវបាននាំយកទៅសម្លាប់ចោលនៅចំការតាឡឹង[318] ។ មានរបាយការណ៍មួយបានកំណត់អត្តសញ្ញាណនៃអដ្ឋិធាតុទាំងនោះថាភាគច្រើនជាអដ្ឋិធាតុរបស់មនុស្សប្រុសពេញវ័យ មានអាយុក្រោម៤៥ឆ្នាំ ដែលតាមទំនងបំផុតនោះគឺជាអ្នកជម្លៀសមកពីភ្នំពេញ[319] ។

**ទំនប់ត្រពាំងថ្ម**

៧៨. ទំនប់ត្រពាំងថ្មមានទីតាំងនៅក្នុងភូមិត្រពាំងថ្មខាងជើង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ អង្គហេតុមួយចំនួនដែលទាក់ទងទៅនឹងទីតាំងធ្វើការដោយបង្ខំនៅទំនប់ត្រពាំងថ្ម មានចែងនៅក្នុងកថាខណ្ឌទី៤៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧[320] ។ ក្នុងតួនាទីជាលេខាស្រុក **អ៊ឹម ចែម** ទទួលស្គាល់ថា គាត់បានមើលការខុសត្រូវលើមនុស្សរាប់រយនាក់មកពីស្រុកព្រះនេត្រព្រះ ដែលពួកគេត្រូវបានបង្ខំឱ្យធ្វើការនៅតាមវាលស្រែ ក្បែរទំនប់ត្រពាំងថ្មនោះ[321] ។ ការងារនៅពេលថ្ងៃ មានរយៈពេលវែងយ៉ាងខ្លាំង ហើយកម្មករធ្វើការដោយបង្ខំទាំងអស់នោះមានពេលសម្រាកតិចតួចណាស់[322] ។ របបអាហារ គឺបបរមួយចានក្នុងមួយថ្ងៃ[323] ។

**ស្ពានស្រែង និងទំនប់ព្រៃរនាម**

៧៩. នៅក្នុងឆ្នាំ១៩៧៨ មនុស្សចំនួន១.៣០០នាក់ ត្រូវបានដាក់ពង្រាយនៅតាមការដ្ឋានធ្វើការបង្ខំនៅស្ពានស្រែង និងការដ្ឋានសាងសង់ទំនប់ព្រៃរនាម នៅក្នុងស្រុកព្រះនេត្រព្រះ (តំបន់៥ របស់ភូមិភាគពាយ័ព្យ)[324] ។ ការកសាងទំនប់ស្ពានស្រែង ប្រវែង៨គីឡូម៉ែត្រ ត្រូវបានធ្វើឡើងដោយដៃសុទ្ធសាធ និង បានបញ្ចប់ក្នុងរយៈពេលបីខែ[325] ។ ពលករដោយបង្ខំទាំងអស់ដែលធ្វើការនៅការដ្ឋានសាងសង់ត្រូវផ្លាក់ខ្លួនឈឺ[326] កង្វះអាហារ[327] និងគ្មានសម្លៀកបំពាក់ត្រឹមត្រូវ[328] ។ ការគំរាមសម្លាប់ត្រូវបានធ្វើឡើងតាមទម្លាប់ចំពោះកំហុសតួចតាច[329] ហើយកម្មករទាំងអស់នោះត្រូវទទួលរងការចាប់ខ្លួន និងការសម្លាប់[330] ។

**ភូមិភាគនិរតី**

**មន្ទីរសន្តិសុខវត្តប្រធាតុ**

៨០. មន្ទីរសន្តិសុខវត្តប្រធាតុ មានទីតាំងនៅក្នុងភូមិក្បាលដំរី ឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ (ដែលជាផ្នែកមួយរបស់តំបន់១៣នៃភូមិភាគនិរតី)[331] ។ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ រណ្ដៅសាកសពចំនួនពី២០០ ទៅ ៣០០កន្លែង ត្រូវបានរកឃើញនៅក្បែរនោះ[332] ហើយតាមការប៉ាន់ស្មានថា មានប្រជាជនចំនួនរហូតដល់១៦.០០០នាក់ ត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខនេះ[333]។ វត្តប្រធាតុ ជាគុកស្រុក នៅក្នុងអំឡុងពេលដែល **តា ទិត** ធ្វើជាលេខាស្រុកគីរីវង់[334] ។ កំណត់ហេតុសួរចម្លើយជាលាយលក្ខណ៍អក្សរនានា ត្រូវបានរៀបចំ និងផ្ញើទៅឱ្យគណៈស្រុកគីរីវង់ (ដោយរាប់បញ្ចូលទាំង **តាទិត** ដែរ) ដែលត្រូវពិនិត្យលើកំណត់ហេតុសួរចម្លើយទាំងអស់នោះ និងសម្រេចថាតើ

អ្នកទោសណាត្រូវដោះលែង និងណាមួយត្រូវសម្លាប់ចោល[335] ។ ជាទូទៅ ការសម្លាប់ត្រូវបានគេធ្វើឡើងក្នុងមួយសប្តាហ៍ម្តង ក្នុងលក្ខណៈជាក្រុម ដែលមានមនុស្សពី៥០ ទៅ ១៥០នាក់ ព្រមទាំងមានស្ត្រី និងកុមារផងដែរ[336] ។

៨១. សាលាធាន់ ត្រូវបានប្រើប្រាស់ជាទីកន្លែងឃុំឃាំង និងមានខ្នោះបីជួរ ដែលក្នុងមួយជួរអាចដាក់មនុស្សបាន៥០នាក់[337] ។ អ្នកទោសត្រូវបានដាក់ខ្នោះជើងភ្ជាប់ទៅនឹងរនុកដែកកណ្តាលមួយ ហើយដៃម្ខាងរបស់អ្នកទោសត្រូវបានដាក់ខ្នោះជាប់ជាមួយអ្នកទោសម្នាក់ផ្សេងទៀត[338] ។ អ្នកទោសត្រូវទទួលរងនូវការធ្វើទារុណកម្ម រាប់បញ្ចូលទាំងការធ្វើឱ្យថប់ដង្ហើមដោយប្រើថង់ផ្លាស្ទិក ហើយគេអាចឮ "សម្រែកដូចសត្វធាតុ"[339] ។ អ្នកទោសខ្លះបានស្លាប់ក្នុងពេលធ្វើទារុណកម្មបែបនេះ និង ជាច្រើនទៀតបានស្លាប់ដោយសារអត់អាហារ ឬជំងឺផ្សេងៗ[340]។ នៅពេលអ្នកទោសត្រូវបាននាំយកទៅសម្លាប់អ្នកទាំងនោះមានសភាពស្គមស្គាំងយ៉ាងខ្លាំងស្ទើរតែដើរមិនរួច[341]។ លើសពីនេះទៀត អ្នកទោសត្រូវបានគេធ្វើឱ្យទៅជាពិការអវៈយវៈ ហើយប្រម៉ាត់ឬលំពែងរបស់អ្នកទោសត្រូវបានគេកាត់យកទាំងរស់[342] ។ សមាជិកគណៈស្រុកនៅក្រោម **តាទិត** ដែលមានបុរសម្នាក់ឈ្មោះ តុំ និងនារីម្នាក់ ឈ្មោះបូ បានមកកាន់វត្តប្រធាតុនេះ ដើម្បីប្រមូលយកប្រម៉ាត់ "រាប់រយ" ហើយ **តាទិត** ខ្លួនឯងផ្ទាល់ក៏ធ្លាប់មកម្តងម្កាលដែរ[343] ។

## ជនសង្ស័យ

## តាអាន

## ប្រវត្តិរូបផ្ទាល់ខ្លួន

៨២. **តាអាន** ជាអតីតសង្ឃមួយអង្គ[344] ដែលមានដើមកំណើតនៅភូមិកំពុងត្រឡាចលើ ក្នុងស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង ដែលជាតំបន់មូលដ្ឋានប្រវត្តិសាស្ត្រនៃចលនាកុម្មុយនីស្តកម្ពុជា[345] ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ក្នុងពេលមានសង្គ្រាមរវាងបក្សកុម្មុយនីស្តកម្ពុជា និង របបសាធារណរដ្ឋខ្មែរ **តាអាន** បានទទួលខុសត្រូវ នៅក្នុងស្រុកកណ្តាលស្ទឹងរបស់តំបន់១៥ ដែលជាមន្ទីរពិសេសរបស់បក្សកុម្មុយនីស្តកម្ពុជា[346] ។ ជាងនេះទៀត អតីតសង្ឃអង្គនេះ ដែលត្រូវបានហៅថា "អាចារ្យអាន" (ដែលអាចជា **តា អាន**) ត្រូវបានកំណត់អត្តសញ្ញាណថា ជាស្ថាតិកម្នាក់នៃគុកក្រាំងតាចាន់នៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ នៅចុងឆ្នាំ ១៩៧៣ ដែលគុកនេះបានក្លាយទៅជាគុកដ៏ឃោរឃៅបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាទីតាំងឧក្រិដ្ឋកម្មមួយដែលបានកំណត់អត្តសញ្ញាណនៅក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ (នៅកថាខណ្ឌ៦០)[347] ។

៨៣. បានជឿថា បច្ចុប្បន្ននេះ **តា អាន** កំពុងរស់នៅក្នុងភូមិអូដារ ស្រុកកំរៀង ខេត្តបាត់ដំបង[348] ។

## សិទ្ធិអំណាច

៨៤. នៅពេលចាប់ផ្ដើមរបបកម្ពុជាប្រជាធិបតេយ្យ **តា អាន** ស្ថិតនៅក្នុងភូមិភាគនិរតី ។ គាត់ទទួលខុសត្រូវផ្នែកយោធានៃតំបន់២៥ (ដែលរាប់បញ្ចូលទាំងស្រុកកណ្ដាលស្ទឹង)[349] ហើយនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៦ គាត់បានក្លាយជាសមាជិកគណៈអចិន្ត្រៃយ៍តំបន់៣៥ ដែលជាការទទួលខុសត្រូវដ៏សំខាន់មួយរបស់គាត់ គឺត្រូវបញ្ចប់ទំនប់កោះស្លា នៅត្រឹមដំណាច់ឆ្នាំ[350] ។ នៅខែមីនា ឆ្នាំ១៩៧៦ **តា អាន** ត្រូវបានជ្រើសតាំងដោយប្រើឈ្មោះថា "ចូ អាន" ឱ្យធ្វើជាតំណាងកសិករភូមិភាគនិរតី នៅក្នុងសភាតំណាងប្រជាជន[351] ។

៨៥. នៅដើមឆ្នាំ១៩៧៧ **តា អាន** បានដឹកនាំកម្មាភិបាលភូមិភាគនិរតីមួយក្រុម ដែលបានធ្វើដំណើរទៅកាន់ភូមិភាគកណ្ដាល (ភូមិភាគឧត្ដរចាស់) និងបានចាប់ផ្ដើមការបោសសម្អាតយ៉ាងម៉ត់ចត់បំផុតទៅលើកម្មាភិបាលនៅទីនោះ ដោយចាប់ផ្ដើមពីថ្នាក់ភូមិភាគ និងតំបន់ រហូតដល់ថ្នាក់ឃុំទៀតផង[352] ។ កម្មាភិបាលដ៏គួរឱ្យកត់សម្គាល់តែម្នាក់ ដែលគេចផុតពីការបោសសម្អាតនៅភូមិភាគកណ្ដាលនោះ គឺជាលេខាភូមិភាគ ឈ្មោះ កែ ពក[353] ។ **តា អាន** បានកាន់តំណែងជាលេខាតំបន់៤១[354] និងជាសមាជិកគណៈភូមិភាគកណ្ដាល[355] ។ កង ចាប ហៅ សែ អាចបានធ្វើជាអនុលេខាគណៈភូមិភាគមួយរយៈពេលខ្លីដែរ[356] ។ ក៏ប៉ុន្តែ នៅត្រឹមដំណាច់ខែមីនា ឬដើមខែមេសា ឆ្នាំ១៩៧៧ កង ចាប ហៅ សែ បានក្លាយជាលេខា ភូមិភាគឧត្ដរថ្មី[357] ហើយ **តា អាន** បានក្លាយជាអនុលេខាភូមិភាគកណ្ដាល[358] ។

៨៦. ចាប់តាំងពីពេលនោះមក រហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ **តា អាន** គឺជាសមាជិកមានឋានៈខ្ពស់បំផុតលំដាប់ទីពីររបស់បក្សកុម្មុយនីស្តកម្ពុជា នៅភូមិភាគកណ្ដាល ហើយទំនងជាធ្លាប់បានបម្រើការជា លេខាភូមិភាគតាមជាក់ស្ដែង ក្នុងអំឡុងដែល កែ ពក បាន អវត្តមានក្នុងរយៈពេលយូរពីភូមិភាគកណ្ដាល[359] ។ ក្នុងនាមជាអនុលេខាភូមិភាគ **តា អាន** ប្រហែលជាធ្លាប់ជា សមាជិកគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងមហាសន្និបាតបក្សលើកទី៥ ដែលគណៈ កម្មាធិការនេះរួមមាន "លេខា និងអនុលេខាតំបន់ លេខា និងអនុលេខាភូមិភាគ"[360] ។

៨៧. នៅក្នុងមុខតំណែងជាអនុលេខា **តា អាន** ទទួលខុសត្រូវខាងសន្តិសុខនៅភូមិភាគកណ្តាល ហើយមាន "សិទ្ធិអំណាចទៅលើកិច្ចការស៊ីវិល និងយោធា"[361] ។ ដូច្នេះ **តា អាន** មានការទទួលខុសត្រូវផ្ទាល់ទៅលើមន្ទីរសន្តិសុខចំនួន២៥ នៅក្នុងភូមិភាគកណ្តាលនេះ[362] ។ កម្មាភិបាលនៅមន្ទីរសន្តិសុខទាំងអស់នោះបានរាយការណ៍តាមរយៈខ្សែសង្វាក់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលទៅឱ្យ **តា អាន**[363] ។ **តា អាន** មានសិទ្ធិ និងអំណាច (ក) ក្នុងការផ្តល់បទបញ្ជាទៅឱ្យអ្នកក្រោមបង្គាប់ទាំងអស់ ដែលអ្នកទាំងនោះត្រូវមានកាតព្វកិច្ចគោរពតាម និង (ខ) ផ្តន្ទាទោស ដាក់វិន័យ ផ្អាក ឬដកអ្នកក្រោមបង្គាប់ចេញពីមុខតំណែង ប្រសិនបើអ្នកនោះ មានជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិណាមួយដែលគាត់ (**តា អាន**) មិនបានអនុញ្ញាត ឬ យល់ព្រម ។ ក្នុងនាមជាសមាជិកគណៈភូមិភាគ **តា អាន** ក៏មានសិទ្ធិអំណាចក្នុងការ "កម្ទេចទាំងក្នុង និងក្រៅជួរ"[364] ។ ជាលទ្ធផលពីសិទ្ធិអំណាចនេះ **តា អាន** បានប្រើប្រាស់លើការត្រួតត្រាយ៉ាងមានប្រសិទ្ធិភាព ទៅលើបុគ្គលទាំងឡាយនៅមន្ទីរសន្តិសុខ និងទីតាំងឧក្រិដ្ឋកម្មផ្សេងៗទៀតដោយបានចូលរួមនៅក្នុងអំពើឧក្រិដ្ឋកម្ម ដូចដែលមានចែងនៅក្នុងកថាខណ្ឌទី១៨ ដល់កថាខណ្ឌទី៥៣ និងមានសិទ្ធិអំណាចក្នុងការសម្រេចថា តើមនុស្សណាម្នាក់នៅទីតាំងទាំងនោះ ត្រូវយកទៅ "កម្ទេច" ឬ សម្លាប់ចោល ។

៨៨. តំបន់ដែល**តា អាន** ត្រួតត្រាក្នុងនាមជាលេខាតំបន់៤១ រួមមាន ស្រុកព្រៃឈរ កងមាស កំពង់សៀម ជើងព្រៃ និងបាធាយ ក្នុងខេត្តកំពង់ចាម[365] ។ ក្នុងនាមជាអនុលេខាភូមិភាគកណ្តាល **តា អាន** ក៏មានសិទ្ធិអំណាចទៅលើតំបន់៤២ ដែរ (ដែលរួមមានស្រុកស្ទឹងត្រង់ និងចំការលើ ក្នុងខេត្តកំពង់ចាម, ស្រុកបារាយ ក្នុងខេត្តកំពង់ធំ និងស្រុកព្រែកប្រសព្វ ក្នុងខេត្តក្រចេះ) និងតំបន់៤៣ (ដែលរួមមានស្រុកសន្ទុក សណ្តាន់ ប្រាសាទសំបូរណ៍ ប្រាសាទបល្ល័ង្ក ស្ទោង និងស្ទឹងសែន ឬទីរួមខេត្តកំពង់ធំ ខេត្តកំពង់ធំ)[366] ។ មន្ទីរធំរបស់ **តា អាន** នាសម័យនោះស្ថិតនៅក្នុងភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដែលមានទីតាំងនៅចំពីខាងក្រោយការិយាល័យស្រុកសព្វថ្ងៃ[367] ។

៨៩. **តា អាន** ត្រូវបានគេពិពណ៌នាថាជា "មេដឹកនាំជាន់ខ្ពស់" (ដែលបានពិពណ៌នាដោយប្រធានសន្តិសុខរបស់ ភូមិភាគកណ្តាល)[368], និងថាជា "អង្គការលើ"[369] និងជាមេដឹកនាំម្នាក់ក្នុងចំណោម "មេដឹកនាំថ្នាក់តំបន់ ពីរបីនាក់...." ដែលរស់រានមានជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យ[370] ។ តួនាទីរបស់គាត់ជាមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យក៏ត្រូវបានបញ្ជាក់អះអាងដែរថា បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ **តា អាន** នៅតែជាកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់បំផុត ។ ខ្មែរក្រហម បានដកថយទៅកាន់ជួរភ្នំដងរែកនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ហើយបានបង្កើតតំបន់មួយដែលត្រូវបានស្គាល់ថាជា តំបន់១០០១ ឬភ្នំ១០០១ ដែលចែកចេញជាបីភូមិភាគ ។ **តា អាន** ទទួលខុសត្រូវលើភូមិភាគមួយក្នុងចំណោម

ភូមិភាគទាំងបីនេះ ដែលដាក់តាមឈ្មោះគាត់តែម្តង (ភូមិភាគ តា អាន)[371]។ ក្នុងអំឡុងពេលនោះ អាន រស់នៅក្នុង "ភូមិ តា អាន"[372] ។

## ការចូលរួម និងការដឹងឮ

៩០. តាមរយៈមុខតំណែងថ្នាក់ដឹកនាំរបស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងភូមិភាគកណ្តាល **តា អាន** បានរៀបចំផែនការ បានជម្រុញ បានញុះញង់ បានជួយសម្រួល បានជួយនិងជម្រុញ បានលើកទឹកចិត្ត បានបណ្តែតបណ្តោយ និង/ឬ បានចេញបញ្ជាឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចដែលមានចែងនៅក្នុងកថាខណ្ឌទី១៨ ដល់កថាខណ្ឌទី៥៣ ។ ការចូលរួម និងការដឹងឮរបស់ **តា អាន** អំពីឧក្រិដ្ឋកម្មជាក់លាក់ទាំងអស់នេះត្រូវបានផ្តល់ភ័ស្តុតាងដូចខាងក្រោមនេះ៖

ក. ការបោសសម្អាតនៅភូមិភាគកណ្តាល (ដូចមានពិភាក្សាលម្អិតនៅក្នុងកថាខណ្ឌទី១៨ ដល់ទីកថាខណ្ឌទី ២២) ត្រូវបានរៀបចំគម្រោងដោយ **តា អាន** និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងបានអនុវត្តដោយ **តា អាន** និងកម្មាភិបាលភូមិភាគនិរតី ដែលបានមកកាន់ភូមិភាគកណ្តាលជាមួយគាត់ និងដែលស្ថិតនៅ ក្រោមបញ្ជារបស់គាត់[373] ។ **តា អាន** បានសារភាពថា គាត់បានដឹងអំពីការសម្លាប់កម្មាភិបាលភូមិភាគកណ្តាល និង យល់ព្រមឱ្យមានការបោសសម្អាតដោយប្រាប់អ្នកភូមិនៅមូលដ្ឋាននៅក្នុងសន្ទរកថាមួយនៅវត្តអូរត្រកួនថា អ្នកភូមិមិនត្រូវភ័យខ្លាចពីរឿង "ចាប់ខ្លួន និងសម្លាប់កម្មាភិបាលមុនៗនោះទេ" ដោយសារតែពួកកម្មាភិបាលទាំងអស់នោះ "មិនស្មោះត្រង់នឹងអង្គការ និងបដិវត្តន៍" និងត្រូវតែ "កម្ទេច"[374] ។

ខ. ការសម្លាប់ប្រជាជនថ្មី និងប្រជាជនដែល "មានខ្សែសង្គមចាស់" ត្រូវបានរៀបផែនការ បានញុះញង់ និងបានបញ្ជាដោយ **តា អាន** ។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ **តា អាន** បានប្រាប់អនុលេខាតំបន់៤៣ និងប្រធានស្រុកស្ទោង ថាគាត់នឹងកម្ទេចប្រជាជនណាដែល "មានកំហុសសូម្បីតែតិចតួចបំផុតក៏ដោយ" និងសម្លាប់សមាសភាពសង្គមចាស់ទាំងអស់ (ដោយរាប់ចាប់ពីអតីតមេដប់ខ្ទង់ឡើងទៅ) "ដើម្បីពួកវា ងើបក្បាលរួច"[375] ។ សាក្សីមកពីស្រុកដែល **តា អាន** ធ្លាប់រស់នៅ បានអះអាងថា បន្ទាប់ពីការមកដល់ របស់ **តា អាន** ព្រមទាំងកម្មាភិបាលភូមិភាគនិរតីនៅក្នុងឆ្នាំ១៩៧៧ អ្នកដែល "ជាប់ពាក់ព័ន្ធនឹងសង្គមចាស់" ត្រូវនាំយកទៅសម្លាប់ចោល[376] ។ របៀបរបបនៃការចាប់ខ្លួន និងបាត់ខ្លួនដដែលៗ ដែលត្រូវបានគេមើលឃើញនៅទូទាំងភូមិភាគកណ្តាល បន្ទាប់ពីការមកដល់របស់ **តា អាន** និងកម្មាភិបាលភូមិភាគនិរតី (ដូចមានសរសេរលម្អិតនៅក្នុងកថាខណ្ឌទី២២ និងលេខយោងទី៤១ និងទី៤៣) កំណត់បានថា នេះជាកិច្ចខិតខំប្រឹងប្រែងដែលបានរៀបចំ

និងធ្វើផែនការឡើងដោយ **តា អាន** និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗទៀត និងបានអនុវត្តដោយ **តា អាន** និងកម្មាភិបាលរបស់គាត់មកពីភូមិភាគនិរតី ។ កែ ពក ខ្លួនឯងផ្ទាល់ធ្លាប់បានស្តីបន្ទោសដល់ "កម្មាភិបាលមិនល្អមកពីភូមិភាគនិរតី" ចំពោះការរំលោភបំពាន និងការសម្លាប់ដែលធ្វើឡើងនៅក្នុងភូមិភាគកណ្តាលនៅក្នុងអំឡុងពេលនោះ[377] ។

គ. **តា អាន** ក៏បានរៀបចំផែនការ និងចេញបញ្ជាឱ្យមានការចាប់ខ្លួន និងសម្លាប់ទ្រង់ទ្រាយធំ ទៅលើប្រជាជនចាមផងដែរ ។ នៅក្នុងខែសីហា ឆ្នាំ១៩៧៧ **តា អាន** បានបញ្ជាឱ្យប្រធានអង្គភាព និងឃុំស្វែងរកកំណត់អត្តសញ្ញាណ និងប្រមូលជនជាតិចាមដែលនៅសេសសល់ និងយកអ្នកទាំងនោះទៅកាន់មូលដ្ឋានរបស់ពួកគេ[378] ។ ដប់ថ្ងៃក្រោយមក ភូមិចាម នៅក្នុងស្រុកកងមាស ត្រូវអស់មនុស្សរលីង ហើយប្រជាជនចាមនៅសេសសល់ដែលរស់នៅទីនោះ ត្រូវបាននាំទៅកាន់គុកវត្តអូរត្រកួន និងសម្លាប់ចោល[379] ។ គិតមកដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ អ្នករស់ជីវិតជាជនជាតិចាម មានចំនួនតែបន្តិចបន្តួចប៉ុណ្ណោះដែលនៅសេសសល់ នៅក្នុងស្រុកកងមាស និងតំបន់ផ្សេងៗទៀត ក្នុងខេត្តកំពង់ចាម ដែលធ្លាប់តែមានសហគមន៍ចាមដ៏ធំនោះ[380] ។

ឃ. ក្នុងអំឡុងពេលចុះទៅកាន់វត្តអូត្រកួនម្តងនោះ **តា អាន** បានរៀបចំផែនកា បានជួយនិងជម្រុញនិងបានចូលរួមនៅក្នុងគំរោងមួយ ដើម្បីកំណត់អត្តសញ្ញាណ និងលប់បំបាត់ចោលមនុស្សទាំងឡាយ ដែលមិនសប្បាយចិត្តជាមួយរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលជាខ្មាំងស៊ីរូងផ្ទៃក្នុងសំខាន់ៗផ្សេងទៀត ។ នៅក្នុងឱកាសនេះដែរ **តា អាន** បានផ្តល់បទឧទ្ទេសនាមមួយ ដែលនៅក្នុងនោះគាត់បានប្រកាសថា ប្រជាជនគួរ "រាយការណ៍ទៅឱ្យប្រធានស្រុក" ប្រសិនបើ ប្រធានអង្គភាពរបស់ខ្លួនមិនព្រមគោរពតាម "គោលនយោបាយផ្តល់អាហារឱ្យប្រជាជនបីពេលក្នុងមួយថ្ងៃ" ហើយ "ប្រជាជនគ្មានអាហារហូបចុកគ្រប់គ្រាន់ទេនោះ"[381] ។ អ្នកភូមិមូលដ្ឋានទាំងអស់ដែលហ៊ានរាយការណ៍ដូច្នេះ ត្រូវបានគេ "ដឹកតាមរទេះសេះ" យកទៅសម្លាប់ចោល[382] ។

ង. **តា អាន** បានរៀបចំផែនការ បានបញ្ជា និងបានយល់ព្រមឱ្យមានការចាប់ខ្លួន និងដាក់ឱ្យជាប់ឃុំឃាំងចំពោះមនុស្សនៅក្នុងតំបន់៤១ និងភូមិភាគកណ្តាល ។ ឧទាហរណ៍ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨ ប្រធានភូមិភាគកណ្តាល ឈ្មោះ កែ ពក បានផ្ញើសារទូរលេខមួយច្បាប់ ទៅឱ្យមន្ទីរ៨៧០ ដោយផ្តល់យោបល់ថា យោធាមកពីតំបន់៤១ បានចាប់យោធាពីរនាក់ ដែលគេអះអាងថាស្ថិតនៅក្នុងអង្គភាពទ័ពអាកាស៥១២[383] ។ សារទូរលេខនិយាយយោងទៅលើ "លិខិតច្បាប់ដើម" ដែលថា "សមមិត្តអាន នៅក្នុងតំបន់៤១" បានផ្ញើជូនអង្គការស្តីពីបញ្ហានេះ ។ សារទូរលេខនេះឱ្យសួរទៅ ស៊ូ ម៉េត (ដែលជាលេខាកងពល៥០២ រាប់បញ្ចូលទាំងកងទ័ពអាកាស របស់កម្ពុជាប្រជាធិបតេយ្យ

ផង) ថាតើឃោធាដែលត្រូវបានចាប់ខ្លួននោះស្ថិតនៅក្នុងអង្គភាពរបស់គាត់មែនឬទេ ហើយបានបញ្ជាប់ថា៖ “ប្រសិនបើមែន សូមទាក់ទងទៅសមមិត្តអាន នៅក្នុងតំបន់៤១ ហើយទទួលយកឃោធាទាំងអស់នោះទៅវិញចុះ ប៉ុន្តែប្រសិនបើមិនមែនទេ សូមឱ្យយើងដឹងផង”[384] ។ ឯកសារនេះអះអាងបញ្ជាក់ថា **តា អាន** បានជាប់ពាក់ព័ន្ធផ្ទាល់ ជាមួយនឹងការចាប់ខ្លួនអ្នកទោសនៅក្នុងតំបន់៤១ និងការសម្រេចលើជោគវាសនារបស់អ្នកទោសនោះ ។ នៅក្នុងករណីផ្សេងៗទៀត ប្រជាជនជាច្រើនក្រុម ត្រូវបានចាប់ខ្លួននៅក្នុងស្រុកមួយរបស់តំបន់៤១ និងបន្ទាប់មក ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ដែលស្ថិតនៅក្នុងស្រុកផ្សេងៗទៀត[385] ។ ការចល័តអ្នកទោស ពីស្រុកមួយទៅស្រុកមួយនៅក្នុងតំបន់៤១ នឹងមិនអាចធ្វើទៅបានឡើយ ប្រសិនបើគ្មានផែនការ ការដឹងឮ ការយល់ព្រម និងការចូលរួមនៃមន្ទីរតំបន់របស់ **តា អាន** ទេនោះ ។

ច. **តា អាន** បានចុះទៅពិនិត្យការដ្ឋានធ្វើការ មន្ទីរសន្តិសុខ និងសហករណ៍ជាប្រចាំនៅក្នុងតំបន់របស់គាត់ ដោយរាប់បញ្ចូលទាំងការដ្ឋាន ដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តដែរ[386] ។ **តា អាន** បានចុះទៅវត្តអូរត្រកួន[387] វត្តតាមាគ (មន្ទីរឃុំឃាំងបណ្ដោះអាសន្ន)[388] ការដ្ឋានទំនប់អន្លង់ជ្រៃ[389] ការដ្ឋានព្រីងជ្រំ[390] និងស្ថានីយទឹកកំពង់កែក នៅក្នុងភូមិក្តីបឹង[391] ។ ក្នុងពេលចុះទៅពិនិត្យទាំងអស់នេះ **អាន** ប្រហែលជាធ្លាប់បានជួប និងដឹកនាំកម្មាភិបាលមូលដ្ឋាន ដែលជាអ្នកក្រោមបង្គាប់គាត់ និងបានផ្តល់បទឧទ្ទេសនាមជាសាធារណលើកទឹកចិត្តឱ្យប្រជាជនខំប្រឹងធ្វើការឲ្យកាន់តែខ្លាំងក្លាថែមទៀត ដើម្បីឆ្លើយតប និងគោរពទៅតាម សារាចរណែនាំ និងជួយកំណត់អត្តសញ្ញាណ និងកម្ទេចអ្នកមិនស្មោះត្រង់ និងដែលជាខ្មាំងរបស់ របបនោះ[392] ។ ក្នុងពេលចុះទៅពិនិត្យទាំងអស់នោះ **តា អាន** ប្រហែលជាអាចអង្កេតឃើញពីស្ថានភាពរបស់ការដ្ឋានទាំងអស់នេះ ដោយរាប់ទាំងស្ថានភាពរបស់អ្នកទោស និងកម្មករដែលរស់នៅទីនោះ និងប្រសិទ្ធិភាពនៃគោលនយោបាយ ព្រមទាំងសារាចរដែលគាត់បាននិងកំពុងដាក់ចេញឱ្យអនុវត្តក្នុងឋានៈគាត់ជាលេខាតំបន់ និងអនុលេខាភូមិភាគ ។

ឆ. ប្រពន្ធ **តា អាន** ឈ្មោះសមមិត្តកាន ក៏បានចុះទៅពិនិត្យមើលការដ្ឋាន សហករណ៍ និងភូមិនៅតាមតំបន់ផ្សេងៗក្នុងស្រុកព្រៃឈរ[393] យ៉ាងទៀងទាត់ផងដែរ ។ សាក្សីខ្លះបានបញ្ជាក់ថា កានអាចមានមុខនាទីផ្លូវការណាមួយជាអនុ របស់ អាន ជាប្រធានស្រុក ឬជាប្រធានឃុំ[394] ។ កានត្រូវបានគេប្រទះឃើញ “នៅគ្រប់ទីកន្លែង” និងបានបង្កការភ័យខ្លាចយ៉ាងខ្លាំង ដោយសារថាបើមានប្រជាជនណាម្នាក់ត្រូវបានគាត់បានចង្អុរដាក់ក្នុងពេលគាត់ចុះទៅពិនិត្យនោះ អ្នកនោះនឹងត្រូវបាត់ខ្លួនជារឿយៗជាមិនខាននៅពេលក្រោយៗមក[395] ។

## តា ទិត
## ប្រវត្តិរូបផ្ទាល់ខ្លួន

៩១. **តា ទិត** (ហៅ តា ទិត ហៅ យឹម ទិត ហៅ តា១៧) ជាមនុស្សមកពីស្រុកត្រាំកក់ ខេត្តតាកែវ ដែលជាស្រុកកំណើតរបស់តា ម៉ុក ហើយក៏ជាកន្លែងដែលត្រូវបានប្រកាសថាជា ស្រុកគំរូមួយ នៅក្នុងចំណោម "ស្រុកគំរូចំនួនបី" និងហៅថាជា "ផ្នែកសំខាន់" របស់ "ភូមិភាគប៉ុល ពត" និងជា "គំរូគោល" របស់សង្គមកម្ពុជាប្រជាធិបតេយ្យ[396] ។ តា ម៉ុក ជាលេខាភូមិភាគនិរតី និងជាសមាជិករបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជានៅក្នុងអំឡុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ[397] ។ **តា ទិត** ជាប្អូនថ្លៃរបស់តា ម៉ុក ដោយបានរៀបការជាមួយ ប្អូនស្រីពៅ របស់ តាម៉ុក ឈ្មោះ កែន[398] ។ ក្នុងនាមជាសមាជិកគ្រួសាររបស់ តា ម៉ុក **តា ទិត** ត្រូវបានប្រគល់ឱ្យនូវតួនាទីសំខាន់ៗនៅក្នុងអង្គការបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគនិរតី និង "បានឡើងឋានៈយ៉ាងរហ័ស"[399] ។

៩២. សព្វថ្ងៃនេះ **តា ទិត** ជាអ្នកជំនួញមានទ្រព្យសម្បត្តិម្នាក់រស់នៅក្នុងទីក្រុងភ្នំពេញ[400] ។

### សិទ្ធិអំណាច

៩៣. **តា ទិត** ជាលេខាស្រុកគីរីវង់ (ស្រុក១០៩) នៅក្នុងខេត្តតាកែវ ដែលជាផ្នែកមួយរបស់តំបន់១៣ ភូមិភាគនិរតី ចាប់ពីឆ្នាំ១៩៧៦ រហូតដល់ចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨[401] ។ យោងតាមសម្តីប្រធានឃុំ ម្នាក់ក្នុងចំណោមប្រធានឃុំដទៃទៀតនៅក្នុងស្រុកនោះ **តា ទិត** បានទទួលមុខតំណែងនេះដោយសារតែលេខាស្រុកមុន "បានការពារមនុស្សជាច្រើន ដូច្នេះហើយ លេខាស្រុកមុននោះត្រូវបានដកចេញ ហើយបានជំនួសវិញដោយ **ទិត** ដែលជាបងថ្លៃរបស់ តា ម៉ុក"[402] ។

៩៤. នៅពាក់កណ្តាលឆ្នាំ១៩៧៧ តា ម៉ុក **តា ទិត** និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត របស់បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំផែនការនិងបានផ្តួចផ្តើមឱ្យមានការបោសសម្អាតយ៉ាងរង្គាលមួយនៅក្នុងភូមិភាគពាយ័ព្យ ដែលចាប់ផ្តើមនៅពេលមានការមកដល់ នូវកងកំលាំងរបស់ភូមិភាគនិរតី នៅក្នុងស្រុកព្រះនេត្រព្រះ នៅខែមិថុនា ឆ្នាំ១៩៧៧[403] និងបានកើនឡើងខ្លាំងរយៈពេលមួយឆ្នាំក្រោយមកគឺនៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ ដោយមានការចាប់ខ្លួន លេខាភូមិភាគពាយ័ព្យឈ្មោះ មូល សម្បត្តិ ហៅ រស់ ញឹម និងមេដឹកនាំជាន់ខ្ពស់ខាងភូមិភាគ និងមេដឹកនាំតំបន់[404] ។ ក្នុងអំឡុងពេលនោះ **តា ទិត** បានបម្រើតួនាទីជាមេដឹកនាំ *តាមព្រឹត្តហេតុ* របស់ភូមិភាគពាយ័ព្យ[405] ។ បន្ទាប់ពីការចាប់ខ្លួនលេខា ភូមិភាគឈ្មោះ ញឹម នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ **តា ទិត**

បានចូលកាន់មុខតំណែងជាលេខាតំបន់១ របស់ភូមិភាគពាយ័ព្យ និង ជាអនុលេខាគណៈភូមិភាគពាយ័ព្យ*តាមនីតិន័យ* ហើយ តា ម៉ុក បានក្លាយទៅជាលេខាភូមិភាគពាយ័ព្យ[406] ។ **តា ទិត** បានចូលជំនួស ហេង ទាវ ហៅ ប៉ែត ហៅ កន្តុល (ដែលជាសមាជិកជាយូរមកហើយរបស់គណៈភូមិភាគពាយ័ព្យ) ធ្វើជាលេខាតំបន់១[407] និង កី (ដែលជាសមាជិកត្រៀមនៃគណៈអចិន្ត្រៃយ៍) ធ្វើជាអនុលេខាភូមិភាគពាយ័ព្យ[408] ។

៩៥. គិតមកត្រឹមពាក់កណ្តាលឆ្នាំ១៩៧៨ ការទទួលខុសត្រូវរបស់ តា ម៉ុក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានកើនឡើងគួរឱ្យកត់សំគាល់ ហើយតំបន់នៅក្រោមការត្រួតត្រារបស់គាត់ បានពង្រីកពីភូមិភាគនិរតី រហូតដល់បញ្ចូលភូមិភាគបស្ចិម ភាគភូមិកណ្តាល ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ[409] ។ ជាលទ្ធផល តា ម៉ុក បានចុះទៅភូមិភាគពាយ័ព្យ "ម្តងម្កាល" ទេ ហើយ **តា ទិត** បានបម្រើការជាលេខាភូមិភាគតាមព្រឹត្តហេតុ[410] ។ នៅចុងរបបកម្ពុជាប្រជាធិបតេយ្យ **តា ទិត** អាចត្រូវបានគេតម្លើងឋានៈជាលេខាភូមិភាគតាមនីតិន័យដោយសារមានសាក្សីម្នាក់ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំរបស់កម្មាភិបាលភូមិភាគពាយ័ព្យសំខាន់ៗនៅចុងឆ្នាំ១៩៧៨ ដែលនៅពេលនោះ **តា ទិត** បានមកជាមួយកងការពារ៤ ឬ ៥នាក់ ហើយបានប្រកាសថា គាត់ជា "ប្រធានភូមិភាគថ្មី"[411] ។ ក្នុងឋានៈជាលេខាតាមព្រឹត្តហេតុ ឬតាមនីតិន័យរបស់ភូមិភាគ ដែលជាភូមិភាគមួយដ៏សំខាន់បំផុតជាយុទ្ធសាស្ត្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **តា ទិត** អាចក្លាយទៅជាសមាជិករបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងមហាសន្និបាតបក្សលើកទី៥ [412] ។

៩៦. ក្នុងនាមជាអនុលេខា និងលេខាភូមិភាគស្តីទី **តា ទិត** បានទទួលខុសត្រូវខាងផ្នែកសន្តិសុខនៅក្នុងភូមិភាគពាយ័ព្យ ហើយមាន "សិទ្ធិអំណាចទៅលើកិច្ចការស៊ីវិល និងយោធា"[413] ។ ដូច្នេះ **តា ទិត** ទទួលខុសត្រូវផ្ទាល់ទៅលើមន្ទីរសន្តិសុខចំនួន២៧ នៅក្នុងភូមិភាគពាយ័ព្យ[414] ។ កម្មាភិបាលនៅមន្ទីរសន្តិសុខទាំងអស់នោះ បាយរាយការណ៍តាមរយៈខ្សែសង្វាក់បញ្ជាទៅឱ្យ **តា ទិត** ដោយផ្ទាល់ ឬដោយប្រយោល[415] ។ **តា ទិត** មានសិទ្ធិ និងអំណាច (ក) ក្នុងការផ្តល់បទបញ្ជាទៅឱ្យអ្នកនៅក្រោមបង្គាប់របស់គាត់ទាំងអស់ ដែលមានកាតព្វកិច្ចត្រូវតែអនុវត្តតាម ហើយ(ខ) ផ្តន្ទាទោសដាក់វិន័យផ្អាកឬដកអ្នកក្រោមបង្គាប់ចេញពីមុខតំណែង ប្រសិនបើអ្នកទាំងនោះជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្ត ដែលគាត់មិនបានអនុញ្ញាត យល់ព្រម ឬបើពុំដូច្នោះទេ បានបណ្តែតបណ្តោយ ។ ក្នុងឋានៈជាសមាជិកគណៈភូមិភាគមួយរូប **តា ទិត** ក៏មានសិទ្ធិអំណាចក្នុងការ "កម្ទេច ទាំងក្នុង និងក្រៅជួរ"[416] ។ ដោយសារតែមានសិទ្ធអំណាចនេះ **តា ទិត** បានប្រើប្រាស់លើការត្រួតត្រាយ៉ាងមានប្រសិទ្ធិភាពទៅលើមនុស្សនៅក្នុងមន្ទីរសន្តិសុខ និងទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗទៀត ដោយបានចូលរួមនៅក្នុងឧក្រិដ្ឋកម្ម ដូចមានចែងនៅក្នុងកថាខណ្ឌទី៥៤ដល់កថាខណ្ឌទី៨១ ហើយមានសិទ្ធិ

និងអំណាច នៅក្នុងការសម្រេច ថាតើមនុស្សណាម្នាក់នៅក្នុងទីតាំងទាំងអស់នោះ ត្រូវ "កម្ទេច" ឬសម្លាប់ចោល ។

៩៧. តំបន់ដែល **តា ម៉ុក** បានត្រួតត្រា ក្នុងឋានៈជាលេខាតំបន់១ មានរាប់បញ្ចូលផ្នែកខ្លះរបស់ស្រុកបាណន់ នាពេលបច្ចុប្បន្ននេះ[417], ស្រុករតនមណ្ឌល[418], ស្រុកមោងឫស្សី[419], ស្រុកសង្កែ[420] និងស្រុកសំឡូត[421] នៅក្នុងខេត្តបាត់ដំបង[422] ។ មន្ទីររបស់តំបន់១ នៅក្នុងអំឡុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ស្ថិតនៅចំកន្លែងប៉ុស្តិ៍នគរបាលរតនមណ្ឌល នាពេលបច្ចុប្បន្ន[423] ។ ក្នុងនាមជាលេខាស្តីទី និងជាអនុលេខា ភូមិភាគពាយ័ព្យ តា ម៉ុក ក៏មានសិទ្ធិអំណាចទៅលើតំបន់២, ៣, ៤, ៥, ៦ និង៧ របស់ភូមិភាគពាយ័ព្យដែរដែលតាមពិត ទៅគឺឥឡូវនេះ តំបន់ទាំងអស់នេះស្ថិតនៅក្នុងខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និង ខេត្តពោធិ៍សាត់[424] ។

## ការចូលរួម និងការដឹងឮ

៩៨. ឆ្លងកាត់ការកាន់មុខតំណែងជាច្រើនជាមេដឹកនាំរបស់ ប.ក.ក **តា ម៉ុក** បានរៀបចំផែនការ បានជម្រុញ បានញុះញង់ បានជួយសម្រួល បានជួយនិងជម្រុញ បានលើកទឹកចិត្ត បានបណ្តែតបណ្តោយ និង/ឬ បានចេញបញ្ជាឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដូចដែលមានចែងនៅក្នុងកថាខណ្ឌទី៥៤ ដល់កថាខណ្ឌទី៨១ ។ ការចូលរួម និងដឹងឮរបស់ **តា ម៉ុក** ផ្ទាល់អំពីឧក្រិដ្ឋកម្ម មានភស្តុតាងបញ្ជាក់ដូចតទៅ៖

ក. ការបោះសម្អាតមេដឹកនាំភូមភាគពាយ័ព្យ (ដែលបានពិភាក្សាយ៉ាងពិស្តារនៅកថាខណ្ឌទី៥៤ ដល់កថាខណ្ឌទី៥៩) ដែលបញ្ចប់ត្រឹម **តា ម៉ុក** ជាលេខាភូមិភាគស្តីទី បានរៀបចំផែនការឡើងផ្ទាល់ដោយ **តា ម៉ុក** តា ម៉ុក និង មេដឹកនាំ ប.ក.ក ដទៃទៀត ហើយសកម្មភាពបោះសម្អាតនេះធ្វើឡើងដោយកម្មាភិបាលភូមិភាគនិរតី ក្រោមការបញ្ជារបស់មេដឹកនាំខាងលើនេះ ។

ខ. ការចាប់ខ្លួនជាក្រុម និងការសម្លាប់រង្គាល ដែលបានកើតឡើងនៅទូទាំងភូមិភាគពាយ័ព្យ ក្រោយពីក្រុមកម្មាភិបាលភូមិភាគនិរតីបានមកដល់ (មានពន្យល់បន្ថែមនៅកថាខណ្ឌទី៥៩ និងក្រោមលេខយោង២២២ ដល់ ២២៨) ជាសកម្មភាពដែលរៀបចំផែនការ បានញុះញង់ និងបានបញ្ជាដោយ **តា ម៉ុក** ។ ការដឹងឮអំពីការចាប់ខ្លួនទាំងឡាយ និងការទទួលខុសត្រូវផ្ទាល់របស់ **តា ម៉ុក** ចំពោះទង្វើទាំងនេះ បានទទួលការបញ្ជាក់អះអាងពីអតីតសមាជិកគណៈភូមិភាគពាយ័ព្យ និងជាអតីតលេខាតំបន់១[425] ។

គ. នៅស្រុកគិរីវង់ **តា ម៉ុក** បានបញ្ជាឱ្យអ្នកនៅក្រោមបង្គាប់ចាប់ខ្លួន និងសម្លាប់មនុស្ស ។ ប្រធានស្រុករាមអណ្តើក ឈ្មោះ ងោល បានទទួលបញ្ជាពី **តា ម៉ុក** ឱ្យសម្លាប់មនុស្ស២០០នាក់[426] ។ មានម្តងនោះ **តា**

**ទិត** បានបញ្ជា ង៉ោល ឱ្យសម្លាប់មនុស្ស២នាក់ដែលប្រុងរត់គេចខ្លួនទៅវៀតណាម ហើយ **តា ទិត** បានមកមើលការសម្លាប់មនុស្សនេះផ្ទាល់ភ្នែកដើម្បីឱ្យច្បាស់ថា ង៉ោល ពិតជាបានអនុវត្តតាមការបញ្ជារបស់គាត់មែន[427] ។ ករណីការសម្លាប់ជាច្រើន ធ្វើឡើងដោយកងកម្លាំងសន្តិសុខស្រុកដែលស្ថិតក្រោមត្រួតត្រា និងបញ្ជារបស់ **តា ទិត**[428] ។ សមាជិកម្នាក់នៃគណៈស្រុករបស់ **តា ទិត** ហៅ "ពេទ្យ" ប៊ូ បានសម្លាប់សាច់ញាតិទាំងអស់របស់មេភូមិកុកព្រិចដោយផ្ទាល់ដៃ[429] ។ នៅមន្ទីរសន្តិសុខវត្តព្រះធាតុ កំណត់ហេតុលាយលក្ខណ៍អក្សរនៃការសួរចម្លើយត្រូវបានគេរៀបចំឡើង និងបានបញ្ជូនទៅឱ្យគណៈស្រុក របស់ **តា ទិត** ដើម្បីពិនិត្យ[430] ។ បន្ទាប់មកគណៈស្រុកត្រូវបញ្ជូនបញ្ជីមួយត្រឡប់មកមន្ទីរសន្តិសុខវត្តព្រះធាតុវិញ ដើម្បីសម្គាល់តើអ្នកទោសណាខ្លះត្រូវដោះលែង និងអ្នកណាខ្លះត្រូវយកទៅសម្លាប់ចោល[431] ។

ឃ. **តា ទិត** ថែមទាំងបានបញ្ជាកូនចៅរបស់ខ្លួននៅស្រុកគិរីវង់ឱ្យ "ឃ្លាំមើល ទាហាន គ្រូបង្រៀន និងខ្សែរយៈពាក់ព័ន្ធរបស់អ្នកទាំងនោះ" និងឱ្យកម្ទេចប្រជាជនជម្លៀស ដែលមិនសូវមានសាច់ញាតិជាប្រជាជនមូលដ្ឋាន[432] ។

ង. **តា ទិត** បានដឹងឮ បានបញ្ជា និងប្រហែលជាធ្លាប់បានចូលរួមដោយផ្ទាល់ ក្នុងសកម្មភាពធ្វើទារុណកម្ម និងកាយវិកលកម្មលើអ្នកទោស ។ សមាជិកគណៈស្រុកគិរីវង់ ដែលស្ថិតក្រោមបង្គាប់ **តា ទិត** បានមកមន្ទីរសន្តិសុខវត្តព្រះធាតុ ដើម្បីប្រមូលប្រមាត់ដែលកាត់ចេញពីអ្នកទោស ។ ចំណែក **តា ទិត** ខ្លួនឯងផ្ទាល់ ក៏ធ្លាប់មកម្តងម្កាលដែរ[433] ។

ច. **តា ទិត** បានដឹកនាំមេឃុំ និងជនក្រោមបង្គាប់ខ្លួន និងជាអ្នករាយការណ៍ឱ្យខ្លួនផងនោះ ឱ្យទៅប្រមូលស្រូវអង្ករនៅតាមសហករណ៍ និងតាមភូមិនានា ដែលស្ថិតនៅក្នុងដែនដីកាន់កាប់របស់ខ្លួន[434] ។ ដោយសារតែមូលហេតុនេះហើយ ទើបប្រជាជននៅស្រុកគិរីវង់ ត្រូវធ្វើការជាច្រើនម៉ោង និងទទួលរបបអាហារតែពាក់កណ្តាលប៉ុណ្ណោះ ហើយមានប្រជាជនជាច្រើនបានស្លាប់ដោយការស្រេកឃ្លាន[435] ។ ស្រូវអង្ករមួយចំនួនធំត្រូវត្រូវបានគេដឹកយកពីសហករណ៍ភូមិភាគពាយ័ព្យនៅឆ្នាំ១៩៧៨ ធ្វើឱ្យប្រជាជននៅទីនោះពុំមានអាហារបរិភោគគ្រប់គ្រាន់[436] ។

ឆ. **តា ទិត** បានបញ្ជូនក្រុមកម្មាភិបាលទៅ "មន្ទីរកសាង" ភូមិភាគនិរតី ដែលបានបង្កើតឡើងក្នុងរវាងខែមករា និងខែកុម្ភៈ ឆ្នាំ១៩៧៨ ក្នុងគោលបំណងសម្រាប់កម្មាភិបាល ប.ក.ក. ទាំងឡាយ ដែលត្រូវបានរកឃើញថា "មានជាប់និន្នាការ" ឬ "ជាមនុស្សក្រោមបង្គាប់មេដឹកនាំដែលត្រូវបានចាប់ខ្លួន និងជាអ្នកដែលមានគោលជំហរគួរឱ្យសង្ស័យដែលត្រូវធ្វើការស្រាវជ្រាវជាបន្តទៀត"[437] ។

ជ. **តា ទិត** បានទៅពិនិត្យតាមបណ្តាមន្ទីរសន្តិសុខ សហករណ៍ ការដ្ឋាន រោងចក្រ ស្រែចម្ការ និងតាមអគាររដ្ឋនានា ក្នុងតំបន់របស់ខ្លួន រួមទាំងកន្លែងដែលអំពើឧក្រិដ្ឋបានប្រព្រឹត្តឡើង ដូចជានៅវត្តព្រះធាតុ

ជាដើម[438] ។ ពេលកំពុងចុះទៅពិនិត្យនោះ **តា ទិត** តែងតែជួបផ្ទាល់ ដើម្បីណែនាំកម្មាភិបាលក្រោមបង្គាប់ និងផ្តល់បទឧទ្ទេសនាមលើកទឹកចិត្តឲ្យប្រជាជនខំប្រឹងធ្វើការ ស្របតាមសារាចរណែនាំរបស់បក្ស[439] ។ ជាងនេះទៀត ក្នុងពេលចុះពិនិត្យទាំងអស់នោះ **តា ទិត** ប្រហែលជាបានមើលឃើញពីស្ថានភាពនៅកន្លែងទាំងអស់នោះ រួមទាំងស្ថានភាពរបស់អ្នកទោស និងប្រជាជនកំពុងធ្វើការនៅទីនោះ ។ **តា ទិត** ប្រហែលជាធ្លាប់ដឹងឮពីប្រសិទ្ធភាពនៃគោលនយោបាយដែលខ្លួនបាននិងកំពុងអនុវត្ត និងសារាចរណែនាំដែលខ្លួនបានដាក់ចេញ ក្នុងសមត្ថភាពជាលេខាស្រុកគិរីវង់ ជាលេខាតំបន់១ និងជាលេខាស្តីទីភូមិភាគពាយ័ព្យ ។

## អ៊ឹម ចែម

## ប្រវត្តិរូបផ្ទាល់ខ្លួន

៩៩. **អ៊ឹម ចែម** កើតនៅឆ្នាំ១៩៤៦ នៅភូមិក្បាលអូរ ស្រុកត្រាំកក់ ខេត្តតាកែវ[440] ។ **អ៊ឹម ចែម** បានចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៧០ ដោយសារមូលហេតុខ្លាច "ពូជសាសន៍ខ្មែរត្រូវបាត់បង់"[441] ។ **អ៊ឹម ចែម** មកពីភូមិ ជាមួយគ្នានឹងតា ម៉ុក ដែលជាលេខាភូមិភាគនិរតី និងជាសមាជិកគណៈអចិន្ត្រៃយ៍ ប.ក.ក ហើយមានទំនាក់ទំនងជាប់ជាយូរយ៉ាងណាស់មកហើយជាមួយ តា ម៉ុក[442] ដែលនៅតែបន្តពេញមួយរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[443] ។

១០០. **អ៊ឹម ចែម** បច្ចុប្បន្នជាមេឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ[444] ។ **អ៊ឹម ចែម** បានកាន់តំណែងនេះចាប់តាំងពីខែមិថុនា ឆ្នាំ២០០៥ មក នៅពេលគាត់ត្រូវបានតម្លើងឋានៈពីជំទប់ឃុំ រហូតដល់មេឃុំ[445] ។

## សិទ្ធិអំណាច

១០១. ក្នុងអំឡុងពេលពីឆ្នាំ១០៧៦ ដល់ខែមិថុនា ឆ្នាំ១៩៧៧ **អ៊ឹម ចែម** ជាលេខាស្រុកកោះអណ្តែត នៅខេត្តតាកែវ (ដែលជាផ្នែកមួយនៃតំបន់១៣ នៃភូមិភាគនិរតី)[446] ។ នៅខែមិថុនា ឆ្នាំ១៩៧៧ **អ៊ឹម ចែម** ត្រូវបានតែងតាំងជាលេខាស្រុកព្រះនេត្រព្រះ ក្នុងខេត្តបន្ទាយមានជ័យ (ជាផ្នែកនៃតំបន់៥ ភូមិភាគពាយ័ព្យ) ហើយបានកាន់មុខងារនេះរហូតដល់ថ្ងៃបញ្ចប់នៃរបប[447] ។ តា ម៉ុក បានជ្រើសរើស **អ៊ឹម ចែម** ដោយផ្ទាល់មកកាន់តំណែងនេះ ។

១០២. **អ៊ឹម ចែម** មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាយូរមកហើយជាមួយ តា ម៉ុក ដែលជាលេខាភូមិភាគនិរតី ជាសមាជិកគណៈអចិន្ត្រៃយ៍ ប.ក.ក និង (ចាប់ផ្តើមពីខែមិថុនា ឆ្នាំ១៩៧៨) ជាលេខាភូមិភាគពាយ័ព្យ ។ **អ៊ឹម ចែម** និង តាម៉ុក បានពិភាក្សាអំពីផែនការបីឆ្នាំ សម្រាប់ស្រុកព្រះនេត្រព្រះ ជាកន្លែងដែល **អ៊ឹម ចែម** ត្រូវ "ដោះស្រាយបញ្ហារបស់ប្រជាជននៅទីនោះ"[448] ។ ក្នុងពេលកាន់មុខតំណែងនៅស្រុកព្រះនេត្រព្រះ**អ៊ឹម ចែម** បានផ្តល់ដំណឹងដល់ តាម៉ុក ពីស្ថានភាពនៃអ្នកជាប់ឃុំឃាំង[449] ការធ្វើពលកម្មដោយបង្ខំ និងការរីកចំរើននៅការដ្ឋានកសាងទំនប់[450]) ។ ពេល **អ៊ឹម ចែម** នៅកាន់អំណាចជាលេខាស្រុកកោះអណ្តែត ក្នុងភូមិភាគនិរតី ក៏ដូចជាពេលដែលនៅ ស្រុកព្រះនេត្រព្រះដែរ តា ម៉ុក នៅតែបន្តដាក់បញ្ហាទៅលើ **អ៊ឹម ចែម** ជាងដែលទាក់ទិននឹងភារកិច្ចរបស់គាត់នៅក្នុងស្រុកព្រះនេត្រព្រះ[451]) ។ ទំនាក់ទំនងជាមួយ តាម៉ុក មានជាបន្តបន្ទាប់ តាំងពីមុន ពេល និងក្រោយពេលដែល តាម៉ុក បានក្លាយជាលេខាភូមិភាគពាយ័ព្យនៅខែមិថុនា ឆ្នាំ១៩៧៨ មកម្ល៉េះ ។

១០៣. បន្ថែមលើការទំនាក់ទំនងជាមួយ តាម៉ុក **អ៊ឹម ចែម** បានរាយការណ៍ជូន និងបានទទួលបញ្ជាពីថ្នាក់ដឹកនាំកំពូលនៃរបបកម្ពុជាប្រជាធិបតេយ្យដែលរួមមាន ប៉ុល ពត[452] "អង្គការថ្នាក់លើ"[453] និងគណៈភូមិភាគ អំពីបញ្ហាការធ្វើពលកម្មដោយបង្ខំនៅស្រុកព្រះនេត្រព្រះ [454] ។

១០៤. ក្នុងនាមជាលេខាស្រុក ឥទ្ធិពលរបស់ **អ៊ឹម ចែម** បានរីកសុះសាយទូទាំងតំបន់៥ ជាទីដែលគាត់បានបង្កើត ធ្វើប្រតិបត្តិការ និងត្រួតត្រាលើមន្ទីរសន្តិសុខតំបន់៥ នៅឯភ្នំទ្រយោង[455] ។ ភ្នំទ្រយោងជាកន្លែងដែលកម្មាភិបាលស្រុកព្រះនេត្រព្រះ និងបុគ្គលដទៃទៀតដែលត្រូវបានសម្គាល់ថាជាខ្មាំងក៏ត្រូវបានចាប់ឃុំឃាំងដោយខុសច្បាប់[456]ទទួលរងពលកម្មដោយបង្ខំនៅការដ្ឋានវាយថ្មរបស់មន្ទីរសន្តិសុខនោះ[457] និងត្រូវបានសម្លាប់ចោល[458] ។ សាក្សីមួយចំនួនបាននិយាយថា **អ៊ឹម ចែម** ជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង[459] ។ លើសពីនេះទៀត ឈ្លបឃុំដែលស្ថិតនៅក្រោមការត្រួតត្រារបស់ **អ៊ឹម ចែម** ជាអ្នកទទួលខុសត្រូវក្នុងការចាប់ខ្លួនមនុស្សយកទៅសម្លាប់នៅភ្នំទ្រយោង[460] ។

១០៥. ក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ **អ៊ឹម ចែម** ថែមទាំងបានប្រើសិទ្ធិអំណាចត្រួតត្រាលើមន្ទីរសន្តិសុខមួយចំនួននៅក្នុងស្រុក រួមមាន មន្ទីរសន្តិសុខភ្នំចក្រី (ដែលមានដំណើរការដូចគុកស្រុកព្រះនេត្រព្រះដែរ) និងកន្លែងសម្លាប់មនុស្សនៅជាប់គ្នានោះនៅភូមិតារត់ ។

១០៦. **អ៊ឹម ចែម** បានទទួលស្គាល់ថា ខ្លួនបានបញ្ជូនមនុស្សពីស្រុកព្រះនេត្រព្រះ ទៅធ្វើស្រែនៅទំនប់ត្រពាំងថ្ម ស្រុកភ្នំស្រុកជាប់គ្នានោះដែលជាកន្លែងពោរពេញដោយការអត់ឃ្លាន និងការងារហួសកម្លាំង[461] ។ **អ៊ឹម ចែម** ថែមទាំងបានទទួលស្គាល់ថាខ្លួនបានបញ្ជូនមនុស្ស និងដកហូតអាវុធពីកងឈ្លបភូមិភាគពាយ័ព្យ ដើម្បីបង្ខំឱ្យទៅធ្វើការនៅស្ពានស្រែង និងការដ្ឋានទំនប់ព្រៃរនាម ក្នុងស្រុកព្រះនេត្រព្រះ[462] ។

១០៧. ក្នុងសមត្ថភាពជាលេខាស្រុក **អ៊ឹម ចែម** បានប្រើការត្រួតត្រាយ៉ាងមានប្រសិទ្ធភាព លើបុគ្គលផ្សេងៗនៅ ថ្នាក់ស្រុក និងឃុំ ដែលជាអ្នកបានចូលរួមក្នុងអំពើឧក្រិដ្ឋ ដូចមានពន្យល់យ៉ាងពិស្តារនៅក្នុងកថាខណ្ឌទី ៧៤ ដល់កថាខណ្ឌទី៧៩ ។ ដោយសាររចនាសម្ពន្ធបញ្ជាការតាមឋានានុក្រមរបស់អង្គការ ប.ក.ក **អ៊ឹម ចែម** មានសិទ្ធិអំណាច (ក) ចេញបញ្ជាឱ្យមនុស្សក្រោមបង្គាប់មានកាតព្វកិច្ចត្រូវតែធ្វើតាម និង (ខ) ដាក់ទណ្ឌកម្ម ពិន័យ ផ្អាក ឬដកអ្នកក្រោមបង្គាប់ទាំងនោះពីតំណែងរបស់ពួកគេ ប្រសិនបើ អ្នកទាំងនោះជាប់ទាក់ទិននឹងអំពើដែល **អ៊ឹម ចែម** មិនអនុញ្ញាត មិនយល់ព្រម ឬបើមិនដូច្នោះទេ បានបណ្តែតបណ្តោយឱ្យកើតឡើង ។

## ការចូលរួម និងការដឹងឮ

១០៨. ក្នុងនាមជាលេខាស្រុកព្រះនេត្រព្រះ **អ៊ឹម ចែម** បានរៀបចំផែនការ បានជំរុញ បានញុះញង់ បានជួយសម្រួល បានជួយនិងជំរុញ បានលើកទឹកចិត្ត បានបណ្តែតបណ្តោយ ឬបានបញ្ជាឱ្យមានការប្រព្រឹតឧក្រិដ្ឋកម្ម ដែលមានពន្យល់យ៉ាងពិស្តារនៅក្នុងកថាខណ្ឌទី៥៤ ដល់កថាខណ្ឌទី៥៩ និងកថាខណ្ឌទី ៧៤ ដល់កថាខណ្ឌទី៧៩ ។ ការចូលរួម និងដឹងឮរបស់ **អ៊ឹម ចែម** នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ មានភស្តុតាង បញ្ជាក់ដូចតទៅ ៖

ក. **អ៊ឹម ចែម** មានជាប់ពាក់ព័ន្ធដោយផ្ទាល់ ក្នុងការចាប់ខ្លួនកម្មាភិបាលស្រុកព្រះនេត្រព្រះ ។ ឧទាហរណ៍ **អ៊ឹម ចែម** បានសារភាពថា នៅក្នុងអំឡុងពេលដែលខ្លួននៅកាន់អំណាចជាលេខាស្រុក បទបញ្ជាឲ្យចាប់ខ្លួនដែលចេញពីការិយាល័យភូមិភាគគឺផ្ញើតម្រង់មកគាត់ផ្ទាល់ ហើយគាត់ជាអ្នកទទួលបញ្ជានោះផ្ទាល់ និងបានអនុវត្តតាម ដោយកំណត់មនុស្សដែលត្រូវចាប់ខ្លួន[463] ។ ជាងនេះទៀត **អ៊ឹម ចែម** បានធ្វើជាអធិបតីនៅ ក្នុងអង្គប្រជុំមួយក្នុងឆ្នាំ១៩៧៨ នៅវត្តព្រះនេត្រព្រះ ជាកន្លែងដែលបានសម្រេចឱ្យចាប់ខ្លួនអតីតអនុលេខាស្រុកព្រះនេត្រព្រះ ឈ្មោះ អាត សំ[464] ។ បន្ទាប់មក **អ៊ឹម ចែម** បានទៅចាប់ អាត សំ ដោយផ្ទាល់ដៃ[465] ។

ខ. **អ៊ឹម ចែម** ថែមទាំងបានដឹងឮ អំពីព្រឹត្តិការណ៍មួយចំនួន រួមមាន ការសម្លាប់មនុស្សនៅចម្ការតាឡឹងកន្លែងសម្លាប់មនុស្សនៅជាប់វត្តព្រះនេត្រព្រះដោយសារមានការប្រជុំនៅវត្តព្រះនេត្រព្រះ[466] ។

គ. **អ៊ឹម ចែម** ទទួលស្គាល់ពីការបញ្ជូនមនុស្សរហូតដល់៨០០ នាក់ (ក្នុងនោះរួមមានឈ្លបភូមិភាគពាយ័ព្យដែលខ្លួនបានដកហូតអាវុធ) យកទៅកាន់ការដ្ឋានដោយបង្ខំនៅទំបន់ស្ពានស្រែង និងព្រៃរនាមនៅក្នុងស្រុកព្រះនេត្រព្រះ[467] ហើយ **អ៊ឹម ចែម** សារភាពថា ទំនប់នេះ ប្រើកម្លាំងពលកម្ម

មនុស្សសុទ្ធសាធ[468] ។ **អ៊ឹម ចែម** ទទួលស្គាល់ថា ខ្លួនជាអ្នកផ្ដើមគំនិត និងជាធ្វើផែនការសាងសង់ទំនប់[469] ទាំងអស់នេះ ។ **អ៊ឹម ចែម** បានធ្វើទំនាក់ទំនងជាមួយ ប៉ុល ពត អំពីស្ថានភាពពលករដោយបង្ខំ ហើយបានទទួលស្គាល់ថា មានមនុស្សខ្លះបានស្លាប់ដោយសារការធ្វើការហួសកម្លាំង[470] ។

ឃ. **អ៊ឹម ចែម** ត្រូវបានគេកំណត់អត្តសញ្ញាណថា ប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង[471] ជាកន្លែងដែលអ្នកទោសមានចំនួនរហូតដល់៤ម៉ឺននាក់ បានស្លាប់ដោយសារការសម្លាប់ ការបង្អត់អាហារ និងការធ្វើការបាក់កម្លាំង[472]។ជាផ្នែកនៃការលុតដំកសាងខ្លួនអ្នកជាប់ឃុំត្រូវបានគេបង្ខំឱ្យធ្វើការនៅការដ្ឋានវាយថ្មរបស់មន្ទីរសន្តិសុខ ឬឱ្យភ្ជួរស្រែ[473] និងឲ្យហូបតែបបរ១វែកប៉ុណ្ណោះក្នុងមួយពេល[474] ។

ង. **អ៊ឹម ចែម** ទទួលស្គាល់ថា ខ្លួនបានបញ្ជូនមនុស្សរាប់រយនាក់ទៅកន្លែងធ្វើពលកម្មដោយបង្ខំ នៅការដ្ឋានទំនប់ត្រពាំងថ្ម[475] និងថាពលករនៅទីនោះបានធ្លាក់ខ្លួនឈឺ គ្មានអាហារគ្រប់គ្រាន់ ហើយបានស្លាប់ដោយសារតែការអត់ឃ្លាន[476] ។ **អ៊ឹម ចែម** បានទទួលផែនការការងារសម្រាប់ការដ្ឋានទំនប់ត្រពាំងថ្មនៅក្នុងកិច្ចប្រជុំប្រចាំខែមួយ[477] ហើយបានទទួលដំណើរចុះពិនិត្យរបស់ ខៀវ សំផន និង ប៉ុល ពត[478] នៅការដ្ឋានទំនប់នេះ ។

ច. ជាចុងក្រោយសាក្សីនានាពិណ៌នាពីស្ថានភាពកង្វះអាហារនៅស្រុកព្រះនេត្រព្រះបន្ទាប់ពីការមកដល់របស់កម្មាភិបាលភូមិភាគនិរតី[479] ។ ស្រុកព្រះនេត្រព្រះ ជាកន្លែងដែលជួបប្រទះនឹងបញ្ហាស្បៀងអាហារយ៉ាងធ្ងន់ធ្ងរ ដោយសារប្រជាជនថ្មីជាង៩ម៉ឺននាក់ បានចូលមកស់នៅទីនេះ ដែលពីមុនមានប្រជាជនតិតតួចតែប្រមាណ១៥០គ្រួសារប៉ុណ្ណោះ ដែលជាអ្នកតាំងទីលំនៅមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥[480] ។ **អ៊ឹម ចែម** ខ្លួនឯងផ្ទាល់ទទួលស្គាល់ថា ក្នុងអំឡុងពេលនៃអាណត្តិអន្ត្រែយ៍នៃមុខតំណែងជាលេខាស្រុកព្រះនេត្រព្រះ[481] របស់គាត់មានមនុស្សច្រើនរហូតដល់ជាង១ម៉ឺននាក់បានស្លាប់ ដោយសារការសម្លាប់ ការបង្អត់អាហារនិងជម្ងឺផ្សេងៗ ហើយបញ្ហាកង្វះខាតអាហារ និងការថែទាំខាងផ្នែកវេជ្ជសាស្ត្រ[482] ក៏បានកើតមានផងដែរនៅក្នុងរយៈពេលនេះ ។

## បទល្មើសដែលមានទោសធ្ងន់

១០៩. យើង សហព្រះរាជអាជ្ញា មានហេតុផលជឿថា **តា អាន** បានរៀបចំផែនការ បានញុះញង់ បានបញ្ជា បានជួយនិងជំរុញ ឬបានប្រព្រឹត្តបទល្មើសនានា ដូចមានចែងក្នុងកថាខណ្ឌទី១៨ ដល់កថាខណ្ឌទី៥៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣, **តា ទិត** បានរៀបចំផែនការ បានញុះញង់ បានបញ្ជា បានជួយនិងជំរុញ ឬបានប្រព្រឹត្តបទល្មើសនានា ដូចមានចែងក្នុងកថាខណ្ឌទី៥៤ ដល់កថាខណ្ឌទី៨១ និងថា **អ៊ឹម ចែម** បានរៀបចំផែនការ បានញុះញង់ បានបញ្ជា បានជួយ

និងជំរុញ បានលើកទឹកចិត្ត ឬប្រព្រឹត្តបទល្មើសនានា ដូចមានចែងក្នុងកថាខណ្ឌទី៥៤ ដល់កថាខណ្ឌទី ៥៩ និង កថាខណ្ឌទី៧៤ ដល់កថាខណ្ឌទី ៧៩ ដែលបទល្មើសខាងលើ បានកើតឡើងនៅប្រទេសកម្ពុជា ក្នុងរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

១១០. យើងមានសំអាងគ្រប់គ្រាន់ថា ជនសង្ស័យទាំងនេះគឺជាមេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង/ឬ ជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត នៅក្នុងឧក្រិដ្ឋកម្ម អនុលោមតាមមាត្រា២៩ នៃច្បាប់ អ.វ.ត.ក ។ ជនសង្ស័យទាំងនេះ បានរៀបចំផែនការ បានញុះញង់ បានបញ្ជា បានជួយនិងជំរុញ ឬបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ។ ជនសង្ស័យទាំងនេះ មានចេតនាផ្ទាល់ក្នុងការធ្វើឱ្យឧក្រិដ្ឋកម្មនេះ ត្រូវបានប្រព្រឹត្តឡើង ឬយ៉ាងហោចណាស់ ជនសង្ស័យទាំងនេះបានដឹងពីភវនីយហេតុជាសក្តានុពលដែលថាឧក្រិដ្ឋកម្មទាំងនេះនឹងត្រូវបានប្រព្រឹត្តឡើងនៅក្នុងការប្រតិបត្តិទៅតាមផែនការ ការញុះញង់ បទបញ្ជា ឬជំនួយរបស់ពួកខ្លួន ។

១១១. នៅទីកន្លែងដែលជនសង្ស័យទាំងនេះ បានប្រព្រឹត្តបទឧក្រិដ្ឋទាំងអស់នោះ គឺពួកគេបានធ្វើឡើងដូច្នេះ តាមរយៈការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ជាមួយនិង សហចារីដទៃទៀត ។ បទឧក្រិដ្ឋទាំងនេះ ជាកម្មវត្ថុនៃសហកម្មឧក្រិដ្ឋកម្មរួម ឬបើផ្ទុយពីនេះ ក៏ជាហេតុបច្ច័យនៃ សហកម្មឧក្រិដ្ឋកម្មរួមតាមចរិតធម្មជាតិ និងដែលអាចព្យាករណ៍បាន ។ ជនសង្ស័យត្រូវតែបានដឹង ឬគួរតែបានដឹងថា ឧក្រិដ្ឋកម្មដូច្នេះក៏ជាហេតុបច្ច័យតាមចរិតធម្មជាតិ និងដែលអាចព្យាករណ៍បាន ដែលនាំឱ្យមានការប្រតិបត្តិនូវសហកម្មឧក្រិដ្ឋកម្មរួមហើយជនសង្ស័យនៅតែសម្រេចចិត្តចូលរួមនៅក្នុងសហកម្មនោះ ។ សមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ដែលបានធ្វើសកម្មភាពដោយឈរលើ មូលដ្ឋាននៃគោលបំណងរួមដោយមានចេតនាដូចគ្នា ។

១១២. ជនសង្ស័យទាំងនេះថែមទាំងត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងអស់នេះ ក្នុងនាមជាមេដឹកនាំអ្នកក្រោមបង្គាប់របស់ខ្លួន ដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ។ ជនសង្ស័យទាំងនេះ មានសិទ្ធិអំណាច និងការត្រួតត្រាយ៉ាងមានប្រសិទ្ធភាពទៅលើជនក្រោមបង្គាប់ ហើយជនសង្ស័យទាំងនេះ ក៏បានដឹង ឬមាន ហេតុផលត្រូវតែដឹងថា អ្នកក្រោមបង្គាប់របស់ខ្លួនបម្រុងនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តអំពើទាំងនោះ ហើយជនសង្ស័យមិនបានរិះរកមធ្យោបាយសមស្រប និងចាំបាច់ ដើម្បីទប់ស្កាត់កុំឱ្យអំពើឧក្រិដ្ឋកម្មទាំងនោះ កើតឡើង ឬក៏មិនបានផ្តន្ទាទោសដល់ចារីទាំងអស់នោះ ។

១១៣. យើងមានសំអាងគ្រប់គ្រាន់ថា ទាក់ទិននឹង **តា អាន តា ទិត** និង **អ៊ឹម ចែម** ល័ក្ខខ័ណ្ឌតម្រូវចាំបាច់ ដែលមានចែងនៅក្នុងវិធាន៤២ និងវិធាន៦៣ សម្រាប់ការនាំខ្លួន និងឃុំខ្លួនបណ្តោះអាសន្ន រង់ចាំការស៊ើបសួរ និងបើកសវនាការត្រូវបានបំពេញហើយ ដូច្នេះពិចារណាថា៖

ក. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ផ្តល់នូវមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនសង្ស័យទាំងនេះបានប្រព្រឹត្តបទឧក្រិដ្ឋមួយ ឬច្រើន ដូចបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ។ ភស្តុតាងប្រមូលបាន នៅក្នុងរយៈពេលស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញា រួមមាន សាក្សី និងឯកសារភស្តុតាងផ្សេងៗ គាំទ្រចំពោះភវនីយភាពដែលថាជនសង្ស័យដូចបានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ នឹងត្រូវបានកាត់ឱ្យជាប់ទោសចំពោះឧក្រិដ្ឋកម្មនានាដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ និងត្រូវបានផ្តន្ទាទោសតាមច្បាប់អ.វ.ត.ក ។

ខ. ដោយសារភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត និងភវនីយភាពដែលជនសង្ស័យទាំងនេះនឹងត្រូវទទួលទោសដ៏វែងចំពោះបទឧក្រិដ្ឋទាំងនោះ ហេតុនេះហើយពិតជាមានផលអាក្រក់នៃការរត់គេចខ្លួនពីយុត្តិធម៌ និងការមិនចូលខ្លួននៅពេលមានសវនាការនៃជនសង្ស័យទាំងនេះ ។ ជនសង្ស័យទាំងនេះមានលទ្ធភាព និងមធ្យោបាយផ្នែកសេដ្ឋកិច្ចគ្រប់គ្រាន់ ដើម្បីគេចខ្លួនចេញពីប្រទេស និង/ឬបើមិនដូច្នោះទេគេចពីយុត្តិធម៌ ។ ជនសង្ស័យបានដឹងថា អ.វ.ត.ក ត្រូវបានបង្កើតឡើង ហើយកិច្ចដំណើរការនីតិវិធីរបស់តុលាការក៏បានចាប់ផ្តើមហើយដែរ ។ ហេតុដូច្នេះហើយ វាទំនងយ៉ាងខ្លាំងដែលថា ជនសង្ស័យទាំងនេះនឹងប្រើប្រាស់គ្រប់មធ្យោបាយដែលមានដើម្បីគេចខ្លួនពីយុត្តិធម៌ ។ យ៉ាងហោចណាស់មានជនសង្ស័យ២នាក់ ក្នុងចំណោមជនសង្ស័យទាំងនេះរស់នៅក្បែរព្រំដែនខ្មែរ-ថៃ ។

គ. ដោយសារមុខតំណែងជាន់ខ្ពស់របស់ជនសង្ស័យដែលបានកាប់កាន់កាលពីអតីតកាល និងដោយសារចរិតនៃបទឧក្រិដ្ឋដែលមានលក្ខណៈទំលូទូលាយ ជាប្រព័ន្ធ និងធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តដោយជនសង្ស័យ មានវភីនីយភាពគ្រប់បែបយ៉ាងដែលថា សាក្សី ជនរងគ្រោះ និងតតីយជន នឹងមានអារម្មណ៍ថា ពួកគាត់ទទួលរងការគំរាមកំហែង និងការបំភិតបំភ័យ ដែលជាហេតុរារាំងពួកគាត់មិនឱ្យជួយដល់អង្គជំនុំជំម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រសិនបើជនសង្ស័យមិនត្រូវបានចាប់ និងឃុំខ្លួនដើម្បីរង់ចាំការស៊ើបសួរ និងបើកសវនាការទេនោះ ។

ឃ. ខណៈដែលការស៊ើបអង្កេត និងសវនាការជាបន្តបន្ទាប់ ទំនងជាទាក់ទាញចំណាប់អារម្មណ៍ ការចូលរួម និងការរំជើបរំជួលរបស់សាធារណជនយ៉ាងធំនោះ ដើម្បីជាប្រយោជន៍ដល់យុត្តិធម៌ដែលជនសង្ស័យទាំងនេះត្រូវតែបានចាប់ខ្លួន និងឃុំខ្លួន ដើម្បីធានាឱ្យមានសន្តិសុខរបស់ពួកគេ និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ។

១១៤. យើងមានសំអាងគ្រប់គ្រាន់ថា ល័ក្ខខ័ណ្ឌតម្រូវចាំបាច់នានា ដើម្បីផ្តល់ឱ្យមានវិធានការការពារសម្រាប់បុគ្គលម្នាក់ៗ រួមមាន ជនរងគ្រោះ សាក្សី និងតតីយជន ទោះបាននិយាយយោងដោយចំពោះ ឬមិនចំពោះក្តី ឬតាមការធ្វើឱ្យជាប់ជំពាក់ដោយចាំបាច់ក្តី ដែលមាននៅក្នុងដីកាសន្និដ្ឋាន

បញ្ជូនរឿងឱ្យស៊ើបសួរនេះ នៅក្នុងសំណុំរឿងអមមកជាមួយ និងនៅក្នុងឯកសារភស្តុតាងដទៃទៀត ដែលភ្ជាប់មកជាមួយនេះក៏ដោយ គឺយើងមានសំអាងគ្រប់គ្រាន់ ។ វិធានការការពារទាំងអស់នេះ សំខាន់ចាំបាច់ណាស់ពីព្រោះថាជោគជ័យនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា គឺអាស្រ័យលើលទ្ធភាព និងឆន្ទៈរបស់សាក្សីទាំងនោះ ក្នុងការជួយស្វែងរក ការពិត ។ ជាងនេះទៀត ជនរងគ្រោះ សាក្សី និងតតីយជន ដែលបានជាប់ពាក់ព័ន្ធក្នុងដំណើរការ នីតិវិធីទាំងនេះមានសិទ្ធិទទួលបាននូវសុវត្ថិភាពចំពោះជីវិត និងទ្រព្យសម្បត្តិរបស់ពួកគេ ការប្រព្រឹត្តិ មកលើដោយសមរម្យ ការគោរព និងភាពជាឯកជនសមហេតុផល ស្របទៅនឹងដំណើរការនៃសិទ្ធិ សមស្របរបស់ជនសង្ស័យ ។

១១៥. នៅដំណាក់ការស៊ើបសួរបឋមនេះ នៅពេលដែលការវិភាគល្អិតល្អន់មួយមិនទាន់ធ្វើនៅឡើយទាក់ទិននឹង គោលគំនិតស្តីពីការគំរាមកំហែង ទៅលើសាក្សីជនរងគ្រោះ និងតតីយជនម្នាក់ៗ សហព្រះរាជអាជ្ញាស្នើរឱ្យមាន វិធានការការពារជាមូលដ្ឋានជាក់លាក់សំរាប់ពួកគាត់ រហូតដល់ពេល មានការវាយតម្លៃល្អិតល្អន់ជាក់លាក់ពី បុគ្គលម្នាក់ៗត្រូវបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ។ វិធានការអន្តរកាលនេះគួរតែ មាន ប៉ុន្តែមិនត្រូវកំណត់ត្រឹមអ្វីដែលមានចែងដូចខាងក្រោមនេះប៉ុណ្ណោះទេ ៖

ក. ការមិនលាតត្រដាងជាសាធារណ:[483] រួមមានទាំង ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានតាមរយៈការបោះពុម្ព និង ជាអេឡិចត្រូនិចនៃឯកសារណាមួយក៏ដោយ[484] ដែលភ្ជាប់មកជាមួយនេះ និងរាប់បញ្ចូលទាំង តែមិនបាន កំណត់ត្រឹមតែសក្ខីកម្ម ឬកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ឬអត្តសញ្ញាណរបស់ សាក្សី ឬរបស់ ក្រុមសាក្សីប៉ុណ្ណោះទេ លើកលែងតែមានការចាំបាច់សមហេតុផល សម្រាប់ភាគីការពារក្តី និងភាគីដើម បណ្តឹងរដ្ឋប្បវេណី ដើម្បីចូលរួម និងជួយក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះតែប៉ុណ្ណោះ ។

ខ. ការផ្តល់ជូននូវឯកសារប្រភេទនេះ គឺសម្រាប់តែសមាជិកដែលបានចាត់តាំង នៃក្រុមមេធាវី ការពារក្តី របស់ជនសង្ស័យ និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពេលឈ្មោះរបស់ពួកគាត់ ត្រូវបាន ចុះក្នុងបញ្ជី ពិសេសដែលបានរក្សាទុកដោយ ការិយាលយសហចៅក្រមស៊ើបអង្កេត និងបន្ទាប់ពីពួក គេបានចុះហត្ថលេខា លើសម្បថមិនលាតត្រដាងព័ត៌មានបែបនេះជាសាធារណៈ រួមទាំងប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មានតាមរយៈការបោះពុម្ព និងជាអេឡិចត្រូនិច លើកលែងតែមានការចាំបាច់សមហេតុផល ដើម្បីអនុញ្ញាតឱ្យអ្នកទាំងនោះត្រៀបករណី របស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែប៉ុណ្ណោះ ។

